# មាតិកាអត្ថបទ


 ជំពូក ១: ពូជជ្រូក ........................................................... ៥

១. ពូជជ្រូកក្នុងស្រុក ........................................................... ៥

២. ពូជជ្រូកនាំចូល ........................................................... ៧

៣. ពូជកូនកាត់ ........................................................... ៩

 ជំពូក ២: ការចិញ្ចឹមជ្រូក និងប្រព័ន្ធនៃការសាងសង់ទ្រុង ........................................... ១២

១. ប្រព័ន្ធនៃការចិញ្ចឹមនៅក្នុងប្រទេសឡាវ ........................................... ១២

២. ការសាងសង់ទ្រុងជ្រូក ........................................................... ១៥

៣. ទ្រុង កំរាល និងតំរូវការទីធ្លា ........................................................... ១៩

៤. ប្រព័ន្ធនៃការប្រក់ដំបូលខុសៗគ្នា ........................................................... ២២

 ជំពូក ៣: ប្រព័ន្ធនៃការផ្តល់ចំណី ........................................................... ២៤

១. ការផ្តល់ចំណីសត្វតាមបែបបុរាណ ........................................................... ២៤

២. ការផលិតចំណីតាមបែបបុរាណ ........................................................... ២៨

៣. ការផលិតចំណីតាមបែបឧស្សាហកម្ម ........................................................... ២៩

៤. ការលាយចំណីតាមបែបឧស្សាហកម្មលាយជាមួយចំណីតាមបែបទំលាប់ ......... ៣០

៥. ការគ្រប់គ្រងចំណីទូទៅ ........................................................... ៣២

 ជំពូក ៤: ការជ្រើសរើសពូជជ្រូក ........................................................... ៣៨

១. ការជ្រើសរើសជ្រូកបា និងជ្រូកមេក្រមុំ ........................................... ៣៨

២. ជ្រូកមេដែលផ្តល់ផលច្រើន ........................................................... ៣៩

៣. ការផ្តល់ចំណី និងខ្សែស្រឡាយនៃពូជ ........................................... ៤១

 ជំពូក ៥: ការបង្កាត់ពូជ ........................................................... ៤៥

១. ការគ្រប់គ្រងមេជ្រូកក្រមុំ ........................................................... ៤៥

២. ការគ្រប់គ្រងមេជ្រូកផ្តាច់ដោះ ........................................................... ៤៦

៣. ការបង្កាត់ជ្រូកបាក្មេង ........................................................... ៤៧

៤. វដ្តនៃអ៊ីស្ត្រូសែន ការបង្កាត់តាមបែបធម្មជាតិ សិប្បនិម្មិត និងថ្ងៃកើតកូន ..... ៤៨

៥. ការកត់សំគាល់មេជ្រូករកឈ្មោល....................................................៥២
៦. ការគ្រប់គ្រងការបង្កាត់ ....................................................................៥៣
៧. ការគ្រប់គ្រងការដាក់បា....................................................................៥៦

ជំពូក ៦: មេជ្រូកដើម.........................................................................៥៧
១. ការត្រួតពិនិត្យ និងការកត់ត្រាមេជ្រូកដើម.........................................៥៧
២. ការផ្តល់ចំណី និងសុខភាពមេជ្រូក.......................................................៥៨

ជំពូក ៧: ការកើតកូន ........................................................................៦១
១. មុនពេលកើត ក្នុងពេលកើត និងក្រោយពេលកើតកូន...............................៦១
២. ការថែទាំសុខភាពកូនជ្រូកទើបកើត និងមេជ្រូក .....................................៦៤

ជំពូក ៨: មេជ្រូកបំបៅដោះ និងកូនជ្រូក ..................................................៦៧
១. ទ្រុង និងទីធ្លាសំរាប់កូនជ្រូក ..............................................................៦៧
២. ការថែទាំសុខភាពកូនជ្រូក និងមេជ្រូក...................................................៦៨
៣. ការសាងសង់ទ្រុង អនាម័យ និងការផ្តល់ចំណី.........................................៧០
៤. តារាងមេជ្រូកបំបៅដោះ និងកូនជ្រូក.....................................................៧២

ជំពូក ៩: ការថែរក្សា និងការផ្តាច់ដោះកូនជ្រូក ........................................៧៣
១. ភាពស៊ាំ និងពេលវេលាផ្តាច់ដោះ..........................................................៧៣
២. ការផ្តល់ចំណី និងទ្រុងសំរាប់កូនជ្រូកផ្តាច់ដោះ.........................................៧៧
៣. ការចាប់ និងដឹកកូនជ្រូក....................................................................៧៩

ជំពូក ១០: ជ្រូកជំទង់ និងជ្រូកសាច់ ......................................................៨០
១. បញ្ហាលើជ្រូកជំទង់ និងកំឡុងពេលជ្រូកសាច់..........................................៨០
២. ការបែងចែកជាក្រុម និងការផ្តល់ចំណី...................................................៨២
៣. តារាងសំរាប់ជ្រូកជំទង់ និងជ្រូកសាច់ ...................................................៨៤

ជំពូក ១១: ការត្រួតពិនិត្យ និងកត់ត្រាផលិតផល.......................................៨៦
១. ការថែរក្សាការកត់ត្រា.........................................................................៨៦
២. ទិសដៅផលិតកម្ម..............................................................................៨៨


ជំពូក ១២: ការត្រួតពិនិត្យសុខភាពជ្រូក ........................................................................៩០

១. ការធ្វើអនាម័យ និងវិធានការត្រួតពិនិត្យសុខភាព........................................៩០

២. គោលការណ៍ការពារជំងឺ..........................................................................៩៣

៣. ការដាក់ជ្រូកថ្មីចូលក្នុងកសិដ្ឋាន ..................................................................៩៤


ជំពូក ១៣: ជំងឺជ្រូក ..................................................................................................៩៦

១. ចំណាត់ថ្នាក់ជំងឺប៉េស្តជ្រូក ............................................................................៩៦

២. ជំងឺអុតក្តាម...........................................................................................................៩៧

៣. ជំងឺព្រូនមូល .........................................................................................................៩៨

៤. ជំងឺរាគកូនជ្រូក ......................................................................................................៩៩

៥. ជំងឺកញ្ច្រិល .........................................................................................................១០០

៦. ជំងឺអង្គែរ ...............................................................................................................១០១

៧. តេឡាវ៉ ..................................................................................................................១០២

# ឧបសម្ព័ន្ធរូបភាព

១. ពូជជ្រូក....................១០៤
២. ការជ្រើសរើសពូជ....................១០៥
៣. ទ្រុងជ្រូក និងកំរាល....................១០៦
៤. ស្នូកទឹក និងស្នូកចំណី....................១០៧
៥. ចំណី : អនុផល និងគ្រាប់ធញ្ញជាតិ....................១០៨
៦. ចំណី : ការធ្វើចំណីតាមបែបធម្មជាតិ....................១០៩
៧. ចំណី : ការធ្វើចំណីតាមបែបឧស្សាហកម្ម....................១១០
៨. ការថែទាំកូនជ្រូក....................១១១
៩. មេជ្រូកបំបៅកូន និង កូនជ្រូក....................១១២
១០.ការចាប់ជ្រូក និងការចាក់ថ្នាំការពារ....................១១៣
១១. ជំងឺ និងភាពមិនប្រក្រតី....................១១៤
១២. ការក្រៀវកូនជ្រូក....................១១៥
១៣. ការយកវត្ថុវិភាគទៅមន្ទីរពិសោធន៍....................១១៥
១៤. កសិដ្ឋានចិញ្ចឹមជ្រូកខ្នាតធំ....................១១៦
១៥. រូបភាពជ្រូកផ្សេងៗ....................១១៧

# ជំពូក ១: ពូជជ្រូក



## ១. ពូជជ្រូកក្នុងស្រុក

### ជ្រូកក្នុងស្រុក (ប្រភេទទី១)

ជ្រូកប្រភេទនេះអាចត្រូវបានគេប្រទះឃើញនៅក្នុងប្រទេស។ វាមានទំហំដងខ្លួនតូចប្រៀបធៀប ទៅនឹងប្រភេទជ្រូកក្នុងស្រុកដទៃទៀត។ ឈ្មោះរបស់វាខុសៗគ្នាពីតំបន់ទៅតំបន់ ឧទាហរណ៍ ម៉ុឈីត (Muchid), ម៉ុកាដូន (Mukadone), ម៉ុបប៉ាវ (Muboua) ទោះជាបីយ៉ាងណាក៏ដោយជាធម្មតាគេ ហៅវាថា ម៉ុលឡាត់ (Muladt) ។

អាយុរកឈ្មោលលើកដំបូងប្រហែល ៨-៩ខែដែលមានទំងន់ដងខ្លួនពី ២១-៣០គីឡូក្រាម ទំងន់ពេញវ័យរបស់ជ្រូកញីគឺប្រហែល ៤២-៤៨គីឡូក្រាម។ អាយុកើតកូនលើកទី១ គឺប្រហែល ១២ខែ ដែលមានអត្រាកើតកូន១.៥ក្នុងមួយឆ្នាំ និងក្នុងមួយសំបុកមានកូនជ្រូកពី ៧-៨ក្បាល។ កូនជ្រូកត្រូវបានគេផ្តាច់ដោះនៅអាយុ ២-៣ខែ និងមានទំងន់ប្រហែល ៧-៨គីឡូក្រាម។ ជ្រូកឈ្មោលពេញវ័យអាយុ ៦ខែ ទំងន់៣០គីឡូក្រាម។



រូបភាពជ្រូក ម៉ុលឡាត់ ប្រភេទ១

លក្ខណៈពូជនេះគឺ

- បណ្តោយដងខ្លួនប្រហែល ៧៥-៩២សង់ទីម៉ែត្រ និងកំពស់ប្រហែល ៤៦-៥៤សង់ទីម៉ែត្រ
- ថ្គាមវែង និងស្រួច ស្រដៀងគ្នាទៅនឹងជ្រូកព្រៃ
- ទំហំត្រចៀកមធ្យម ហើយជាទូទៅត្រង់
- ស្បែកពណ៌ខ្មៅ ប៉ុន្តែជ្រូកខ្លះពណ៌ស និងអុចៗ
- ភាគច្រើនក្រចកពណ៌ស

### ជ្រូកក្នុងស្រុក (ប្រភេទទី២)

ជ្រូកប្រភេទទី២ ធំជាងប្រភេទទី១។ អាយុរកឈ្មោលលើកទី១ប្រហែល១ឆ្នាំ ទំងន់ប្រហែល ៣៩គីឡូក្រាម។ ជ្រូកពេញវ័យទំងន់ប្រហែល ៤៧-៦១គីឡូក្រាម។



រូបភាពជ្រូក ម៉ុលឡាត់ ប្រភេទ ២

លក្ខណៈពូជនេះគឺ

- បណ្តោយដងខ្លួនប្រហែល ៨៥-១០០សង់ទីម៉ែត្រ និងកំពស់ប្រហែល ៥១-៧០សង់ទីម៉ែត្រ
- ដងខ្លួនពណ៌ខ្មៅ
- ពេលខ្លះពណ៌ផ្នែកក្រោមពណ៌ស
- ត្រចៀកខ្លីហើយត្រង់

## ជ្រូកក្នុងស្រុក (ប្រភេទទី៣)

ប្រភេទទី៣មានមាឌធំនិងធ្ងន់ ប្រជាជនភាគច្រើនហៅពូជជ្រូកនេះថា ពូជម៉ុឡាវសាំង។ អាយុរកឈ្មោលលើកទី១ប្រហែល ៥-៦ខែ ដែលមានទំងន់ដងខ្លួនប្រមាណ ៣០-៤០គ.ក។ ទំងន់ពេញវ័យរបស់ជ្រូកមេ គឺ ៦៥-៨៥គ.ក និងអាយុកើតកូនលើកទី ១គឺ ១០-១១ខែ។

ចរិកលក្ខណៈរបស់ពូជនេះគឺ

- ដងខ្លួនមានប្រវែងប្រហែល ១០០-១៣៥សង់ទីម៉ែត្រ និង មានកំពស់ប្រហែល ៥៥-៧៦សង់ទីម៉ែត្រ។
- ពណ៌នៅលើដងខ្លួនភាគច្រើនខ្មៅ ហើយតំបន់ពោះភាគច្រើនពណ៌ស-ខ្មៅ
- ច្រមុះមានពណ៌ស និង មានមុខខ្លី
- មានត្រចៀកធំ ពណ៌ខ្មៅ ហើយកោង



រូបភាពជ្រូក ម៉ុលឡាត់ ប្រភេទ ៣

## ២. ពូជជ្រូកនាំចូល

ជាទូទៅ ពូជជ្រូកសំរាប់ផលិតកម្មជ្រូកបែបឧស្សាហកម្មភាគច្រើន គឺ ឡាចវ៉ាយ (Large white) ឡង់ដ្រាស់ (Landrace) និងពូជជ្រូកឌុយរ៉ុក (Duroc) រឺពូជកូនកាត់។ ពូជទាំង ៣ប្រភេទនេះផលិតសាច់ក្រហមដោយរួមផ្សំជាមួយនឹងប្រសិទ្ធភាពរបស់ចំណីផងដែរ (៣គ.កនៃចំណីមានគុណភាពផលិតបានសាច់ជ្រូក១គ.ក)។ តែបើប្រៀបធៀបទៅនឹងពូជជ្រូកក្នុងស្រុក ពូជជ្រូកនាំចូលទាំនេះមិនសូវធន់ទៅនឹងជំងឺ ហើយងាយរងនូវបញ្ហាផ្សេងៗពីអាកាសធាតុក្តៅ និង ចំណីដែលមានគុណភាពអន់។ ជាទូទៅ ពូជសុទ្ធដែលគេ នាំចូលចិញ្ចឹមមិនបានផលល្អទេនៅតំបន់ជនបទ។

### ពូជឡាយវ៉ាយ (យ៉កសៀរ)

ពូជឡាយវ៉ាយមានប្រភពដើមពីប្រទេសអង់គ្លេស និង ចិញ្ចឹមបានល្អក្នុងប្រទេសឡាវ។ វាមានទំងន់ដងខ្លួនពី ៨0-៩0គ.ក នៅអាយុ ៥-៦ខែ។ ជ្រូកមេគឺជាមេល្អដែលមានកូនពី១០-១១ក្បាលក្នុងមួយ សំបុក និងផ្តល់ កូនជ្រូកដែលមានសុខភាពល្អបានរយៈពេល ៤-៥ឆ្នាំ។ ពូជជ្រូកនេះលូតលាស់លឿន និង ផលិតសាច់ក្រហមមានគុណភាពល្អ។



រូបភាពពូជជ្រូកឡាយវ៉ាយ

លក្ខណៈរបស់ពូជជ្រូកនេះគឺ

- ដងខ្លួនពណ៌ស
- ក្បាលតូច ត្រចៀកបញ្ឈរ
- ស្មាធំ ខ្នងត្រង់
- ដងខ្លួនវែង ជើងរឹងមាំ
- ច្រមុះខ្លី

**ពូជឡង់ដ្រាស:**

ពូជឡង់ដ្រាសមានប្រភពដើមពីប្រទេសដែណឺម៉ាក និងចិញ្ចឹមបានល្អក្នុងលក្ខខណ្ឌប្រទេសឡាវ ។ វាអាចមានទំងន់ដងខ្លួនពី ៨០-៩០គ.កនៅអាយុ៥-៦ខែ ។ ជ្រូកមេគឺជាមេល្អដែលមានកូនពី ១០-១២ក្បាលក្នុងមួយសំបុក ។ ពូជនេះលូតលាស់លឿន និងផ្ទាំងសាច់មានគុណភាពល្អ ។

លក្ខណៈរបស់ពូជឡានដ្រេសគឺ

- រោម និងស្បែកពណ៌ស
- ត្រចៀកធំធ្លាក់ចុះ
- ក្បាលតូច និងច្រមុះវែង
- ត្រគាកធំ និងខ្នងកោង

**ពូជឌុយរ៉ុក :**

ពូជឌុយរ៉ុកមានប្រភពដើមមកពីប្រទេសអាមេរិកខាងជើង ។ វាមានកំរិតលូតលាស់លឿន និងមានលទ្ធភាពល្អសំរាប់យកមកចិញ្ចឹមក្នុងលក្ខខណ្ឌអាកាសធាតុប្រែប្រួលតំបន់ត្រូពិច ។ កូនជ្រូកក្នុងមួយសំបុកមាន ចំនួនតិចគឺប្រហែល៧-៨ក្បាល ។ ពពួកវាត្រូវបានប្រើយ៉ាងសំខាន់ទុកជាមេបាសំរាប់បង្កាត់ពូជ ។

រូបភាពពូជជ្រូកឌុយរ៉ុក



លក្ខណៈរបស់ពូជជ្រូកនេះគឺ

- សំបុរពណ៌ត្នោត
- ត្រចៀកមធ្យម និងធ្លាក់បន្តិច
- ក្បាលធំ ច្រមុះខ្លី
- ត្រគាកធំ

## ៣-ពូជជ្រូកកូនកាត់

ការកែលំអរនៃពូជជ្រូកក្នុងស្រុក

ការកែលំអរពូជ គឺជាកត្តាសំខាន់ដែលគេអាចធ្វើបាន និង ទទួលបានទិន្នផលពីសត្វខ្ពស់ ។ គោលបំណងចំបងនៃការកែលំអរពូជ គឺណែនាំនូវលក្ខណៈជាវិជ្ជមានចំពោះពូជជ្រូកក្នុងស្រុក ។ ឧទាហរណ៍ តាមរយៈការបង្កាត់រវាងមេជ្រូកក្នុងស្រុកជាមួយបាជ្រូកនាំចូល កូនជ្រូកគឺទទួលមរតដងខ្លួន និង អត្រានៃការលូតលាស់លឿនដូចឪពុករបស់វា និងភាពធន់ទៅនឹងអាកាសធាតុបានមកពីម្តាយរបស់វា ។ គារបង្កាត់ពូជតែមួយរវាង បា និងកូនមេ និងកូន កូនញី និងកូនឈ្មោលក្នុងសំបុកតែមួយ ។ល ។ គឺត្រូវតែចៀសវាងជាដាច់ខាត ។

ពូជជ្រូកបានាំចូលដែលផ្តល់សាច់បានច្រើន

មេជ្រូកក្នុងស្រុកដែលល្អ ធន់ទៅនឹងអាកាសធាតុក្នុងតំបន់បានល្អ



បាពូជនាំចូល កូនបាដែលផលិតបានសាច់ច្រើន

ពពួកវាគួរតេគ្រៀវ ចិញ្ចឹមសាច់រឺ សំលាប់

រូបភាពការបង្កាត់ពូជ

មេដែលគេបានជ្រើសរើសពីកូននៃការបង្កាត់ខាងលើអាចត្រូវបាគេដាក់ឈ្មោលជាមួយបានាំចូលដែលមានជាប់ខ្សែស្រឡាយ ។ ទ្រុងជ្រូកបែបឧស្សហកម្ម ប្រើប្រព័ន្ធនៃការបង្កាត់នេះ ៤-៥ជំនាន់ដើម្បីឈានទៅដល់ការ បង្កាត់ពូជដែលតំរូវតាមសេចក្តីត្រូវការ ។

## ពូជជ្រូកស៊ីងជីមកពីប្រទេសចិន

ពូជជ្រូកស៊ីងជីមានប្រភពដើមមកពីប្រទេសចិនភាគខាងត្បូង ។ ពួកវាត្រូវបានគេកែលំអរជាពូជកូនកាត់ដែលគេបង្កាត់រវាងពូជជ្រូកក្នុងស្រុករបស់ប្រទេសចិន ជាមួយនឹងពូជជ្រូកនាំចូល ( ជាពិសេសពូជឌុយរ៉ុក) ។ ពូជជ្រូកស៊ីងជី គឺពូជមាននិរន្តភាពសំរាប់រក្សាទុកនៅតាមភូមិ ដែលការអនុវត្តន៏ការចិញ្ចឹមសត្វត្រូវបានគេកែ លំអរ ( ការប្រើទ្រុងជ្រូកស្អាត ការត្រួតពិនិត្យការចាក់ថ្នាំការពារបានម៉ត់ចត់ ចំណីដែលធ្វើនៅផ្ទះលាយជាមួយចំណីបែបឧស្សាហកម្មមានគុណភាពល្អ) ។ ជាមួយនឹងការចិញ្ចឹមសត្វដែលគេកែលំអរទាំងនេះ ពូជនេះអាចទប់ទល់នឹងអាកាសធាតុក្តៅ និងសើមបានល្អប្រសើរជាងពូជជ្រូកនាំចូល នៅក្នុងប្រទេសឡាវ ។

ទោះបីជាយ៉ាងណាក៏ដោយ ការបង្កាត់លើកដំបូងគឺពណ៌ខ្មៅ គឺការបង្កាត់រវាងមេជ្រូកស៊ីងជី និងជាមួយបាស៊ីងជីដែលវាអាចផលិតកូនដែលមានពណ៌ខ្មៅច្រើន ប៉ុន្តែមានកូនជ្រូកខ្លះពណ៌ដូចត្នោត ស្នាមអុជៗ រឺឆ្នូត ។

លក្ខណៈសំខាន់ផ្សេងទៀតរបស់ពូជនេះគឺ:



- ខ្នងវែង និង ត្រង់រាងកោងបន្តិច

- ភ្លៅធំ និងដៃជើងរឹងមាំ

- ក្បាលធំ ហើយខ្លី និងថ្ពាសជ្រួញ

- ស្លឹកត្រចៀកធំ និងធ្លាក់បន្តិច

- ជ្រូកញីភាគច្រើនមានដោះ៧គូរ និង

កូនមួយសំបុកពី ៩-១៣ក្បាល

- កូនជ្រូករឹងមាំ លូតលាស់ឆាប់រហ័ស

ហើយអាចកាប់បានមុនអាយុ

- ជ្រូកញីពេញវ័យមានទំងន់ពី

១០០-១៥០គ.កដែលមានអាយុ១-១.៥ឆ្នាំ

- ជ្រូកបាពេញវ័យមានទំងន់ពី ១២០-១៨០គ.ក

- ជ្រូកមេក្រមុំដាក់ឈ្មោលនៅអាយុ ៨-៩ខែមានទំងន់យ៉ាងហោចណាស់ ៨០គ.ក

ពូជជ្រូកស៊ីងជីមានគុណវិបត្តិធំ២ពីរ:

១. ពូជនេះហាក់ដូចជាងាយទទួលការឆ្លងអង្កែជាងពូជជ្រូកក្នុងស្រុក។ ត្រួតពិនិត្យឱ្យបានម៉ត់ចត់លើ ចៃ អង្កែ ដោយប្រើថ្នាំដូចជា អ៊ីវូម៉ិច ចាក់រៀងរាល់៣ខែម្តង។

២. យើងត្រូវដាក់ស៊ីនជីថ្មីឱ្យបានល្អ ជៀសវាងបង្កាត់ពូជតែមួយ និង បាត់បង់លក្ខណៈល្អនៃពូជជ្រូកស៊ីនជីនេះ ដែលត្រូវបានគេបង្កាត់រវាងពូជជ្រូកក្នុងស្រុកប្រទេសចិន និងពូជ្រូកនាំចូល (ឌុយរ៉ុក)។

## ជំពូក ២: ការចិញ្ចឹមជ្រូក និងប្រព័ន្ធនៃការសាងសង់ទ្រុង

### ២.១ ប្រព័ន្ធនៃការចិញ្ចឹមជ្រូកនៅក្នុងប្រទេសឡាវ

ការចិញ្ចឹមជាលក្ខណៈគ្រួសារនៅក្នុងប្រទេសឡាវជាទូទៅប្រពន្ធ័នៃការចិញ្ចឹមមាន ៤គឺ:

១. ការចិញ្ចឹមលែងឱ្យដើរសេរី

២. ការចិញ្ចឹមពាក់កណ្តាលប្រពលវប្បកម្ម( ធ្វើរបងពទ្ធ័ជុំវិញដោយមានទីធ្លាធំ)

៣. លក្ខណៈប្រពលវប្បកម្ម ( ដាក់បង្ខាំងធ្វើជាទ្រុង)

៤. កសិដ្ឋានធំរុះចិញ្ចឹមជ្រូក និងត្រី

***ការចិញ្ចឹមលែងដើររកស៊ីសេរី***



ប្រពន្ធ័ការចិញ្ចឹមបែបនេះភាគច្រើនមានជាទូទៅនៅតាមតំបន់ជនបទដោយចិញ្ចឹមពូជក្នុងស្រុក។

***<u>គុណប្រយោជន៏:</u>***

- ចំណាយទុន និងកំលាំងពលកម្មតិច

***<u>គុណវិបត្តិ:</u>***

- ទាមទារទីធ្លាធំ និងអាចស៊ីបំផ្លាញដំណាំ
- ជ្រូកពិបាកគ្រប់គ្រង ហើយអាចឆ្លងជំងឺយ៉ាងងាយស្រួយ
- ផ្តល់ផលតិច និងរំខានដល់អ្នកដទៃ



***ការចិញ្ចឹមពាក់កណ្តាលប្រពលវប្បកម្ម:*** ( ធ្វើរបងពទ្ធ័ដោយប្រើទីធ្លាធំ) គេអាចឃើញនៅតំបន់ជាយក្រុង រឺនៅក្នុងសហគមន៏ដែលមានឯកទេសខាងចិញ្ចឹមជ្រូកសាច់ក្នុងស្រុក។

***<u>គុណប្រយោជន៍:</u>***

- ការសាងសង់ទ្រុងធម្មតា ( មានតែដំបូលដែលការពារភ្លៀង និងពន្លឺព្រះអាទិត្យ

- ចំណាយទុនអស់តិចដូចជា អនុផល និងកាកសំណល់ផ្ទះបាយត្រូវបានគេផ្តល់ឱ្យជ្រូកស៊ី

***<u>គុណវិបត្តិ:</u>***

- ផ្តល់ផលបានតិច និងទាមទារទីធ្លាធំ

- ជ្រូកពិបាកត្រួតពិនិត្យ ( ឧទាហរណ៍: ការចាប់ព្យាបាលជាដើម)

- ជ្រូកងាយស្រួលនឹងឆ្លងជំងឺ ( ជាពិសេសនៅពេលគេយកជ្រូកថ្មីមកដាក់បញ្ចូលក្នុងទ្រុងតែមួយ)

***ការចិញ្ចឹមបែបប្រពលវប្បកម្ម:( ធ្វើទ្រុងជ្រូក)***

ប្រពន្ធ័បែបនេះត្រូវបានគេអនុវត្តដោយកសិករដែលមានគំនិតចង់កែលំអរការចិញ្ចឹមជ្រូក។ ជាទូទៅ កសិករទាំងនេះត្រូវបានគេប្រទះឃើញចិញ្ចឹមនៅទីកន្លែងណាដែលមានលក់ចំណីសំរេច( ចំណីបាវ) ។ ពពួកគាត់រស់នៅក្នុងតំបន់ពាក់កណ្តាលជាយក្រុង ហើយចិញ្ចឹមពូជនាំចូល និងពូជកូនកាត់សំរាប់លក់ទីផ្សារក្នុងស្រុក។



***<u>គុណប្រយោជន៍:</u>***

- ងាយស្រួលគ្រប់គ្រង ( ការផ្តល់ចំណី ផ្តល់ទឹក ត្រួតពិនិត្យសុខភាព កើតកូន ។ល។

- ងាយស្រួលធ្វើការចាក់ថ្នាំការពារ និងការព្យាបាល

- គ្រោះឆ្លងជំងឺមានតិច បើសិនកសិករប្រកាន់ខ្ជាប់នូវការធ្វើអនាម័យបានល្អ

- បរិយាកាសជុំវិញ ស្អាត និងដំណាំមិនត្រូវបានបំផ្លាញដោយជ្រូកដែលលែងឱ្យដើររកស៊ីចំណី។

- លាមកអាចធ្វើជីសំរាប់ស្រះត្រី រឺជាជីសំរាប់ដំណាំ (រឺសួនដំណាំ) របស់កសិករ

***<u>គុណវិបត្តិ:</u>*** - ចំណាយទុនអស់ច្រើន ( សំភារៈក្នុងទ្រុង ចំណី និងកំលាំង)

- កសិករទាមទារជំនាញក្នុងការគ្រប់គ្រងខ្ពស់

***ការចិញ្ចឹមបញ្ចូលគ្នាជ្រូក និងត្រី***

ស្រះចិញ្ចឹមត្រីអាចត្រូវបានទទួលជីជាតិដោយលាមកជ្រូក ។ សារាយត្រូវបានបង្កើតដែលត្រីអាចស៊ីជាចំណីបាន ។ បើសិនទឹកមានគ្រប់គ្រាន់រយៈពេលវែងនៅក្នុងស្រះ ទ្រុងជ្រូកគួរតែសាងសង់នៅលើស្រះឱ្យបានច្រើន ដើម្បីឱ្យលាមកជ្រូកអាចធ្លាក់ចំកណ្ដាលស្រះ រឺសង់ក្បែរស្រះដែលអាចបញ្ចូលទៅក្នុងស្រះបាន ។ ប្រភេទត្រីទីឡាយ៉ាផ្សេងៗគ្នាភាគច្រើនត្រូវបានគេចិញ្ចឹមដាក់លាយជាមួយ ត្រីកាប និង ត្រីអណ្ដែង ជាញឹកញាប់ ។



ជ្រូកចំនួន ៦០ក្បាលងាប់ផលិតលាមកគ្រប់-គ្រាន់សំរាប់ស្រះត្រី ១ហិចតា ដែលអាចចិញ្ចឹមត្រីបានចំនួន ៤០០០០ក្បាល ហើយផ្ដល់ទិន្នផលចាប់ពី ៤០០០គ.កឡើងទៅក្នុងមួយឆ្នាំ ។ ប្រសិនលាមកជ្រូកមិនគ្រប់គ្រាន់ទេអាច ត្រូវបានគេចិញ្ចឹមដើម្បីបន្ថែមលាមកឱ្យបានច្រើនទៀតទៅក្នុងស្រះ ។ រុក្ខជាតិដែលដុះនៅក្នុងស្រះទឹក អាចប្រមូលដាក់ ឱ្យជ្រូកស៊ីវិញបាន ។

ការថែទាំដោយយកចិត្តទុកដាក់ គឺជាការចាំបាច់ជាពិសេសនៅពេលដែលយើងប្រើ អ៊ីវ៉ូម៉ិចសំរាប់កំចាត់ចៃ និង ប៉ារ៉ាសិតខាងក្នុង ។ កាកសំណល់តិចតួចរបស់អ៊ីវ៉ូម៉ិចបានបញ្ចេញមកតាមរយៈលាមកអាចសំលាប់ត្រីនៅក្នុងស្រះបាន



ចូរប្រុងប្រយត្ន័លាមករបស់ជ្រូកចាក់ថ្នាំព្យាបាល មិនត្រូវដាក់ចូលក្នុងស្រះទេ ទុករយៈពេល១អាទិត្យសិន (យកសំបកការ៉ុងត្រងពីក្រោមបន្ទះឈើហើយយកប៉ែលចូកចោល) ។ រឺ ជំរើសម្យ៉ាងទៀត លាងជ្រូកជាមួយថ្នាំ ដោយលាងនៅខាងក្រៅទ្រុង ។

## ២.២ ការសាងសង់ទ្រុងជ្រូក

### ***ការជ្រើសរើសទីតាំង***





- ទីតាំងគួរនៅកន្លែងខ្ពស់ដែលទឹកមិនអាចជន់លិច នៅខែវស្សា

- ទីតាំងគួរតែអាចការពារពីពន្លឺព្រះអាទិត្យ (ម្លប់ពិដើមឈើ) ហើយធំទូលាយខ្យល់បរិសុទ្ធ ។

- នៅឆ្ងាយពីលំនៅដ្ឋាន (ប្រហែល ៨-១០ម៉ែត្រ មិននៅក្រោមខ្យល់)

- ក្នុងករណីចិញ្ចឹមជ្រូកច្រើន ទីតាំងដែលជ្រើសរើស ត្រូវការដូចជា:

  + អាចជាប់ផ្លូវល្អជារៀងរហូត
  + មានទីកន្លែងសមរម្យសំរាប់ចោលលាមក
  + អាចភ្ជាប់ប្រភពទឹក និងភ្លើងដែលអាចជឿទុកបាន



ការចិញ្ចឹមជ្រូកដាក់ទុនតិច ទទួលបានផលតិច



ចំណាយទុនក្នុងការសាងសង់ទ្រុងជ្រូក អាស្រ័យទៅលើកំរិតនៃការគ្រប់គ្រងជ្រូក និងការដាក់ទុន (ដាក់ទុនតិចផ្ទុយទៅនឹងប្រពន្ធ័បានផលខ្ពស់)





ការចិញ្ចឹមជ្រូកដាក់ទុនច្រើន ទទួលបានផលតិច

### ***ឧបករណ៍ និងការសាងសង់ទ្រុងជ្រូក***

ទ្រុងជ្រូកមួយអាចសាងសង់ក្នុងតំលៃយ៉ាងថោកដោយប្រើឧបករណ៍ដែលអាចរកបាននៅក្នុងតំបន់។ វាជាការចាំបាច់ ដើម្បីសាងសង់ទ្រុងវាពឹងផ្អែកលើលក្ខខ័ណ្ឌអាកាសធាតុ និងអាស្រ័យទៅលើប្រពន្ធ័ផលិតកម្មជ្រូកផងដែរ។ ត្រូវយកចិត្តទុកដាក់បញ្ហាដូចតទៅនេះ

១. ទ្រុងជ្រូកគួរតែផ្តល់កក់ក្តៅដល់ជ្រូក : ខ្យល់ចេញចូលបានល្អ និងពន្លឺគ្រប់គ្រាន់ មិនក្តៅពេក មិនធំក្លិនស្អុយ មិនត្រជាក់ពេក និងមិនសើមពេក។

២. ទ្រុងជ្រូកគួរតែសាងសង់តាមបណ្តោយអក្សតាមទិសពីកើតទៅលិច (ដើម្បីការពារពីព្រះអាទិត្យ និងភ្លៀង)

៣. ទ្រុងជ្រូកចាំបាច់ត្រូវបែងចែកទ្រុងឱ្យខុស១គ្នាទៅតាមដំណាក់កាលនិមួយ១នៃវដ្តផលិតកម្ម។ ចំនួន និងទំហំរបស់ទ្រុងវាអាស្រ័យទៅលើតំរូវការនៃចំនួនជ្រូកដែលគេត្រូវដាក់នៅក្នុងទ្រុងតាមដំណាក់កាលផលិតកម្មនិមួយ១។

៤. តំលៃនៃការសាងសង់ទ្រុងជ្រូកត្រូវសមស្របទៅនឹងប្រពន្ធ័នៃផលិតកម្មជ្រូក។ ផលិតកម្មជ្រូកដែលឱ្យផលល្អមួយ ទាមទារឱ្យមានចំណាយថ្លៃនៃការសាងសង់ទ្រុងខ្ពស់។

ជាទូទៅ ការសាងសង់ទ្រុងជ្រូកមានពីរប្រភេទ:

- សង់ទ្រុងជ្រូកជាមួយនឹងកំរាលរាបស្មើ (ជាញឹកញាប់ ត្រូវបានគេប្រើសំរាប់ជ្រូកសាច់នៅក្នុងកសិដ្ឋានធំ១) ។

- ទ្រុងជ្រូកដែលមានកំរាលជាបន្ទះឈើ រឺដែកតូច១ (សមស្របគ្រប់ប្រពន្ធ័នៃការចិញ្ចឹមជ្រូកជាពិសេសសំរាប់កសិដ្ឋានតូច១) ។




***ប្រពន្ធ័ផ្ទៃកំរាល***

ចន្លោះរវាងបន្ទះមួយទៅបន្ទះមួយទៀតគួរមានពី ០.៥-១ ស.ម។ កំរាលជាបន្ទះឈើ រឺដែកតូច១គួរតែរាងជ្រាល រឺទេរដើម្បីងាយស្រួលលាងសំអាត។

***ការបែងចែកជាទ្រុងតូច១***

ការបែងចែកជាទ្រុងតូចៗជាច្រើនអាចត្រូវបានគេប្រើដូចជា ឈើ អិដ្ឋ ដែកបំពង់ទីប ។ល ។ ការបែងចែកជាទ្រុងតូចៗគួរតែការពារកូនជ្រូកកុំឱ្យចេញបាន ហើយនៅតែងាយស្រួលយកលាមកចេញបាន ។

***ការបែងចែកជាទ្រុងតូចៗខុសៗគ្នា***



***ទ្រុងធ្វើពីឈើមូលវែងៗ***



***ទ្រុងធ្វើពីបន្ទះឈើតូចៗ***



***ទ្រុងធ្វើពីជញ្ជាំងអិដ្ឋ***

ការបែងចែកជាទ្រុងតូចៗត្រូវតែមានឈើវែងរឹងមាំមិនស្រុតដែលអាចបោះជាយុថ្កាទៅក្នុងដី ។ មានបណ្តាញ ធ្នឹមផ្តេក និងបញ្ឈរ រឺ ក៏បន្ទះឈើតូចៗវាយភ្ជាប់ជាមួយនឹងឈើវែងៗទាំងនេះទៅវិញទៅមក ។ យើងមិនគួរសង់ធ្នឹមផ្តេកឱ្យខ្ពស់ពេកទេ ជ្រូកធំអាចឡើងចេញតាមធ្នឹមបាន ។ ការធ្វើបែបនេះជាពិសេសឱ្យបានរឹងមាំសំរាប់ជ្រូកបា វានឹងព្យាយាមចេញដើម្បីទៅរកមេដែលរកឈ្មោល ។



ចូរអ្នកដាក់ជ្រូកបាក្នុងទ្រុងមួយឱ្យដាច់តែឯងជិតទ្រុងជ្រូកមេដើម្បីជួយជំរុញជ្រូកមេឱ្យឆាប់រកឈ្មោល ។



***ទំហំស្នូកចំណី***

| ប្រភេទជ្រូក | បណ្តោយ | ទទឹង |
|---|---|---|
| កូនជ្រូកនៅបៅដោះ | ១៥-២០ ស.មសំរាប់ជ្រូក១ក្បាល | ២០ ស.ម |
| ជ្រូកសាច់ | ៣០-៣៥ ស.មសំរាប់ជ្រូក១ក្បាល | ២០ ស.ម |
| ជ្រូកមេធើម | ៤០-៥០ ស.មសំរាប់ជ្រូក១ក្បាល | ៣៥-៤០ ស.ម |
| ជ្រូកមេបំបៅដោះ | ៤០-៥០ ស.មសំរាប់ជ្រូក១ក្បាល | ៣៥-៤០ ស.ម |
| ជ្រូកបាពូជ | ៤០-៥០ ស.មសំរាប់ជ្រូក១ក្បាល | ៣៥-៤០ ស.ម |

ស្នូកចំណីត្រូវដាក់ឱ្យនៅនឹងទៅនឹងកំរាលដើម្បីការពារការក្រឡាប់ និងខាតបង់ចំណី ។







***ស្នូកទឹក :***

ស្នូកចំណីអាចត្រូវបានគេប្រើសំរាប់ផ្តល់ទឹកឱ្យជ្រូកផឹកក៏បានដែរ ។ នៅក្នុងកសិដ្ឋានធំៗទឹកផឹកត្រូវបានគេដាក់ឱ្យជ្រូកផឹក ដោយស្វ័យប្រវត្ត ( ធុងមូល រឺក្បាលបឺត) ។



## ២.៣ៈ ទ្រុង កំរាល និងតំរូវការទីធ្លា

### *ទ្រុងជ្រូកដែលមានផ្ទៃរាប កំរាលរឹងមាំ :*

ផ្ទៃរាបស្មើ កំរាលរឹងមាំជាទូទៅគេធ្វើពីស៊ីម៉ង់ (ប៉ុន្តែមិនមែនរលោងទេជៀសវាងការរអិលដួល) រឺពីដីរឹង។ កំរាលគួរតែធ្វើឱ្យទេរបន្តិចទៅផ្នែកខាងក្រោយងាយស្រួលសំអាតជាមួយនឹងទឹក។ វាសមរម្យជាពិសេសសំរាប់ជ្រូកសាច់ ប៉ុន្តែគេអាចអនុវត្តផងដែរលើជ្រូកមេធើម ជ្រូកមេកើតកូន និងជ្រូកបា។




### *ទ្រុងជ្រូកដែលចិញ្ចឹមដោយកំរាលបន្ទះឈើ រឺដែកតូចៗ:*

កំរាលទ្រុងជាធម្មតាត្រូវបានគេធ្វើពីឈើ រឺដើមឈើដែលគេអាចរកបាននៅក្នុងស្រុក។ កសិដ្ឋានចិញ្ចឹមជ្រូកខ្នាតធំ អាចមានកំរាលបន្ទះតូចៗដែលគេអាចរកបានដោយទិញ (ធ្វើពីស៊ីម៉ង់ ដែកកំណាត់ ប្លាស្ទិច ។ល។ ទ្រុងជ្រូកដែលមានកំរាលបន្ទះតូចៗគឺសមស្របសំរាប់ថែរក្សាជ្រូកគ្រប់ប្រភេទទាំងអស់។




### *តំរូវការទីធ្លាសំរាប់ជ្រូក:*

***ជ្រូកសាច់ :***

សំរាប់ជ្រូក ០.៥-១.ម$^{២}$






***ជ្រូកមេផើម :***

សំរាប់មេជ្រូក ១.៥-២ម$^{២}$




ជ្រូកមេផើមត្រូវការកន្លែងស្ងៀមស្ងាត់ ។ ដូច្នេះទ្រុងដាក់ដាច់ដោយឡែកពីគ្នា ពេលខ្លះត្រូវបានគេប្រើសំរាប់ជ្រូកមេ ។ ពេលអាកាសធាតុក្តៅ ជ្រូកមេផើមត្រូវបានគេដាក់ក្នុងទ្រុងឆ្លាស់គ្នាក្នុងក្រុមតូចចំនួនបីក្បាល ។



***ជ្រូកមេបំបៅដោះ :***



សំរាប់ជ្រូកមេមួយក្បាល ៤-៦ $ម^២$

***កូនជ្រូកផ្តាច់ដោះ :***

សំរាប់កូនជ្រូកមួយក្បាល ០.៣-០.៥ $ម^២$



***ជ្រូកបាពូជ :***

សំរាប់កូនជ្រូកមួយក្បាល ០.៣-០.៥ $ម^២$

ការថែទាំដោយយកចិត្តទុកដាក់គឺត្រូវការយកចិត្តទុកដាក់ការពារជ្រូកបាកុំឱ្យចេញពីទ្រុងទៅរកជ្រូកមេក្រមុំ និងមេជ្រូកដែលរកឈ្មោល (ការបែងចែកទ្រុងជាតូចៗរឹងមាំ និងខ្ពស់) ។



## ២.៤: ប្រពន្ធ័នៃការប្រក់ជំបូលខុសៗគ្នា

***ដំបូល :***

ដំបូលទ្រុងជ្រូកអាចជាស្បូវ ស្លឹកឬស្សី សង្ក័សី ក្បឿង ។ល។ ដំបូលដែលប្រក់ស្បូវ រឺស្លឹកឬស្សី គឺមានតំលៃថោក និងត្រជាក់ល្អ ប៉ុន្តែដំបូលទាំងនេះគឺមិននៅឋិតថេរ ។ ដំបូលក្បឿង រឺ ដំបូលសន្លឹកសង្ក័សី គឺមានតំលៃខ្ពស់ ប៉ុន្តែវាមិនងាយខូច ។ នៅរដូវក្តៅ ដំបូលសង្ក័សីធ្វើឱ្យទ្រុងជ្រូកកាន់តែក្តៅនៅពេលថ្ងៃត្រង់ ។





***ទ្រុងល្អ កំដៅគ្រប់គ្រាន់*** ***ទ្រុងមិនល្អម្លប់មិនគ្រប់គ្រាន់***

ទីតាំងទ្រុង និងដំបូលគួរតែសង់អាចការពារជ្រូកពីកំដៅព្រះអាទិត្យ និងភ្លៀង ។ ដំបូលគួរតែសង់ឱ្យមានម្លប់គ្រប់គ្រាន់ពេលដែលមានកំដៅខ្លាំងនៅពេលថ្ងៃត្រង់ ។

មានប្រពន្ធ័សាងសង់ដំបូល សាមញ្ញ ៤ :

- ដំបូលទេរតែមួយ
- ដំបូលទេរមិនស្មើគ្នា
- ដំបូលទេរ ខ្ពស់ស្មើគ្នា
- ដំបូលមានខ្យល់ចេញចូលពីរច្រក

***ដំបូលទេរតែមួយ***



ដំបូលបែបនេះ មានតំលៃថោក ហើយងាយស្រួលសាងសង់។ ដំបូលនេះធ្វើឱ្យមានខ្យល់ចេញចូលបានល្អ ប៉ុន្តែ ទ្រុងនេះកំដៅព្រះអាទិត្យចូលច្រើនពេក ហើយធ្វើឱ្យទ្រុងកាន់តែក្តៅ។ នៅរដូវភ្លៀង នៅពេលមានខ្យល់ និងភ្លៀង ខ្លាំង អាចចូលក្នុងទ្រុងបែបនេះបាន។

***ដំបូលទេរមិនស្មើគ្នា***

ដំបូលប្រភេទនេះ គឺមានកំពស់ខ្ពស់ជាងទ្រុងមានដំបូលតែមួយ។ សារៈប្រយោជន៍របស់ទ្រុងនេះ គឺអាចការពារភ្លៀង និងកំដៅព្រះអាទិត្យបានល្អជាង។

***ដំបូលទេរខ្ពស់ស្មើគ្នា***



ការសាងសង់ដំបូលបែបនេះមានតំលៃខ្ពស់ជាងទ្រុង ២ប្រភេទខាងលើ ប៉ុន្តែវាមានលទ្ធភាពការពារកំដៅព្រះអាទិត្យ និងភ្លៀងបានល្អជាង។

***ដំបូលមានខ្យល់ចេញចូលពីរច្រក***



ដំបូលប្រភេទនេះ ការពារកំដៅព្រះអាទិត្យ និងភ្លៀងបានល្អ ហើយវាមានខ្យល់ចេញចូលបានល្អ។ ការដាក់ទុនមានតំលៃ ខ្ពស់បន្តិច ប៉ុន្តែជាទូទៅវាចាំបាច់ណាស់នៅខែក្តៅ ដើម្បីរក្សា សីតុណ្ហភាពនៅក្នុងទ្រុង ឱ្យនៅក្នុងកំរិតមួយសមស្រប។

# ជំពូក ៣: ប្រពន្ធ័នៃការផ្តល់ចំណី

## ៣.១ ការផ្តល់ចំណីសត្វតាមបែបបុរាណ:

ការផ្តល់ចំណីគួរតំរូវទៅតាមសេចក្តីត្រូវការរបស់សត្វសំរាប់ការថែទាំ ការលូតលាស់ និងការបន្តពូជ ។ ចំណីជ្រូកដែលល្អមានថាមពល ប្រូតេអ៊ីន សារធាតុរ៉ែ និងវីតាមីនគ្រប់គ្រាន់ ។ កន្ទក់ ចុងអង្ករ ពោតក្រហម សណ្តែកសៀង ដំឡូងឈើ បន្លែ និងកាកសំណល់បាយស្រា ជាទូទៅត្រូវបានគេយកធ្វើជាចំណីជ្រូក ។

***ពោតក្រហម:***

ពោតក្រហមគឺជាប្រភេទចំណីសត្វយ៉ាងល្អ ។ វាមានផ្ទុកកាបូអ៊ីដ្រាត (ខ្ពស់)៦៥ភាគរយឡើង និងមានប្រូតេអ៊ីន ៩ភាគរយ ។ វាអាចលាយ និងចំអិនជាមួយប្រភេទចំណីផ្សេងទៀត ប៉ុន្តែមិនអាចលាយច្រើនជាង ៤០ភាគរយបានទេ ។



***សណ្តែកសៀង:***

សណ្តែកសៀងគឺជាដំណាំមួយប្រភេទ ដែលមានគុណតំលៃខ្ពស់ និងជាប្រភេទចំណីល្អណាស់សំរាប់ជ្រូក ។ វាមានប្រូតេអ៊ីន ៣៨ភាគរយ (ខ្ពស់ណាស់) ។ គួរហាលវាឱ្យស្ងួតសិន រឺចំអិនឱ្យឆ្អិនល្អ ដោយផ្សំជាមួយចំណីផ្សេងទៀត ដូចជាកន្ទក់ ចុងអង្ករ និងពោតក្រហម ។



***ដំឡូងមី:***

ដំឡូងឈើជាប្រភេទដំណាំមើមដែលគេប្រើសំរាប់ជាចំណីជ្រូក ។ វាអាចផ្សំជាមួយចំណីដទៃទៀត ពី ១០-២០ ភាគរយ (មិនដែលមានលើសពី ៣០ភាគរយទេ) ។ ដំបូងត្រូវចិតសំបកចេញ លាងសំអាត រួចហើយហាន់ជាចំណិត ហាលឱ្យស្ងួត បន្ទាប់មកកិនវាឱ្យម៉ត់មុនពេលប្រើ ។ មិនត្រូវឱ្យជ្រូកស៊ីដំឡូងស្រស់ទាំងសំបកទេ ពីព្រោះមានសារធាតុពុល ។ ដំឡូងឈើដែលបានចិតជាចំណិត និងហាលបានស្ងួតអាចទុកបានរយៈពេលយូរ ។



ស្លឹកកន្ទំថេត អាកាស្យា និងស្លឹកដើមឈើផ្សេងទៀត:

កន្ទុំថេត និងអាកាស្យាគឺជារុក្ខជាតិបែបប្រពៃណី នៅក្នុងស្រុក និងអាចរកបាន ។ ស្លឹករបស់វាមានប្រូតេអ៊ីនខ្ពស់ ។ ក្រោយពេលស្ងួត គេអាចលាយវាជាមួយចំណីផ្សេងទៀត ។







***ស្លឹកសណ្តែកគួរ***

***ស្លឹកកន្ទុំថេត*** ***ស្លឹកដំឡូងឈើ***

***បន្លែ :***

បន្លែត្រូវបានគេប្រើជាចំណីបន្ថែមសំរាប់ជ្រូកតាមរយៈការចំអិន និងលាយជាមួយចំណីផ្សេងទៀត ដូចជាកន្ទក់ ចុងអង្ករ និងពោតក្រហម ។ គេអាចផ្តល់ឱ្យស៊ីស្រស់ក៏បាន ។ បន្លែដែលសមស្របដូចជា:

- ស្ពៃក្តោប សាឡាត់
- ព្រលិត ដំឡូងជ្វា
- ត្រាវព្រៃ (ត្រូវការចំអិន)
- ចក




***កាកដូងស្ងួត:***

កាកដូងស្ងួតត្រូវបានគេផ្តល់ឱ្យជ្រូកស៊ីផងដែរ ។ វាមានជាតិខ្លាញ់ ៦០-៧០ភាគរយ និងមានផ្ទុកប្រូតេអ៊ីន ២០ភាគរយ ។ គេអាចផ្សំវា ប្រហែល ១០គ.កក្នុងចំណី ១០០គ.ក (១០ភាគរយ) ។




***កន្ទក់:***



កន្ទក់គឺសមស្របណាស់សំរាប់ផ្តល់ជាចំណីជ្រូក ។ វាមានប្រូតេអ៊ីន ១១ភាគរយ ហើយគេអាចប្រើជាសារធាតុ ផ្សំយ៉ាងសំខាន់ ។ កន្ទក់គេអាចផ្សំពី ៣០-៤៥ភាគរយជាមួយចំណីផ្សេងទៀត ។ កន្ទក់គេមិនអាចទុកវាបាន ១ខែទេ ពីព្រោះ វាអាចដុះផ្សិត ។

***កន្ទក់***

***ចុងអង្ករ:***

ចុងអង្ករក៏សមរម្យណាស់ដែរសំរាប់ប្រើជាចំណីជ្រូក ។ វាអាចលាយជាមួយចំណីផ្សេងទៀតពី ១៥-២០ ភាគរយ ។ វាមានប្រូតេអ៊ីនប្រហែល ៨ភាគរយ ។

***បាយស្រា (កាកសំណល់បិតស្រា):***

***ចុងអង្ករ***

ស្រាផលិតក្នុងស្រុកគេអាចផលិតចេញពី អង្ករ ពោតក្រហម ដំឡូងជ្វា ដំឡូងឈើ ចេក ។ល ។ ចំណីដែលគេនិយមផ្តល់ឱ្យជ្រូកស៊ីភាគច្រើនគឺ បាយស្រាផលិតចេញពីអង្ករ ។ គេគួរផ្សំវាជាមួយចំណីផ្សេងទៀត ដូចជា កន្ទក់ និង ចុងអង្ករ ។



បាយស្រាគេអាចផ្តល់ជាចំណីសំរាប់ជ្រូកសាច់ ប៉ុន្តែមិនមែនសំរាប់មេផើម និងមេបំបៅដោះទេ ។ មេជ្រូក ទាំងនេះត្រូវការចំណីដែលមានគុណភាព ដូច្នេះបាយស្រាមិនទាន់មានគុណភាពត្រូវជំនួសដោយចំណីផ្សេងដែល មានគុណភាព ដូចជាចំណីបាវ(ចំណីឧស្សាហកម្ម) ។ ខាងក្រោមជាអាហារផ្សំវិភាគត្រូវបានគេប្រើជាទូទៅក្នុងការផ្សំជាមួយបាយស្រា:

- កន្ទក់ (២គ.ក)
- ចុងអង្ករ (១គ.ក)
- បាយស្រា (៥-១០លីត្រ)

***ផលិតផលនៅក្នុងព្រៃ***

ចំណីជ្រូកគេអាចផ្សំជាមួយផលិតផលដែលមាននៅក្នុងព្រៃ (បន្លែព្រៃ ចេកព្រៃ ត្រាវព្រៃ ។ល។) ជាមួយគ្នានេះដែរ កាកសំណល់ផ្ទះបាយគេអាចប្រើជាចំណីផងដែរ (បបរ បាយ មី ជាដើម) ។ ខាងក្រោមនេះជាឧទាហរណ៍មួយនៃការផ្សំចំណីបន្ថែមនៅក្នុងស្រុកពីផលិតផលនៅក្នុងព្រៃ ។




## ៣.២ ការផលិតចំណីតាមបែបបុរាណៈ

ចំណីផ្សេងគ្នាត្រូវបានគេផ្សំ និងចំអិនដើម្បីឱ្យចំណីកាន់តែមានរសជាតិ។ មានរបៀបធ្វើចំណីបែប បុរាណ ២ប្រភេទ:

១. ផ្សំចំណីផ្សេងទាំងអស់បញ្ចូលគ្នា (កន្ទក់ ចុងអង្ករ ពោតកិន សណ្តែកសៀង ដំឡូងឈើស្ងួត រីម្សៅដំឡូង ស្លឹកអាកាស្យាស្ងួត ។ល។) តាមសមាមាត្រ និងដាក់ឱ្យជ្រូកស៊ីដោយផ្ទាល់។

២. ចំអិនវត្ថុធាតុដើមផ្សេងៗទាំងអស់បញ្ចូលគ្នាដើម្បីងាយស្រួលក្នុងការរំលាយអាហារ និងកំចាត់ជាតិពុល ចេញពីចំណីដូចជា ដំឡូងមី ត្រាវព្រៃ ដើមចេក គ្រាប់ពោត និងសណ្តែក និងកាកសំណល់ផ្ទះ បាយ ជាដើម។




ការផ្សំការប្រើប្រាស់នៅក្នុងស្រុក

| សារធាតុផ្សំ | ការវិភាគការផ្សំចំណី | | |
|---|---|---|---|
| | ទំងន់ជ្រូកពី ១៥-៣០គ.ក | ទំងន់ជ្រូកពី ៣០-៦០គ.ក | ទំងន់ជ្រូកពី៦០គ.កឡើង |
| សណ្តែកសៀង | ២៥ | ២០ | ១៥ |
| កន្ទក់ | ២៥ | ៣០ | ៣៥ |
| ពោតក្រហម | ២០ | ២៥ | ៣០ |
| ចុងអង្ករ | ៥ | ៥ | ៥ |
| ដំឡូងមី | ២០ | ១៥ | ១០ |
| ស្លឹកអាកាស្យា | ៥ | ៥ | ៥ |

| | | | |
|---|---|---|---|
| សរុប | ១០០ | ១០០ | ១០០ |
| ប្រូតេអ៊ីន | ១៦ | ១៥ | ១៤ |

## ៣.៣ ការផលិតចំណីបែបឧស្សាហកម្ម:

***ចំណីសំរេច:***

ចំណីសំរេចត្រូវបានផលិតនៅក្នុងរោងចក្រដោយយោងទៅតាម រូបមន្តចំណីជាក់លាក់ ហើយសមស្របទៅតាមប្រភេទជ្រូក។ មានប្រភេទចំណីសំរេចជាច្រើនដូចជា: ចំណីកូនជ្រូកបំបៅដោះ កូនជ្រូកផ្តាច់ដោះ ជ្រូកសាច់ មេកើតកូន មេដើម មេបំបៅដោះ ជ្រូកបា ។ល។ ចំណីសំរេចអាចផ្តល់ឱ្យជ្រូកស៊ីដោយផ្ទាល់។



*ចំណីសំរាប់កូនជ្រូក ចំណីសំរាប់ជ្រូកសាច់ ចំណីសំរាប់មេបំបៅដោះ*

***ចំណីស្ងួត(ចំណីគ្រាប់):***

ចំណីស្ងួតត្រូវបានផលិតដោយរោងចក្រដែលមានកំរិតប្រូតេអ៊ីនខ្ពស់។ អ្នកចិញ្ចឹមត្រូវតែផ្សំជាមួយ ចំណីដទៃទៀត មុនពេលឱ្យជ្រូកស៊ី ដូចជា : កន្ទក់ ចុងអង្ករ ពោតក្រហមជាដើម ដើម្បីឱ្យបានល្អសមស្របទៅនឹងរបប អាហារផលិតខ្លួនឯងនៅផ្ទះ ។



## ៣.៤ ការលាយចំណីតាមបែបឧស្សាហកម្មលាយជាមួយចំណីតាមបែបទំលាប់ :

បញ្ហាសំខាន់មួយដើម្បីកែលំអរផលិតកម្មជ្រូកនៅតំបន់ជនបទ គឺការកែលំអរប្រព័ន្ធនៃការផ្តល់ចំណី ដែលផលិតផលនោះគេអាចរកបាននៅក្នុងតំបន់ ។ នៅតំបន់ជាច្រើន រឺក្រុមជនជាតិភាគតិច ជាធម្មតាមានប្រព័ន្ធនៃការផ្តល់ចំណីតាមទំលាប់របស់ពួកគេ ។ ប៉ុន្តែជាទូទៅប្រព័ន្ធនៃការផ្តល់ចំណីតាមទំលាប់ត្រូវការកែលំអរនៅក្នុងករណីដូចជា:

- ដាក់ ( នៅក្នុងស្រុក) ជ្រូកនៅក្នុងទ្រុង
- ថែរក្សាការបង្កាត់ពូជជ្រូក ( ទោះបីជាពូជជ្រូកនាំចូលក៏ដោយ)

***ការផ្សំចំណីជាមួយចំណីស្ងួត( ចំណីគ្រាប់) :***

ការលាយចំណីស្ងួតជាមួយនឹងចំណីដែលអាចរកបាននៅក្នុងតំបន់គួរតំរូវទៅតាមសេចក្តីត្រូវនៃការលូតលាស់របស់ជ្រូក ។

| វត្ថុធាតុដើមផ្សំ | ភាគរយផ្សំ | | |
|---|---|---|---|
| | ទំងន់ជ្រូក ១៥-៣០គ.ក | ទំងន់ជ្រូក ៣០-៦០គ.ក | ទំងន់ជ្រូក ៦០គ.កឡើង |
| កន្ទក់ | ៤០ | ៤០ | ៤០ |
| ពោតក្រហម | ៣០ | ៣៥ | ៤០ |
| ចំណីស្ងួត ( ចំណីគ្រាប់) | ៣០ | ២៥ | ២០ |
| សរុប | ១០០ | ១០០ | ១០០ |
| ប្រូតេអ៊ីន | ១៦-១៧ % | ១៥-១៦ % | ១៤-១៥ % |




ដើម្បីកែលំអរប្រព័ន្ធផលិតកម្មជ្រូកនៅតំបន់ជនបទ ការចិញ្ចឹមពូជនាំចូល និងការផ្សំចំណីបែបឧស្សាហកម្ម ( ចំណីបាវ) ជាមួយនឹងចំណីថោកដែលអាចរកបាននៅក្នុងតំបន់ ( ដូចជា កន្ទក់ ពោតក្រហម និងសណ្តែក) ដែលគេចូលចិត្តប្រើ ។ ជ្រូកមេបំបៅដោះ កូនជ្រូក និងកូនជ្រូកផ្តាច់ដោះគួរតែផ្តល់ចំណីដែលផលិតនៅផ្ទះខ្លះ និងមានចំណីបែបឧស្សាហកម្មខ្លះ

***ការថ្លឹងចំនួនចំណីត្រឹមត្រូវ ( ទំងន់ រឺចំណុះ) :***



***១កំប៉ុងទំងន់ ០.៥ គ.ក***

***៤កំប៉ុងទំងន់ ២គ.ក***

ចំណីឧស្សាហកម្មមានតំលៃខ្ពស់ ហើយប្រើមានប្រសិទ្ធិភាព។ ជាមួយនេះផងដែរ នៅពេលយើងផលិត ចំណីខ្លួនឯងដូចខាងលើ យើងត្រូវលាយសារធាតុខុសៗគ្នាដោយត្រឹមត្រូវ (ទំងន់ និងចំណុះត្រឹមត្រូវ)។ អ្នកចិញ្ចឹមត្រូវការកំប៉ុង រឺធុងតាមក្រិតខ្នាត (កំប៉ុង ដបប្លាស្ទិច ជាដើម)ដែលគេប្រើសំរាប់ដាក់ចំណីឱ្យជ្រូកដើម្បីឱ្យដឹងពីទំងន់ប៉ុន្មានគីឡូក្រាមដែលគេផ្តល់ឱ្យជ្រូកស៊ី។

គួរផ្លាស់ប្តូរបាយស្រាដោយដាក់ចំណីបែបឧស្សាហកម្មវិញសំរាប់ជ្រូកមេ កូនជ្រូក និងកូនជ្រូកផ្តាច់ដោះ។






បាយស្រាត្រូវបានគេឱ្យតំលៃយ៉ាងខ្លាំងក្នុងការចិញ្ចឹមជ្រូកតាមទំលាប់របស់ប្រទេសឡាវ ជាពិសេសសំរាប់ជ្រូកសាច់។ ទោះបីជាយ៉ាងណាក៏ដោយ បើអាចធ្វើបាន មិនគួរផ្តល់ចំណីដែលមានគុណតំលៃខ្ពស់នេះដល់មេដើម មេបំបៅដោះ កូនជ្រូក និងកូនជ្រូកផ្តាច់ដោះទេ ពីព្រោះជាតិអាល់កុលមានផ្ទុកអាចនាំឱ្យខូចខាត។ ជ្រូកប្រភេទនេះត្រូវការចំណីដែលមានគុណភាពខ្ពស់ ហេតុដូចនេះបាយស្រាត្រូវការផ្លាស់ប្តូរដោយចំណីផ្សេងដែលមានគុណភាពខ្ពស់ដូចចំណីបែបឧស្សាហកម្ម (ចំណីបាវ)។

***ការស្តុកទុកចំណី៖***



វត្ថុធាតុដើមខ្លះ ដូចជាដំឡូងមី ពោតក្រហម

សណ្តែកសៀងត្រូវការហាលឱ្យបានស្ងួត

ល្អមុនពេលយកស្តុកក្នុង ជង្រុក រឺឃ្លាំង ។

ចំណីសំរេច និងចំណីដែលផ្សំរួចត្រូវបានគេ

រក្សាទុកផងដែរនៅកន្លែងស្ងួតដើម្បីចៀស

វាងការដុះផ្សិត ។ ចំណីដែលមានដុះផ្សិតជាការ

មិនល្អទេសំរាប់សត្វ ។ ការស្តុកត្រូវការការពារឱ្យបានល្អដើម្បីទប់ទល់នឹងកណ្តុរ ។

## ៣.៥ ការគ្រប់គ្រងចំណីទូទៅ :

ចំណីត្រូវការផ្លាស់ប្តូរជារៀងរាល់អាទិត្យសំរាប់កូនជ្រូកបំប៉ន និងជារៀងរាល់ខែសំរាប់ជ្រូកសាច់ ។ គុណភាពរបស់ចំណីត្រូវមានជីវជាតិគ្រប់គ្រាន់ ជាពិសេសគឺរិតប្រូតេអ៊ីនទៅតាមដំណាក់កាលលូតលាស់របស់ជ្រូក ។



*កូនជ្រូក: ប្រូតេអ៊ីន១៨-២០ ٪   ជ្រូកសាច់: ប្រូតេអ៊ីន១៦ ٪   មេជ្រូក: ប្រូតេអ៊ីន១៥٪*

អត្រានៃការលូតលាស់អាស្រ័យទៅលើបរិមាណនៃការស៊ី និងគុណភាពចំណីរបស់ជ្រូក ។ ជារៀងរាល់ថ្ងៃជ្រូកនិមួយៗត្រូវទទួលបរិមាណដែលមានគុណភាពបានគ្រប់គ្រាន់ ។ ចំណីសល់ រឺកខ្វក់នឹងកាត់បន្ថយការស្រេកឃ្លានរបស់ពួកវា ។



ការស្រេកឃ្លានរបស់ជ្រូកគឺមានសារៈសំខាន់ ។



ជ្រូកនឹងស៊ីចំណីមានស្រស់ស្អាតបានច្រើនជាងចំណីកខ្វក់
 រឺចំណី ដុះផ្សិត ។ ចំណីដែលល្អស៊ីអស់ពិស្នូកជារៀងរាល់ថ្ងៃ ។

ទីធ្លាស្នូកចំណីសមរម្យគឺជាការចាំបាច់ ដូចនេះ ជ្រូកនិមួយៗអាចស៊ីនូវអ្វីដែលពួកវាចង់ស៊ីជារៀងរាលថ្ងៃ ។

កសិដ្ឋានជាច្រើនចំណីនៅសល់មាន ១៥ ភាគរយ រឺច្រើនជាងនេះទៅទៀត ។ ចំណីសេសសល់ត្រូវតែចៀសវាង ឱ្យបានអតិបរិមាតាមដែលអាចធ្វើទៅបានៈ

- ជ្រូកត្រូវផ្តល់ចំណីឱ្យទៀងពេល ការធ្វើបែបនេះ ជ្រូកនឹងថ្នឹករបបអាហារបែបនេះ ។
- ជ្រូកត្រូវការផ្តល់ចំណីទៅតាមទំងន់ និងអាយុរបស់វា ។
- ស្នូកជ្រូកត្រូវធ្វើឱ្យបាននឹងល្អដើម្បីកុំឱ្យពួកវាអាចឈ្នួសដួលបាន ។



របបអាហារមានដូចខាងក្រោមៈ

- កូនជ្រូកផ្តាច់ដោះត្រូវផ្តល់ចំណី ៤ដងក្នុងមួយថ្ងៃ
- ជ្រូកសាច់ត្រូវផ្តល់ចំណីមួយថ្ងៃ ២ ដង



គ្រប់ជ្រូកទាំងអស់ត្រូវការទឹក





- ជ្រូកមេធើមមួយក្បាលត្រូវការទឹក: ១០-១២
 លីត្រក្នុង ១ថ្ងៃ

- ជ្រូកមេបំបៅដោះមួយក្បាល: ២០-៣០
លីត្រក្នុង ១ថ្ងៃ

- ជ្រូកសាច់មួយក្បាល: ៦-៨ លីត្រ ក្នុង ១ថ្ងៃ

- ជ្រូកបាមួយក្បាល: ១២-១៥ លីត្រក្នុង ១ថ្ងៃ

ការផ្តល់ទឹកមិនគ្រប់គ្រាន់អាចកាត់បន្ថយការស៊ី
ចំណីរបស់ជ្រូកប្រចាំថ្ងៃ។ ទឹកស្អាតគ្រប់គ្រាន់ត្រូវ
តែមាន គ្រប់ពេលនៅពេលដែលជ្រូកត្រូវការផឹក។

ផ្នែកខាងចុងនៃបំពង់នាំទឹកទៅក្បាលបឺតត្រូវពាស
ដោយសំណប៉ាហាំង ដូចទុយោប្លាស្ទិច រឺបំពង់ បេ វេ
 សេ នឹងត្រូវបានខាំដោយជ្រូកសាច់។

នៅពេលជ្រូកឡើងទំងន់ដល់ ២០-៦០គ.ក
ពួកវាត្រូវបានគេចាត់ទុកថាជាជ្រូកសាច់ និងរបបអាហារ
របស់វា ប្រើចំណីសំរេចមានដូចខាងក្រោម:

- ជ្រូកសាច់ត្រូវផ្តល់ចំណី ២ដងក្នុង ១ថ្ងៃ :ពេលព្រឹក និងល្ងាច
- ជ្រូកសាច់មានទំងន់ពី ២០-៤០ គ.កផ្តល់ចំណី ១.៥គ.ក- ២គ.កក្នុង ១ថ្ងៃ
- ជ្រូកសាច់ទំងន់ពី ៤០-៦០គ.ក ផ្តល់ចំណី ២ គ.ក-២.៥គ.កក្នុង ១ថ្ងៃ

ចំណីប្រើខាងលើនេះអាចយកទៅអនុវត្តបាន ជាពិសេសចំពោះកសិករដែលចិញ្ចឹមពូជនាំចូល ចំណីមាន
គុណភាព និង ការគ្រប់គ្រងបានល្អ។

បរិមាណចំណីដែលបានលើកឡើងពីមុនគឺមានមូលដ្ឋានផ្អែកលើចំណីបែបឧស្សាហកម្ម ។ អ្នកចិញ្ចឹមត្រូវមានក្រិតខ្នាតធុងដែលដាក់ចំណីដើម្បីឱ្យដឹងថាគាត់ផ្តល់ចំណីប៉ុន្មានគីឡូក្រាម ។ គាត់ត្រូវដឹងផងដែរ នូវទំងន់ប្រហាក់ប្រហែលនៃជ្រូករបស់គាត់ ។ ការប៉ាន់ប្រមាណទំងន់អាចរៀនបានពីអ្នកដទៃ (ដូចជា អ្នកទិញជ្រូក និងអ្នកកាប់ជ្រូក) រឺដោយការប្រើជញ្ជីង ។



នៅពេលដែលអ្នកចិញ្ចឹមប្រើវ៉ាស្សូអាហារថោកដែលផលិតដោយខ្លួនឯង វាគឺជាការលំបាកដឹង ប្រសិនបើអ្នកចិញ្ចឹមផ្តល់ចំណីឱ្យជ្រូករបស់គាត់មានថាមពល និងប្រូតេអ៊ីនសំរាប់ការថែទាំ និងការលូតលាស់ ។ ក្នុងករណីនេះ ដូចជា ក្បួនច្បាប់មួយនៃមេដៃ អ្នកចិញ្ចឹមត្រូវតែផ្តល់ចំណីឱ្យជ្រូករហូតដល់វាឈប់ស្រេកតទៀត ។ នៅពេលកសិករចិញ្ចឹមជ្រូកសាច់ គាត់គួរតែផ្តល់ចំណីបន្ថែម បើទោះបីជាតិចតួចក៏ដោយ (បន្ថែមមួយធុងទៀត) ។





*ការបន្ថែមចំណើ ១ធុងទៀត*

ត្រូវថែរក្សាជ្រូកដោយផ្តល់សមស្របដើម្បីទទួលបានផលិតផលល្អបំផុត ។ សីតណ្ហភាព និងសំណើមខ្ពស់កាត់បន្ថយការស៊ីចំណី និងការលូតលាស់ ។





ជ្រូកដែលឈឺអន់ចំណី ហើយនឹងមិនបាន
ទទួលចំណីគ្រប់គ្រាន់។





បញ្ហាសុខភាព និងជំងឺប៉ារ៉ាសិតអាចកាត់បន្ថយសមត្ថភាពនៃការលូតលាស់ពី ៥០ភាគរយឡើង និងបណ្ដាល
ឱ្យជ្រូកលូតលាស់មិនស្មើគ្នា។



យើងដឹងហើយថា ជ្រូកសាច់ដែលចិញ្ចឹម
ឆាប់ធំ អាស្រ័យទៅលើការលូតលាស់បាន
ល្អក្នុងកំឡុងពេលដែលវា នៅកូនជ្រូកអាយុ
៨អាទិត្យដំបូង។

ប្រសិនយើងមិនបានផ្ដល់ដល់កូនជ្រូកតូចៗ



បានគ្រប់គ្រាន់ នោះចំណីដែលល្អបំផុតលើ
ពិភពលោកគឺ គ្មាន ប្រយោជន៏ទេ។ អ្នកត្រូវ
តែជំរុះ (លក់) ជ្រូកដែលលូតលាស់យឺតទាំង
នេះចេញភ្លាមៗតាមដែលអាចធ្វើទៅបាន។



*ជ្រូកបា ជ្រូកគ្រៀវ ជ្រូកមេក្រមុំ*

នៅពេលជ្រូកសាច់បានទំងន់ ៥០គ.ក ចំណីរបស់ពួកវាត្រូវបំបែកគ្នាអាស្រ័យទៅតាមភេទ (យេនឌ័រ)។ ដូចនេះជាការល្អ ដាក់ជ្រូកមេក្រមុំក្នុងទ្រុង ហើយបំបែកជ្រូកគ្បៀវ និងជ្រូកបាឱ្យដាច់ពីគ្នា។



ចំណីមានគុណភាពល្អ ការគ្រប់គ្រងជំងឺមានប្រសិទ្ធិភាព និងបរិយាកាសជុំវិញស្អាត (ទ្រុងជ្រូក)នឹងធ្វើឱ្យការលូតលាស់របស់ជ្រូកប្រសើរឡើង។

## ជំពូក ៤: ការជ្រើសរើសពូជជ្រូក

## ៤.១ ការជ្រើសរើសជ្រូកបា និងជ្រូកមេក្រមុំ:

***ការជ្រើសរើសជ្រូកបា:*** *ការជ្រើសរើសជ្រូកបា*




ការជ្រើសរើសពូជជ្រូកបាបានល្អ គឺមានសារៈសំខាន់ណាស់ដើម្បីផ្តល់ជាប្រយោជន៍ដល់ផលិតកម្មជ្រូក ។ លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសមាន:

- ចៀសវាងការបង្កាត់ពូជតែមួយ: ចូរកុំជ្រើសរើសបាសំរាប់ជាមួយជ្រូកដែលមានខ្សែស្រឡាយគ្រួសារតែមួយ ។
- ជ្រើសរើសកូនជ្រូកចេញពីមេជ្រូកដែលមានកូនកើតមកមាំមួន និងកូនផ្តាច់ដោះបានច្រើន ។
- ជ្រើសរើសចេញពីមេដែលមានកូនច្រើន និងដោះមិនតិចជាង ១២
- ជ្រូកបាគួរតែលូតលាស់លឿន មានសុខភាពល្អ និងជើងរឹងមាំ
- ជ្រូកបាត្រូវតែមានប្រដាប់បន្តពូជល្អ ។

***ការជ្រើសរើសជ្រូកមេក្រមុំ:*** *ការជ្រើសរើសជ្រូកមេក្រមុំ*




ការជ្រើសរើសជ្រូកមេក្រមុំបានត្រឹមត្រូវ គឺមានសារប្រយោជន៍ដើម្បីទទួលបានកូនជ្រូកក្នុងសំបុកបានច្រើន ហើយកូនជ្រូកធំលូតលាស់លឿន ។ លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសមាន:

- ចៀសវាងការជាន់ឈាម: មេក្រមុំមិនត្រូវបង្កាត់ជាមួយឪពុករបស់វាទេ
- ជ្រើសរើសចេញពីមេដែលកើតកូន និងផ្តាច់ដោះបានច្រើន ( មិនតិចជាង ៩ក្បាល)

- មេក្រមុំគួរតែមានមាឌល្អ និងក្បាលដោះមិនតិចជាង ១២ (លក្ខណៈវិនិច្ឆ័យដូចម្តាយរបស់វា)
- មេក្រមុំត្រូវលូតលាស់ មានសុខភាពល្អ និងជើងរឹងមាំ

***សញ្ញានៃការជាន់ឈាមៈ***



ការកើតឡើងនូវក្លនលូន (ធ្លាក់ពោះវៀន) ខ្ពស់ អាចជាមួយសញ្ញាជាន់ឈាម ។ ចូរអ្នកពិចារណាក្នុង ការផ្លាស់ប្តូរបា និងមេ ហើយមិនត្រូវយកកូនក្នុងសំបុកដែលមានការកើតឡើង ធ្លាក់ពោះវៀនខ្ពស់សំរាប់បង្កាត់ពូជ ឡើយ ។ ប្រសិនបើការផ្លាស់ប្តូរទាំងនេះចេញមកពីភូមិផ្សេង នោះការកើតមាននៃទំនាក់ទំនងគឺមានតិចតួចណាស់ ។

### ៤.២ ជ្រូកមេដែលផ្តល់ផលច្រើនៈ

ផលិតភាពរបស់ជ្រូកមេ គឺត្រូវបានគេគិតចេញពីចំនួនកូនជ្រូកក្នុងមួយសំបុក និងចំនួនសំបុកដែលវាបានបង្កើតកូនក្នុងមួយឆ្នាំ ។ ផលិតភាពនៅក្នុងមួយជីវិតរបស់វា ជាចំនួនសរុបនៃកូនជ្រូកដែលវាបានផលិត ។



២ឆ្នាំនៃផលិតភាពមេជ្រូកៈ
ទិសដៅ គឺ ៤សំបុក



មេជ្រូកល្អ និងមេមិនល្អៈ
កូនកើតច្រើន និងកូននៅសល់តិច



ជ្រូកមេកើតកូន ២សំបុកក្នុងមួយឆ្នាំ

ជាមធ្យមដែលកូនជ្រូកបានផ្តាច់ដោះ
ច្រើនជាង ៨ក្បាលក្នុងមួយសំបុក ។

ដូចនេះវាមានសារៈសំខាន់នៅពេល
យើងដឹងពេលជ្រូកកើតកូន និងចរិត
លក្ខណៈនៃការថែទាំកូនរបស់ជ្រូកមេៈ
ភាពងាយស្រួលពេលកើតកូន សភាវ-
គតិរបស់ជ្រូកមេ ភាពប៉ិនប្រសប់
នៃការបំបៅដោះ ។ល ។



ជ្រូកមេដែលមិនមានសមត្ថភាពធ្វើ
ជាមេជ្រូកត្រូវជំរុះចោល ។កូនរបស់
មេជ្រូកនេះមិនត្រូវចិញ្ចឹមទុកធ្វើពូជទេ ។

យើងត្រូវការបង្កើតវិធីសាស្ត្រដែលមានប្រសិទ្ធិ
ភាពដើម្បីចិញ្ចឹមកូនជ្រូកលើសធម្មតាទាំងអស់
ដែល ជ្រូកមេថែទាំមិនបានល្អ ។ ពេលខ្លះយើង
អាចផ្ទេរកូនជ្រូកទាំងនោះទៅឱ្យមេជ្រូកដែល
មានកូន ២-៣ក្បាល (កើតកូនក្នុងពេលដូចគ្នា) ។



គុណភាព និងបរិមាណចំណីត្រូវតែមានតុល្យភាព ធ្វើបែបនេះដើម្បីកុំឱ្យមេជ្រូកធាត់ពេកនៅពេលផើម រឺស្គមពេកក្នុងកំឡុងពេលបំបៅដោះ ។ ស្ថានភាពទាំងពីរនេះអាចបណ្តាលឱ្យមានបញ្ហានៃការបន្តពូជ ។



## ៤.៣ ការផ្តល់ចំណី និងខ្សែស្រលាយនៃពូជ (សេនេទិច):




នៅក្នុងលក្ខខណ្ឌប្រទេសឡាវ វាមានសារៈសំខាន់ ដែលពូជជ្រូកក្នុងស្រុក និងពូជកែលំអ (ពូជកូនកាត់) អាចលូតលាស់អាស្រ័យដោយមានរបបអាហារតុល្យភាពល្អចេញពីធនធានចំណីដែលអាចរកបាន ក្នុងស្រុក ។ មេជ្រូកបំបៅ និងកូនជ្រូកត្រូវការផងដែរនូវចំណីបែបឧស្សាហកម្មខ្លះនៅក្នុងរបបអាហាររបស់ពួកវា ។



គេដឹងថា ជ្រូកពូជនាំចូលសំបុរស(ឡែនដ្រាស និងឡាកវ៉ាយ) លូតលាស់មិនល្អទេបើពឹងទៅលើរបបអាហារធម្មតាក្នុងស្រុក ។ ការលូតលាស់ឆាប់រហ័សអាចកើតមានឡើងតាមរយៈការផ្តល់ចំណីដល់ពួកវា(ចំណីមានតំលៃខ្ពស់)ចំណីឧស្សាហកម្ម ។

ពូជជ្រូកកូនកាត់មានការស្រេកឃ្លាន និងការប្រើប្រាស់ចំណី( ចំណី ១គ.កដើម្បីបានសាច់ជ្រូកមួយ គ.ក) ក៏ខុស១គ្នាដែរ ។ ពូជកូនកាតអាចលូតលាស់បានល្អ នៅពេលគេផ្តល់របបអាហារដែលមានគុណភាពល្អ ផលិតនៅផ្ទះ ។ នេះមានន័យថា ជាទូទៅគេផ្សំចំណីក្នុងស្រុកដែលអាចរកបានជាមួយចំណីឧស្សាហកម្ម ។



ការលូតលាស់លឿន កូននៅក្នុងសំបុកបានច្រើន និងគុណភាពសាច់ គឺជាលក្ខណៈចំបងក្នុងការជ្រើសរើសពូជសត្វ ។



ជ្រូកសាច់ត្រូវតែមានសក្តានុពលភាពលូតលាស់ឆាប់រហ័ស ហើយមានប្រសិទ្ធិភាព និងផលិតសាច់សុទ្ធដែលមានគុណភាពច្រើន ។ ខាងក្រោម គឺជាគំរោងការសំរាប់កសិដ្ឋានចិញ្ចឹមនៅក្នុងប្រទេសឡាវគំរោងភី ឌី អរ ដែលប្រើពូជនាំចូល និងចំណីមានគុណភាព( ចំណីឧស្សាហកម្ម) ។

ទំងន់ ៦០គ.ក ចិញ្ចឹមរយៈពេល ៣ខែដោយប្រើចំណីអស់ ១៨០គ.ក



ជាឧទាហរណ៍ ការគណនានៃការប្រើប្រាស់ចំណីដើម្បីបានសាច់ ១គ.ក : ចំណី ១៨០ គ.កត្រូវការដើម្បីលូតលាស់ទំងន់ជ្រូកពី ១៥-២០គ.គដើម្បីបានកើនទំងន់ ៧០-៨០គ.ក។ ការប្រើប្រាស់ចំណីដើម្បីបានសាច់ ១គ.ក : ចំណី ១៨០គ.ក កើនទំងន់បាន ៦០គ.ក = ចំណី ៣គ.កផលិតបានសាច់ ១គ.ក។ ដូច្នេះ អត្រាការប្រើប្រាស់ចំណី ៣គ.កបានសាច់ជ្រូក ១គ.ក ។





បច្ចេកទេសនៃការជ្រើសរើសពូជ និងការផ្តល់ចំណី អាចបញ្ជាក់ពីភាពដូចគ្នានៃសាច់ក្រហមបានយ៉ាង ដូចម៉េច? ។ នៅទីក្រុងទំនើប រឺអតិថិជនទាន់សម័យចូលចិត្តសាច់ជ្រូកដែលមិនមានខ្លាញ់។ នៅតំបន់ជនបទ ប្រជា-ពលរដ្ឋនៅតែចូលចិត្តជ្រូកតូច ជ្រូកសំបុរខ្មៅនៅក្នុងស្រុក។



ពូជនៅក្នុងស្រុក ៣៨-៤០ភាគរយនៃសាច់សុទ្ធ



ជ្រូកបាពូជឡាយរ៉ាយ ៤៥-៥០ភាគរយនៃសាច់សុទ្ធ



កម្មវិធីបង្កាត់ពូជដែលមានជំនាញបែបឧស្សាហកម្ម សាច់សុទ្ធលើសពី ៦០ភាគរយ ។



ពូជជ្រូកនាំចូលដែលមានទៅដោយសាច់សុទ្ធ



ពូជជ្រូកក្នុងស្រុកដែលមានទៅដោយខ្លាញ់ ។



## ជំពូក ៥: ការបង្កាត់ពូជ

### ៥.១ ការគ្រប់គ្រងមេជ្រូកក្រមុំ :

ជ្រូកមេក្រមុំ គឺជាជ្រូកមេក្មេងដែលត្រៀមខ្លួនដើម្បីបង្កាត់ពូជលើកដំបូង នៅអាយុប្រហែល ៨-៩ខែ។ នៅក្នុងពេលនេះគួរដាក់មេក្រមុំឱ្យនៅក្បែរជ្រូកបាដើម្បីឱ្យឆាប់រកឈ្មោល ប៉ុន្តែមិនត្រូវដាក់ជាមួយជ្រូកបា ទេ។ ជ្រូកមេក្រមុំគួរផ្តល់ចំណីដោយប្រុងប្រយត្ន័ចៀសវាងកុំឱ្យធាត់ រឺស្គមពេក។ ជាធម្មតា វាត្រូវបានគេផ្តល់ចំណី ប្រហែល ២-២.៥គ.ក ក្នុងមួយក្បាល។ បន្ថែមពីនេះទៅទៀត វាត្រូវបានគេផ្តល់បន្លែស្រស់ជាមួយចំណី។

វាមានសារៈប្រយោជន៏ដោយដាក់តាំងជ្រូកមេក្រមុំនាំមកថ្មីដើម្បីជំរុះមេជ្រូកចាស់ ហើយឱ្យជ្រូកមេក្រមុំចូល ក្នុងហ្វូង និងជំរុញជ្រូកមេក្រ-មុំថ្មីឆាប់រកឈ្មោល។ ចូរប្រុងប្រយត្ន័ការដាក់លាយគ្នាជាមួយជ្រូកថ្មីទើបទិញទាំងនេះជា មួយជ្រូកមេផ្សេងទៀតដើម្បីចៀសវាងការខាំគ្នា។



ចូរកត់ត្រាថ្ងៃរបស់ជ្រូកមេក្រមុំណាមួយដែលបង្ហាញពីសញ្ញាការរកឈ្មោលលើកដំបូង ប៉ុន្តែមិនទាន់បង្កាត់វា។



៣អាទិត្យក្រោយពេលដាក់ចូលទ្រុងជ្រូកមេក្រមុំថ្មីទើបនាំមក គួរតែដាក់វាឱ្យសាំទៅនឹងអាកាសធាតុល្អ ហើយនៅពេលណាមួយគួរផ្លាស់ប្តូរវាទៅដាក់ក្នុងទ្រុងរបស់វា។ ទ្រុងរបស់ជ្រូកមេក្រមុំទាំងនោះ គួរដាក់ក្បែរជ្រូកបា ដែលនឹងជំរុញឱ្យជ្រូកក្រមុំទាំងនេះឆាប់រកឈ្មោល។



ចូរឱ្យជ្រូកបាមួយដើរឆ្លាស់គ្នាម្តងមួយនៅមុខទ្រុងជ្រូកមេក្រមុំជារៀងរាល់ថ្ងៃ ដោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់យើង ។ យកចេញជ្រូកមេក្រមុំណាដែលរកឈ្មោល ហើយឱ្យបាពាក់ជ្រូកមេទាំងនោះនៅកន្លែងផ្សេងៗគ្នា ។



ប្រសិនបើអាចធ្វើទៅបាន ថែរក្សាជ្រូកមេនោះនៅក្នុងទ្រុងដើម្បីឱ្យវាធ្វើចលនាឱ្យបានយ៉ាងហោចណាស់ពាក់កណ្តាលនៃការពរពោះលើកដំបូងរបស់វា ពីព្រោះសារពាង្គកាយរបស់វានៅតែលូតលាស់នៅឡើយ ។



### ៥.២ការគ្រប់គ្រងមេជ្រូកផ្តាច់ដោះ :

នៅពេលមេជ្រូកបានផ្តាច់ដោះកូនជ្រូករបស់វាហើយ មេជ្រូកទាំងនោះគេហៅថា មេជ្រូកផ្តាច់ដោះត្រៀមរកឈ្មោល ។ បែបនេះមានន័យថា វាត្រៀមខ្លួនសំរាប់ការបង្កាត់ពេលបន្ទាប់ ។ ជាធម្មតា មេជ្រូកបែបនេះរកឈ្មោលប្រហែល ៧-១៥ថ្ងៃក្រោយពេលផ្តាច់ដោះ ។ មេជ្រូកដែលទើបតែផ្តាច់ដោះកូនរបស់វា គឺស្គមពីព្រោះវាថែទាំកូនទាំងនេះ ។ ជ្រូកមេទាំងនោះត្រូវការផ្តល់ចំណីមានគុណភាពដើម្បីឱ្យវាមានសុខភាពល្អ និងឆាប់រកឈ្មោល ។ ពួកវាត្រូវដាក់នៅ ជិតជ្រូកបា និងចំណីរបស់វាគួរផ្តល់ប្រហែល ២.៥-៣គ.កសំរាប់មួយក្បាលក្នុងមួយថ្ងៃ ។



## ៥.៣ ការបង្វឹកជ្រូកបាក្មេង ៖

នៅពេលដំបូងជ្រូកបាក្មេងអាចដាក់ចូលគ្នានៅក្នុងទ្រុងតែមួយ ប៉ុន្តែនៅពេលវាមានទំងន់ ៥០-៦០គ.ក ត្រូវបំបែកពួកវាចេញដាច់ពីគ្នាចៀសវាងការខាំគ្នា និងមួមៅដាក់គ្នា ។

ការបង្វឹកជ្រូកបាក្មេងគួរចាប់ផ្តើមនៅពេល ប្រដាប់បន្តពូជរបស់ពួកវាអាចពាក់មេបានអាយុប្រហែល ៨ខែ ។ កន្លែងដែលបំផុតសំរាប់ការបង្វឹកនេះគឺក្នុងទ្រុងជ្រូកបា ។ ជ្រូកមេពេញវ័យ ដែលរកឈ្មោលពេញបន្ទុក គួរតែឱ្យបាក្មេងឡើងពាក់ ។ ទុកពេលឱ្យពួកវាស្គាល់គ្នាទៅវិញទៅមក ។ មិនត្រូវឱ្យជ្រូកបាឡើងពាក់មេជ្រូកនៅមុខកន្លែងបង្វឹកទេ អាចធ្វើឱ្យវាមានទំលាប់អាក្រក់ជារៀងរហូត ។ នៅចាប់ផ្តើមដំបូង ជ្រូកបាក្មេងគួរតែជួយវាដូចជា ម្ចាស់បាជួយបញ្ចូលលឹង្គទៅក្នុងប្រដាប់បន្តពូជជ្រូកមេ ហើយទុកឱ្យវាពាក់ដោយជោគជ័យ ។ នៅកំឡុងពេលបង្កាត់មិនត្រូវឱ្យមានការជ្រៀតជ្រែកពីជ្រូកបាដទៃទេ ។

នៅក្នុងករណីដែលជ្រូកបាក្មេង ហើយបង្វឹកវាបានល្អ នៅពេលចាប់ផ្តើមពាក់មេ ពួកវានឹងបង្កើនទំលាប់ពាក់មេបានល្អ ។



*គំនិតបែបនេះត្រឹមត្រូវ*
*ប៉ុន្តែចុងបញ្ចប់ខុសទិសដៅ*

ក្នុងករណីជាច្រើន ចំណង់តាមធម្មជាតិ គឺគ្រប់គ្រាន់ដើម្បីធានាថា ជ្រូកបាក្មេងអាចចាប់ផ្តើមពាក់បានយ៉ាងល្អ ។



ជ្រូកបាបង្កាត់ពូជ គួរតែស្លូត និងងាយស្រួលចាប់ ។ប៉ះ

ថ្នមៗនៅពេលចាប់សត្វ កុំវាយ រឺក៏ធ្វើឱ្យវារបួស។ ជ្រូកបា នេះឆាប់មួមៅ និងពិបាកគ្រប់គ្រងហើយ មិនត្រូវទុកវាបង្កាត់ពូជទេ។





ចូរប្រាកដថាការពាក់មេជាលើកទី ១ ទទួលបានជោគជ័យដោយមានជ្រូកមេទំហំប្រហាក់ប្រហែលគ្នា ហើយ ដែលការរកឈ្មោលរបស់ជ្រូកមេនោះពេញបន្ទុក។

### **៥.៤ វដ្តនៃអ៊ីស្ត្រូសែន ការបង្កាត់តាមធម្មជាតិ សិប្បនិមិត្ត និងថ្ងៃកើតកូន**

មេជ្រូករកឈ្មោល ៧-១៥ថ្ងៃក្រោយពេលផ្តាច់ដោះ និងបន្ទាប់មករៀងរាល់ ២១ថ្ងៃរហូតដល់ពេលពួកវាផើម។ ការគ្រប់គ្រងបានល្អរបស់មេជ្រូកទើបផ្តាច់ដោះថ្មី គឺមានសារៈប្រយោជន៍ដើម្បីធានាថា មេជ្រូកទាំងអស់រកឈ្មោលពេញបន្ទុក។



រកឈ្មោល ៧-១៥ថ្ងៃក្រោយពេលផ្តាច់ដោះកូន      រកឈ្មោលរៀងរាល់ ២១ថ្ងៃរហូតដល់មានផ្ទៃពោះ

សញ្ញារកឈ្មោលមានដូចខាងក្រោមៈ



- យោនីឡើងប៉ោងក្រហម
- នៅមិនស្ងៀម (រំជើបរំជួយ) និងស្រែករោើ
- នោមញឹកញាប់
- អន់ចំណី
- ឡើងពាក់ជ្រូកដទៃ
- មានហូរទឹករំអិលតាមរន្ធយោនី

***មានពីរដំណាក់កាលសំរាប់អង្កេតមើលការរកឈ្មោលៈ***



១. តាមរយៈការអង្កេតសញ្ញានៃការដោយឈ្មោល (នៅមិនស្ងៀម និងពាក់ជ្រូកដទៃ) យោនី (ឡើងក្រហម ឡើងប៉ោងដោយមានហូរទឹករំអិល) និងប៉ះពាល់មេជ្រូក ។

សង្កត់លើខ្នងត្រូវបានគេយកមកប្រើ(រឺ ផ្នែកម្ខាងទៀតលើ ខ្នង)ដើម្បីកំណត់ពេលវេលាបង្កាត់ពូជបាន ត្រឹមត្រូវ ។ ក្នុងកំឡុងពេលបង្កាត់ពូជត្រឹមត្រូវ ជ្រូកមេមិនរត់ទៅណា ហើយ នេះគឺសំដៅពេល មេជ្រូកកំពុងរកឈ្មោល ។



២. តាមរយៈការនាំជ្រូកបាទៅជិតមេជ្រូក ជ្រូកមេនឹងបង្ហាញសញ្ញារកឈ្មោលយ៉ាងច្បាស់ ។ ប្រការនេះ គួរធ្វើ ដោយផ្ទាល់ក្រោយពេលដាក់ចំណី នៅពេលព្រឹក និងពេលល្ងាច ។

***មានការបង្កាត់ ២របៀប តាមធម្មជាតិ និងតាមសប្បនិម្មិត:***

១. ការបង្កាត់តាមធម្មជាតិ

នៅពេលជ្រូកមេក្រមុំអាយុបាន ៥-៦ខែ ពួកវាចាប់ផ្តើមរកឈ្មោលលើកទី១ ។អាយុក្មេងជាងនេះ ជ្រូកមេក្រមុំ គឺមិនសមស្របទេសំរាប់បង្កាត់ពូជ ពីព្រោះសរីរាង្គបន្តពូជរបស់ពួកវាមិនទាន់លូតលាស់បានល្អ ។ជ្រូកមេត្រូវតែបង្កាត់ពូជនៅពេលដែលវាមានអាយុ ៧-៨ខែ និង ចាប់រកឈ្មោលលើកទី ២ និងលើកទី ៣ ។ រយៈពេលជាមធ្យមនៃវដ្តអ៊ីស្ត្រូសែន គឺ ២១ថ្ងៃ ហើយវដ្តនេះកើតឡើងម្តងទៀតនៅពេលជ្រូកមេដាក់បាមិនបានជោគជ័យ ។



២. ការបង្កាត់បែបសិប្បនិម្មិតលើជ្រូក :

នៅពេលប្រើការបង្កាត់តាមបែបសិប្បនិម្មិត ជ្រូកបាមិនបង្កាត់ដោយផ្ទាល់ជាមួយជ្រូកមេទេ ។ ជាមួយនឹងការបង្កាត់តាមបែបសិប្បនិម្មិត ស្ពែមដែលបានពីជ្រូកបាត្រូវបានគេប្រមូលទុក រួចហើយដាក់បញ្ចូលតាមរយៈប្រដាប់បញ្ចូលស្ពែមទៅក្នុងស្បូនរបស់មេជ្រូក ។



*ការប្រមូលស្ពែម*



*ការបញ្ចូលស្ពែមទៅក្នុងស្បូន*

***អត្ថប្រយោជន៍របស់ការបង្កាត់តាមបែបសិប្បនិម្មិត:***

១. ស្ពែមអាចដឹកជញ្ជូនបានផ្លូវឆ្ងាយទៅដល់កសិដ្ឋានជាច្រើន

២. ការបង្កាត់តាមបែបសិប្បនិម្មិតជាវិធីមួយល្អ ប្រើបាពូជតែមួយសំរាប់ដាក់មេជាច្រើន( និងកាត់បន្ថយការចំណាយ)

៣. ការបង្កាត់បែបសិប្បនិម្មិតអាចទប់ស្កាត់ការរាតត្បាតនៃជំងឺ ដែលបង្កពីជ្រូកបា ធ្វើឱ្យមានការរីករាលដាល

***ការគិតសំរាប់ថ្ងៃកើតកូនះ***

រយៈពេលផើមរបស់ជ្រូកមេមាន ១១៤ថ្ងៃ រឺ ៣ខែ ៣អាទិត្យ ៣ថ្ងៃ ( ៣ខែ និង ២៤ថ្ងៃ)

ថ្ងៃកើតកូនអាចត្រូវបានគិតដូចក្រោមះ

| | | |
|---|---|---|
| ឧទាហរណ៏ ១ : | ថ្ងៃបង្កាត់ : | ០៦/០៨/២០០២ |
| | រយៈពេលផើម | ២៤/០៣ |
| | ថ្ងៃកើតកូន | ៣០/១១/២០០២ |
| ឧទាហរណ៏ ១ : | ថ្ងៃបង្កាត់ : | ១៤/០៨/២០០២ |
| | រយៈពេលផើម | ២៤/០៣ |
| | ថ្ងៃកើតកូន | ៣០/១១/២០០២=៨/១២/២០០២ |
| | | ( ថ្ងៃ : ៣៨-៣០=៨ ខែ: ១១ +១=១២) |

| ពេលវេលារំពឹងទុកនៃការរកឈ្មោល និងថ្ងៃកើតកូនរបស់មេជ្រូក | | | | | | | |
|---|---|---|---|---|---|---|---|
| ព័តិមានលំអិតនៃការដាក់ឈ្មោល | | ព័តិមានលំអិតរបស់ជ្រូកមេ និងជ្រូកបា | | ការបង្កាត់ដែលទទួលបានជោគជយ័ | | ការបង្កាត់ដែលមិនទទួលបានជោគជ័យ | |
| លេខរៀង | ថ្ងៃដាក់ឈ្មោល | ចំនួនជ្រូកបា | ចំនួនជ្រូកមេ | រយៈពេលផើមខែថ្ងៃ | រំពឹងថ្ងៃកើត | ចន្លោះពេលរកឈ្មោល | លទ្ធភាពរកឈ្មោលបន្ទាប់ទៀត |
| ១ | | | | ៣+២៤ថ្ងៃ | | ២១ថ្ងៃ | |
| ២ | | | | ៣+២៤ថ្ងៃ | | ២១ថ្ងៃ | |
| ៣ | | | | ៣+២៤ថ្ងៃ | | ២១ថ្ងៃ | |
| ៤ | | | | ៣+២៤ថ្ងៃ | | ២១ថ្ងៃ | |
| ៥ | | | | ៣+២៤ថ្ងៃ | | ២១ថ្ងៃ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៦ | | | | ៣+២៤ថ្ងៃ | | ២១ថ្ងៃ | |

## ៥.៥ ការកត់សំគាល់មេជ្រូករកឈ្មោលៈ

ការអង្កេតពេលរកឈ្មោលត្រូវបានគេធ្វើដោយផ្ទាល់ ក្រោយពេលដាក់ចំណី ។ ការបង្កាត់គួរធ្វើនៅពេលព្រលឹម និងពេលល្ងាច នៅពេលអាកាសធាតុត្រជាក់ល្មម និងមេជ្រូកបង្ហាញការឈ្មោលពេញបន្ទុក ។





ចូរត្រួតពិនិត្យមេជ្រូកដែលកំពុងរកឈ្មោលឱ្យបានទៀងទាត់ យ៉ាងហោចណាស់ ២ដងក្នុងមួយថ្ងៃ ពេលព្រលឹម និងពេលល្ងាច ។ ការរកឈ្មោលរបស់ជ្រូកមេមានរយៈពេលខ្លី ( ត្រឹមតែ១ថ្ងៃប៉ុណ្ណោះ) ដូចនេះ ជាការល្អ បង្កាត់ជ្រូកមេ នៅចន្លោះពេល ១២ម៉ោង ( ពេលព្រលឹម និងពេលល្ងាច) ។

ពេលព្រឹកៈ ការពិនិត្យការរកឈ្មោល បង្កាត់ជាលើកទី ២ ចំពោះជ្រូកមេដែលបាន ដាក់បាលើកទី ១នៅពេល ល្ងាច ។




ពេលល្ងាចៈ ការពិនិត្យការរកឈ្មោល បង្កាត់ជាលើកទី ២ ចំពោះជ្រូកមេដែលបាន ដាក់បាលើកទី ១នៅពេល ព្រឹក ។



### ២៥.៦_ការគ្រប់គ្រងការបង្កាត់



ការដាក់ឈ្មោលគឺជាព្រឹត្តិការណ៍សំខាន់មួយ ព្រោះថាជាការចាប់កំណើតមួយដែលប្រកបដោយជោគជ័យ ។

ដើម្បីការបង្កាត់ទទួលបានលទ្ធផលល្អ គឺត្រូវបង្រៀនបាពេញវ័យ និងផ្សាំងអោយបានល្អ ។ រៀងរាល់ថ្ងៃ មេក្រមុំ និងមេជ្រូកទើបផ្តាច់ដោះ គួរតែដាក់ពួកវាឱ្យជិតជាមួយជ្រូកបា ដើម្បីដាស់អារម្មណ៏វា ឱ្យឆាប់រកឈ្មោល ។



វាជាការប្រសើរបំផុត ដាក់ជ្រូកមេទើបផ្តាច់ដោះ ឱ្យមើលឃើញស្តាប់សំលេង និងធំក្លិនរបស់ជ្រូកបា គឺជ្រូកបាកាន់តែចាស់ក្លិនកាន់តែល្អ ហើយការរកឈ្មោលក៏បានលឿន ។



ជ្រូកមេដែលរកឈ្មោលគឺនៅមិនស្ងៀម ដើរទៅជិតជ្រូកបា បែរក្រោយ និងត្រចៀករបស់វាងើបឡើង ។



យោនីឡើងក្រហម លយចេញឃើញច្បាស់ រីកធំ និង មានសើម ។



ក្រោយពេលរកឃើញថាមេជ្រូករក ឈ្មោល មេជ្រូកត្រៀមខ្លួនជាស្រេចសំរាប់បង្កាត់ ។ ចូរទុកឱ្យមេជ្រូក និងបាជួបគ្នាទៅវិញទៅមក ដើម្បី បង្កាត់ ។



ការបង្កាត់ពូជតាមធម្មជាតិ

ជាយោបល់ការដាក់បាម្តងទៀត គួរដាក់ ឈ្មោលចន្លោះពេលពី ៨-១០ ម៉ោងក្រោយ ដាក់ លើកទី១ ។ការធ្វើបែបនេះ នឹងបង្កើនឱកាស សំរាប់ការ បង្កកំណើតឱ្យបានច្រើន ។



ការគ្រប់គ្រងការបង្កាត់ត្រូវធានាថា មាន ប្រសិទ្ធិភាព ជាអតិបរិមាដែលធ្វើឱ្យ មេជ្រូកដើម ។

អ្នកត្រូវប្រាកដប្រជាថា នៅកំរាលកន្លែង ដាក់បាមិនរអិល ដូច្នេះជ្រូកបា និងមេមាន ជំហរល្អ ។ ជាការណែនាំគួរដាក់ស្មៅស្ងួត ចំបើង រឺសំភារៈ ផ្សេងៗនៅលើកំរាលកន្លែងបង្កាត់ ។



ក្រោយពេលបង្កាត់ ជ្រូកមេ និងជ្រូកបាគួរតែបំបែកវាឱ្យនៅក្នុង ទ្រុងរបស់វារៀង១ខ្លួន។ ពេលខ្លះជ្រូកមេត្រូវបានគេដាក់នៅក្នុងទ្រុង របស់វាតែឯង ជៀសវាងការខាំគ្នា ជាមួយជ្រូក មេដទៃ ដែលជាហេតុធ្វើឱ្យការ បង្កកំណើតថយចុះ។



ចូរអ្នកកត់ត្រាឱ្យបានលំអិតពី ពេលវេលានៃការដាក់ឈ្មោល លើសៀវភៅកត់ត្រាសំរាប់ជ្រូកមេ។ ជ្រូកមេដែលបានដាក់ឈ្មោលហើយ គួរតែធ្វើការអង្កេតមើលអាការៈខាងក្រៅ ដែលជាសញ្ញាសង្ស័យ នៃការរកឈ្មោលម្តងទៀត។ ប្រសិនបើមេជ្រូកមិនបង្ហាញសញ្ញាអ្វីទេ ក្រោយពេលដាក់ឈ្មោលហើយបាន ២១ថ្ងៃ យើងអាចសន្មត់បានថាមេជ្រូកនោះផើមហើយ។



**ពេលវេលានៃការបង្កាត់**

អាយុនៃការដាក់ឈ្មោលវាអាស្រ័យទៅលើអាយុ និងទំងន់របស់មេជ្រូក។ ជ្រូកមេក្រមុំពេញរូបរាងអាចបង្កាត់បាននូវអាយុពី៨-៩ខែ និងបង្កើតកូននូវអាយុ ១២ទៅ១៣ខែ។ ជ្រូកមេក្រមុំពូជនាំចូលគួរមានទំងន់យ៉ាងហោចណាស់ ៨០គ.ក មុនពេលបង្កាត់។ ភាពជោគជ័យនៃការបង្កកំណើត គឺកើនខ្ពស់ នៅពេលដែលមេជ្រូករកឈ្មោលលើកទី២ រឺទី៣ (កុំដាក់ឈ្មោលនៅពេលមេជ្រូករកឈ្មោលលើកទី១)។



ជ្រូកមេក្រមុំតូចនេះត្រូវបានគេដាក់ឈោលរហ័សពេក។ កូនជ្រូក ៣រស់ និងកូនជ្រូក ៣ងាប់នៅពេលកើត

ជ្រូកក្រមុំមួយគួរតែមានលក្ខណៈពេញរូបរាងល្អមុនពេលដាក់បា

ជ្រូកក្រមុំតូចនេះត្រូវបានគេដាក់ឈ្មោលរហ័សពេកកូនងាប់

## ៥.៧ ការគ្រប់គ្រងការដាក់បា

ជ្រូកបាដែលគេបង្កាត់តាមបែបធម្មជាតិអាចពាក់មេបាន ២-៣ដងក្នុងមួយអាទិត្យ ដូច្នេះហើយទើបវាអាចមានកូន៧៥០ក្បាលក្នុងមួយឆ្នាំ។ បើប្រៀបធៀប ជ្រូកមេមួយក្បាលអាចផលិតកូនបានប្រហែល ១៥ក្បាលក្នុងមួយឆ្នាំ (២សំបុកក្នុងមួយឆ្នាំ)។



ការប្រុងប្រយត្ន័ត្រឹមត្រូវ គឺតំរូវឱ្យមានការជ្រើសរើស និងការគ្រប់គ្រងចំពោះជ្រូកបា ដើម្បីឱ្យកូនជ្រូកកើតមករឹងមាំ និងមានសុខភាពល្អ។

ចំណីជ្រូកបាត្រូវតែត្រួតពិនិត្យជៀសវាងការធាត់ និងស្គមពេក ដែលប្រការនេះវាមានឥទ្ធិពលទៅលើ គុណភាពនៃទឹកស្ពែម និងចំណង់ពាក់មេរបស់ជ្រូកបា។ ជាទូទៅ ជ្រូកបាពេញវ័យ គួរតែផ្តល់ចំណី ៣-៤ គ.ក ក្នុងមួយថ្ងៃ។ ប៉ុន្តែនៅពេលដែលជ្រូកបាពាក់មេច្រើន រឺក៏វាស្គមចុំនចនេះគួរតែបង្កើនការផ្តល់ចំណី និងបន្ថែម



បន្លែស្រស់ខ្លះទៅតាមរបបអាហារកំណត់ប្រចាំថ្ងៃ។

ត្រូវប្រុងប្រយត្ន័មិនត្រូវឱ្យជ្រូកបាពាក់មេ រឺយកស្ពែមច្រើនហួសពេកទេ ព្រោះគុណភាពទឹកកាមនឹងថយចុះបង្កកំណើត ។

| អាយុរបស់បា | ចំនួនដែលអាចបង្កាត់បាន |
|---|---|
| ៨-១២ខែ | ២ ដងក្នុងមួយអាទិត្យ |
| ១២ខែឡើង | ៣ ដងក្នុងមួយអាទិត្យ |

## ជំពូក ៦: ជ្រូកមេធើម

### ៦.១ ការត្រួតពិនិត្យ និងការកត់ត្រាមេជ្រូកធើម

ជ្រូកមេអាចរកឈ្មោលឡើងវិញរាល់ ២១ថ្ងៃ ។ ក្រោយការដាក់ឈ្មោលដែលទទួលបានជោគជ័យ មេជ្រូកនឹងមិនរកឈ្មោលទៀតទេ នៅពេលដែលវាធើម ។ ការដាក់ឈ្មោល ២ដងក្នុងចន្លោះពេលពី ៨-១០ម៉ោង វានឹងបង្កើនឱកាសនៃការមានផ្ទៃពោះរបស់ជ្រូកមេ និងទទួលបានកូនច្រើន ។ ចំណែកឯ ជ្រូកមេមិនមានផ្ទៃពោះ វានឹងរកឈ្មោលម្តងទៀត នៅ៣អាទិត្យ(២១ថ្ងៃ) ក្រោយដាក់ឈ្មោល ។ ដូច្នេះ ត្រួតពិនិត្យជ្រូកមេឡើងវិញ ក្រោយពីដាក់ឈ្មោលបាន ១៨-២៤ថ្ងៃ រួចហើយត្រួតពិនិត្យម្តងទៀត នៅ ៦អាទិត្យ (៤២ថ្ងៃ) ក្រោយដាក់ឈ្មោល ដើម្បីឱ្យប្រាកដថាមេជ្រូកទាំងអស់ធើម ។



ការដាក់ឈ្មោលលើកទី១ ៨-១០ម៉ោងក្រោយដាក់ឈោល ការដាក់ឈ្មោលលើកទី២



ការដាក់ឈ្មោល ត្រួតពិនិត្យនៅ ៣អាទិត្យក្រោយដាក់ឈ្មោល ត្រួតពិនិត្យនៅ៦អាទិត្យ ក្រោយ ដាក់ឈ្មោល



ត្រូវត្រួតពិនិត្យឱ្យមានប្រសិទ្ធិភាពចំពោះ ក្រុមជ្រូក មេដែលបានដាក់បាហើយ មេជ្រូកត្រូវតែដាក់សំគាល់ រឺកំណត់អត្តសញ្ញាណកម្មឱ្យបានច្បាស់ (ដាក់ប្លាកត្រចៀកនៃត្រចៀកដែលបានចុះ) ។



មេជ្រូកដែលធើមគួរតែដាក់បំបែកពីមេជ្រូក ដែលផ្តាច់ដោះកូនហើយនិងជ្រូកដទៃទៀតជៀសវាងការ ខាំគ្នា និងការមានបញ្ហាក្នុងពេលមេជ្រូកធើម ។

ត្រូវកត់ត្រាជ្រូកមេដែលបាន ដាក់ឈ្មោលហើយទាំងអស់ ។





## ៦.២ ការផ្តល់ចំណី និងសុខភាពជ្រូក

ក្នុងកំឡុងពេលមេជ្រូកធើម គួរតែផ្តល់ចំណីឱ្យបានគ្រប់គ្រាន់ សំរាប់ខ្លួនវាផ្ទាល់ និងអំប្រីយ៉ុង ។ ផ្អែកទៅលើការចិញ្ចឹមជ្រូក ពូជនាំចូល ចំណីដែលមានគុណភាព (បែបឧស្សាហកម្ម) និងការគ្រប់គ្រងបានល្អ ។ ចំនួនចំណីខាងក្រោមនេះ ត្រូវបានគេផ្តល់អនុសាសន៏ឱ្យ ប្រើក្នុងដំណាក់កាលខុសៗគ្នាក្នុងកំឡុងពេលធើម:

| ដំណាក់កាលរយៈពេលធើម | ចំនួនចំណីសំរាប់ជ្រូកមេ/ក្បាល |
|---|---|
| ក្រោយការបង្កាត់ ៣០ថ្ងៃ | ២.០០ គ.ក |
| ៣០-៦០ ថ្ងៃ | ២.២០ គ.ក |
| ៦០-៩០ ថ្ងៃ | ២.២០ គ.ក |
| ៩០-១០៥ ថ្ងៃ | ២.៥០ គ.ក |

| | |
|---|---|
| ១០៥-១១៤ ថ្ងៃ | ២.០០ គ.ក |
| នៅថ្ងៃកើតកូន | កុំផ្តល់ចំណី |

***ចូរចងចាំថា កុំផ្តល់បាយស្រោ រឺកាកបីយ៉ែ ដល់មេជ្រូកជិតកើតកូន មេបំបៅដោះកូន និងកូនជ្រូក ។***

ការផ្តល់ចំណីគួរតែដាក់កំណត់នៅពេលមេជ្រូកជិតកើតកូន ( ផ្តល់ចំណីច្រើនពេកបណ្តាលឱ្យជ្រូកក្លៀន និងពិបាកក្នុងកំឡុងពេលកើត) ប៉ុន្តែមេជ្រូកគួរតែត្រូវបានគេផ្តល់ទឹកផឹកស្អាតឱ្យបានគ្រប់គ្រាន់ ។



ចូរប្រុងប្រយត្ន័ ចំពោះការផ្តល់ចំណីត្រូវតាមចំនួនត្រឹមត្រូវពេក។ ការផ្តល់ ចំណីច្រើនពេក មេជ្រូកផលិត ខ្លាញ់ច្រើន តែបើផ្តល់ចំណីតិចពេក





វាបណ្តាលឱ្យមេជ្រូកស្គម។ បញ្ហាទាំងពីរនេះ នឹងបង្កការលំបាកនៅពេល ការបង្កើតកូន និង ការបំបៅដោះ។

កម្មវិធីចាក់ថ្នាំការពារ គឺមានសារសំខាន់សំរាប់ជ្រូក មេល្អទុកធ្វើពូជ។



ការត្រួតពិនិត្យមេជ្រូកម្តងៗជា រៀងរាល់ថ្ងៃ ដោយមើល ខ្ទើចជើង ក្លៀន អន់ចំណី ហូរទឹករំអិល ក្អក របួស ។ល។







បញ្ចុកថ្នាំទំលាក់ព្រូនតាមមាត់ ( ជៀសវាងការចាក់ក្នុងកំឡុងពេលជិត កើតកូន) និងលាងសំអាត មេជ្រូក នៅពេលវាត្រូវបានគេផ្លាស់ដាក់ ទ្រុងកើតកូន។

ត្រូវយកមេជ្រូកដាក់ក្នុងទ្រុងកើតកូន ៧ថ្ងៃមុនពេលដល់ថ្ងៃកើតកូន។ ពោលគឺនៅពេលមេជ្រូកផើម បានរយៈពេល ១០៧ថ្ងៃ។



ការថែរក្សាមេជ្រូកក្នុងកំឡុងពេលផើម បានត្រឹមត្រូវ ជួយឱ្យមេជ្រូក កើតកូនប្រកបដោយជោគជ័យ។



# ជំពូក ៧: ការកើតកូន

## ៧.១ មុនពេលកើត ក្នុងពេលកើត និងក្រោយពេលកើតកូន



នៅពេលមេជ្រូកជិតរកឈ្មោល គួរតែអង្កេតឱ្យបានជិតដល់ដើម្បីកំណត់ឱ្យច្បាស់ថ្ងៃកើតកូន ហើយប្រសិនបើចាំបាច់ត្រូវជួយមេជ្រូក និងសង្គ្រោះជីវិតរបស់កូនជ្រូក។ នៅក្នុងកសិដ្ឋានជាច្រើន ៣0 ភាគរយនៃចំនួនដែលបានកើតទាំងអស់ បានស្លាប់នៅអាយុ ៤ថ្ងៃ។ ការថែរក្សាបានល្អត្រឹមត្រូវ អាចជួយជីវិតកូនជ្រូកជាច្រើនបាន។



នៅពេលជិតកើតកូន មេជ្រូកបង្ហាញអាការៈទុក្ខភ័យ អាចខាំជញ្ជាំង យោនី និងកន្សោមដោះឡើង ប៉ោង។ នៅពេលជាមួយគ្នានេះដែរ កសិករអាចច្របាច់កន្សោម ដោះថ្នមៗ ហើយប្រសិនបើមានទឹកដោះចេញ បានន័យថា មេជ្រូកជិតដល់ពេលកើតកូនហើយ។

ទ្រុងកើតកូនគួរតែរៀបចំដោយមានចំបើងនៅលើកំរាល ហើយកន្សោមដោះ និងចុងដោះត្រូវតែ សំអាតឱ្យស្អាត។



កូនជ្រូកកើត ជាទៀងទាត់ ចន្លោះពីមួយទៅមួយប្រហែលពី១០-១៥នាទី ។

ប្រសិនបើចន្លោះពេលកើត លើសពីមួយ ម៉ោង នោះវាមានបញ្ហា ។ ចូរអ្នកសង្កេតមើលក្បាលពោះ ពីចលនារបស់កូនជ្រូកដែលមិនទាន់កើត ។

កសិករគួរតែយកចិត្តទុកដាក់ នៅពេលមេជ្រូក កើតកូន និងជួយវាប្រសិនបើ ចាំបាច់ ។ ក្រណាត់ស្អាតគួរតែមានសំរាប់សំអាត និងជូតសំងួតកូនជ្រូកនិងជូតរំអិលឱ្យអស់ចេញពីមាត់ និងច្រមុះដើម្បីធានាថាការ ដកដង្ហើមប្រព្រឹត្តទៅ បានងាយស្រួល ។ ការអនុវត្តន៍បែបនេះ កូនជ្រូកជាច្រើនត្រូវបានគេជួយសង្គ្រោះជីវិតបាន ។



នៅពេលយើងសង្កេត រឹប៉ាន់ស្មានបញ្ហា ដែលកើតមាននៅពេលកើតកូននោះ



កសិករត្រូវអនុវត្តការត្រួត ពិនិត្យតាមរន្ធយោនី ។ ពេលខ្លះកូនជ្រូកអាច ត្រូវខ្ទាស់ជាប់ ហើយកសិករអាចជួយកូនជ្រូកទាំងនេះដោយថ្នមៗ នៅពេលកើត ។

មុនពេលលូកចូលរន្ធយោនី កសិករត្រូវលាង ដៃ និងដើមដៃជាមួយនឹងសាប៊ូ ។ កាត់ក្រចក ឱ្យខ្លី និង សំអាតភាពកខ្វក់នៅជាប់នឹង ក្រចក ។ បើមិនប្រត្តិបត្តិតាមបទដ្ឋាន អនាម័យឱ្យបានម៉ត់ចត់ទេ នោះស្បូន



ងាយនឹងឆ្លងមេរោគយ៉ាងងាយស្រួល ។



ក្នុងករណីពេលកើតកូន មេជ្រូកមិនមានថាមពលគ្រប់គ្រាន់ រឺមិនមានការខំប្រឹងសំរាប់រុញកូនចេញ រឺថាការ កើតកើតកូនមានរយៈពេល ច្រើនជាង ១ម៉ោង មេជ្រូកត្រូវចាក់ថ្នាំ អុកស៊ីតូស៊ីន កំរិត ០.២៥សេសេ ចាក់ សាច់ដុំ ដើម្បីជួយមេជ្រូកក្នុងការរុញ កូនចេញមកក្រៅ ។ ប្រសិនបើមេជ្រូកនៅតែមិនទាន់កើតកូនទៀត ពេទ្យសត្វគួរតែត្រូវបានគេហៅមកសំរាប់ជួយសង្គ្រោះ ។



ត្រូវប្រាកដថាមេជ្រូកសំអាតរួច រាល់ក្នុងរយៈពេលមួយម៉ោង ក្រោយពេល កូនជ្រូកចុងក្រោយបានកើត រឺការឆ្លងមេរោគ តាមស្បូនអាចនឹងមានជាលទ្ធផល ។



ត្រួតពិនិត្យកន្សោមដោះរបស់មេជ្រូក យ៉ាងហោចណាស់ឱ្យបាន ២ដងក្នុងមួយថ្ងៃ ។ ប្រសិនបើ វារឹងជាដុំៗ និងក្តៅកន្សោមដោះ របស់អាចនឹងមានឆ្លងមេរោគ (ជំងឺរលាកដោះ) ។ ក្នុងករណីនេះ គួរតែហៅពេទ្យសត្វដើម្បីជួយសង្គ្រោះ ។



ប្រើអុកស៊ីតូស៊ីន និងអង់ទីប៊ីយោទិច តាមវេជ្ជបញ្ជាពេទ្យត្វតែមួយគត់ដើម្បី ព្យាបាល ការឆ្លងមេរោគលើកន្សោមដោះ និងស្បូន ។

## ៧.២ ការថែរក្សាសុខភាពកូនជ្រូកទើបកើត និងមេជ្រូក



គ្រប់កូនជ្រូកទាំងអស់ត្រូវ ដាក់ឱ្យបៅដោះភ្លាមៗ នៃដំបូងរបស់មេវា (ទឹកដោះព្រៃ រឺកូឡូសជ្រូម) ពីព្រោះទឹកដោះនេះ មានស្ដុកអង់ទីគរ័ ការពារកូនជ្រូកប្រឆាំងនឹងមេរោគ ។



សំលាប់មេរោគលើផ្ចិតឱ្យលឿនតាមដែលអាចធ្វើបានដល់កូនជ្រូកដែលទើបកើត (ប្រើអ៊ីយ៉ូតឌីន) ។ កាត់ធ្មេញព្រៃ និងកាត់កន្ទុយរបស់កូនជ្រូកឱ្យខ្លី ប្រសិនបើត្រូវការ (កាត់កន្ទុយ) ។





នៅពេលកូនជ្រូកត្រូវបានគេដាក់ក្នុងទ្រុងធ្វើពីឈើ រឺទ្រុងចាក់ស៊ីម៉ង់ត៍ កូនជ្រូកត្រូវការចាក់ជាតិដែក ក្នុងរយៈពេល ៧២ម៉ោងក្រោយពេលកើត ដើម្បីការពារជំងឺខ្វះឈាម (ទឹកដោះមេមានជាតិដែកមិន គ្រប់គ្រាន់) ។ ការចាក់ជាតិដែកមិនជាចាំបាច់ទេ នៅពេលដែលកូនជ្រូកមានទីធ្លាដើរ ដែលជាតិដែកនេះ មាននៅក្នុងដី

(នៅក្នុងដីមានផ្ទុកជាតិដែក) ។ កូនជ្រូកដែលមានជាតិដែកមិនគ្រប់គ្រាន់ វាមានរូបរាងស្លេក ស្គាំង និងរោមបះ





រួចចាប់ផ្តើមជ្រុះរោម និងអាចងាប់ ។

កន្លែងកក់ក្តៅសំរាប់កូនជ្រូកទើបកើតដាក់ឱ្យឆ្ងាយពីមេជ្រូក គឺមានសារៈសំខាន់ ។ កន្លែងនេះគួរតែ មានកំដៅពី ២៧-៣០ ដឺក្រេសេ សំរាប់កូនជ្រូកទើបកើតបាន ៤ថ្ងៃ និងកន្លែងទាក់ទាញកូនជ្រូកដែលមាន ទីធ្លា ។ ប្រអប់ដាក់កូនជ្រូកមានទំហំ ៦០ស.ម គុណ ៦០ ស.ម និង/រឺ មានផ្តល់ភាពកក់ក្តៅដល់កូនជ្រូក ។



ផ្តល់ចំណីដល់មេជ្រូក ២ដងក្នុងមួយថ្ងៃ ហើយចំណីមិនត្រូវធំក្លិន រឺខូច ។ ទឹកផឹកត្រូវដាក់ឱ្យមានជា ប្រចាំ ។

ត្រូវប្រុងប្រយត្ន័ មេជ្រូកមិនត្រូវការកំដៅខ្លាំងពេកទេ មិនស៊ីចំណី រឺក្បៀន ។ ក្នុងករណីនេះ មេជ្រូក នឹងមិនផលិតទឹកដោះគ្រប់គ្រាន់ទេ សំរាប់កូនរបស់វា ។



ការផ្តល់ចំណីដែលមានគុណភាពដល់មេជ្រូក គឺមានសារៈសំខាន់ណាស់ ។ ចំនួនចំណីត្រូវការកាត់បន្ថយ នៅថ្ងៃដែលមេជ្រូកកើតកូន រហូតដល់១-២ថ្ងៃក្រោយទៀត ។ បន្ទាប់មកទៀត ចំណីគួរតែផ្តល់ទៅតាម តំរូវការរបស់មេជ្រូក ទៅតាមចំនួនកូនក្នុងសំបុក និងលក្ខខណ្ឌជាក់ស្តែងរបស់វា ។



នៅថ្ងៃកើតកូន មិនត្រូវផ្តល់ចំណីដល់មេជ្រូកទេ ប៉ុន្តែគួរដាក់ទឹកផឹកឱ្យគ្រប់គ្រាន់ ។ នៅថ្ងៃទី ពីរ និងថ្ងៃបន្ទាប់ មេជ្រូកត្រូវបានគេផ្តល់ចំណីឱ្យស៊ីច្រើនជាបណ្តើរៗ ។ មេជ្រូកមួយត្រូវការរបបអាហារប្រហែល ២.០០-២.៥០គ.ក ក្នុងមួយថ្ងៃ សំរាប់ថែទាំទំងន់ខ្លួនរបស់វា ។ ចំពោះការផលិតទឹកដោះ និងចំណីសំរាប់កូន របស់វា ត្រូវការបន្ថែម ០.២៥គ.កសំរាប់កូនជ្រូកមួយក្បាលក្នុងមួយថ្ងៃ ( សំដៅទៅលើ ជ្រូកមេពូជនាំចូល រឺ ពូជដែលគេបានកែលំអរ





ដោយគេបានផ្តល់ចំណីដែលមានគុណភាព) ។

ឧទាហរណ៏ : របបអាហារសំរាប់មេជ្រូក ដែលមានកូនចំនួន ៨ក្បាល គឺផ្តល់ចំណី ៤គ.កក្នុងមួយថ្ងៃ : ២ គ.ក + (០.២៥ គ.ក គុណនឹង ៨ក្បាល) = ២គ.ក+ ២គ.ក= ៤គ.ក សំរាប់មេជ្រូកក្នុង១ថ្ងៃ ។

## ជំពូក ៨: មេជ្រូកបំបៅដោះ និងកូនជ្រូក

### ៨.១ ទ្រុង និងទីធ្លាសំរាប់កូនជ្រូក



មេជ្រូកមួយ មានទំងន់ ១០០ដង ច្រើនជាងទំងន់កូនជ្រូកនៅពេលកើត ។ កូនជ្រូកជាច្រើន ត្រូវមេដេកសង្កត់ លុះត្រាតែយើងធ្វើការប្រុងប្រយត្ន័ ។ ភាពកក់ក្តៅ ទីធ្លាលេងសប្បាយធ្វើឱ្យកូនជ្រូក ចូលចិត្ត ត្រូវដាក់នៅឆ្ងាយពីមេជ្រូក គឺជាវិធីមួយដ៏ល្អបំផុត ។

កូនជ្រូកទើបកើតត្រូវការស្អាត ស្ងួត មានទីធ្លាសំរាប់កូនជ្រូកដើរលេង កន្លែងរឹទ្បាំងកក់ក្តៅ ដើម្បីថែទុកកូនជ្រូកឱ្យមានសុខភាពល្អ ជៀសវាងជំងឺរាគ និងការពារកូនជ្រូកខ្សោយឱ្យរួចផុតពីសេចក្តីស្លាប់ ។ កន្លែងដែលមានភាពសុខស្រួលបែបនេះ អាចត្រូវបានគេដាក់ចំបើងដែលស្ងួតនៅលើកំរាលដោយរួមជាមួយ ភ្លើងអំពូលអគ្គិសនី រឺចង្កៀងប្រេងកាតដាក់ខាងលើ (កំពស់ប្រហែល ១ម៉ែត្រ) ដើម្បីផ្តល់កំដៅដល់កូនជ្រូក។







កូនជ្រូកដែលស្លាប់ព្រោះតែមេជ្រូក ដេកកិន លើទាំងអស់ គឺមិនអាចទទួលយកបាន ហើយឆ្លុះ បញ្ចាំងពីកំរិតនៃការថែទាំមិនបានល្អ ។





ទ្រុងមេសំរាប់កើតកូនមួយ នឹងការពារកូនជ្រូកជាច្រើនឱ្យគេចផុតពីការដេកកិនរបស់មេវា ។

បើនៅក្នុងទ្រុងដែលគ្មាន ទ្រុងសំរាប់កើតកូន ទ្រុងជ្រូកនោះត្រូវមានរបារឹងមាំ ហើយឃ្លាតឆ្ងាយពីជញ្ជាំង ២០ សង់ទីម៉ែត្រ (និងកំពស់ ២០ សង់ទីម៉ែត្រពីលើកំរាលទ្រុង) ដើម្បីការពារកូនជ្រូកកុំឱ្យគាប នឹងជញ្ជាំង ។



## ៨.២ ការថែទាំសុខភាពរបស់កូនជ្រូក និងមេជ្រូក

បញ្ហារបស់កូនជ្រូកគឺ មេជ្រូក និងការផ្តល់ចំណី មានន័យថា កូនជ្រូកមិនបានទទួលទឹកដោះគ្រប់គ្រាន់ពីមេរបស់វា ។



(ពីងប៉ុង) លាមកមូលដូចបាល់ រឺគ្មានលាមក មានន័យថាមេជ្រូកក្បៀន ។ មេជ្រូកនឹងមិនសុខស្រួល



ឡើយ ។ កសិករជាញឹកញាប់ ដឹងពីការប្រើប្រាស់ ថ្នាំបុរាណ ដើម្បីយកជ័យជំនះពីបញ្ហាក្លៀននេះ ។



គ្រោះថ្នាក់ដោយសារក្លៀន គឺថាចំណើឡើងជូរនៅក្នុងពោះវៀន ។ ជាតិពុលត្រូវបានជ្រាបចូលទៅក្នុង ឈាមដែលបណ្តាលឱ្យមានបញ្ហា លើទឹកដោះ ។ កន្ទ្រាមដោះមេជ្រូក ឡើងក្តៅ និងរឹង ។



រាគ គឺជាជំងឺខ្លាំងជាងគេបំផុត គំរាមកំហែងជីវិតរបស់កូនជ្រូក ។ ក្នុងរយៈពេលតិចជាង ២៤ម៉ោង កូនជ្រូកនឹងបាត់បង់ជាតិទឹក ។





ដំណោះស្រាយមួយដោយថ្នាំបាត់បង់ជាតិ ( អំបិលបន្ថិចលាយជាមួយនឹងស្ករ) អាចផ្តល់ឱ្យកូនជ្រូកដែល



ខ្សោយតាមសុីរ៉ាំងដោយមានបំពង់ រឺអត់បំពង់ រឺក៏ដាក់ក្នុងចំណី ប្រសិនបើកូនជ្រូកអាចស៊ីចំណីបានដោយខ្លួនវា ។

ការពារប្រសើរជាងព្យាបាល ។ អ្នកត្រូវប្រាកដថា កូនជ្រូកទាំងអស់បានទទួលជាតិដែក និងមេជ្រូកបានចាក់ទំលាក់ព្រូនបានត្រឹមត្រូវ ហើយជាទូទៅកម្មវិធីចាក់ថ្នាំការពារប្រឆាំងនឹងជំងឺត្រូវបានគេធ្វើយ៉ាងត្រឹមត្រូវមុនពេលកើតកូន ។

## ៨.៣ ការសាងសង់ទ្រុង អនាម័យ និងការផ្តល់ចំណី

ទ្រុងជ្រូកដែលល្អមានភាពតានតឹង (stress )តិចបំផុត និងមានកំរាល



បន្ទះឈើ រឺដែកតូចៗតំរៀបគ្នា ( ចន្លោះពីបន្ទះដែកមួយទៅបន្ទះដែកមួយ 0.៥-១.0សង់ទីម៉ែត្រ) ដែលលាមកជ្រូកជ្រុះបាន ដើម្បីឱ្យ កូនជ្រូកមិនមានផ្ទុះជំងឺឆ្លង ។



បទដ្ឋានអនាម័យនៅក្នុងទ្រុងមេជ្រូកកើតកូនត្រូវតែធ្វើអនាម័យឱ្យបានល្អជាទីបំផុត ។ វាមានសារៈសំខាន់សំអាតទ្រុងឱ្យបានស្អាត លាងសំអាតដោយបាញ់ទឹក និងសំលាប់មេរោគពេលដាក់ជ្រូក
ចិញ្ចឹមបន្តចន្លោះពេលពីជ្រូកមួយទៅជ្រូកមួយទៀត ។



ការផ្តល់ចំណី និងទឹកដល់មេជ្រូកបានត្រឹមត្រូវ ជួយឱ្យវាផុតក្តីបារម្ភនៅក្នុងពេលបំបៅដោះ ។

នៅពេលកូនជ្រូកដល់អាយុ ៧ថ្ងៃ ពួកវាត្រូវរៀនស៊ីចំណី
ពួកវាគួរតែស៊ីចំណីបែប




ឧស្សាហកម្មគ្រាប់ល្អិតៗដែលមានគុណភាព ( ប្រហែល ២0ក្រាមសំរាប់កូនជ្រូកមួយក្នុងមួយថ្ងៃ រឺចំណីដែល

ធ្វើនៅផ្ទះ ដោយលាយជាមួយ កន្ទក់ ចុងអង្ករដែលមានគុណភាព និងកិនលាយជាមួយគ្រាប់ពោត ។ ទឹកផឹកស្អាតត្រូវដាក់ឱ្យវាផឹកជាប្រចាំ ។

កូនជ្រូកឈ្មោលដែលគេមិនបាន ជ្រើសរើសសំរាប់ទុកធ្វើពូជ អាចត្រូវបាន គេគ្រៀវនៅអាយុ ២អាទិត្យ (ងាយស្រួលចាប់ និងមុខរបួសឆាប់ជា) ។



## ៨.៤ តារាងសំរាប់មេជ្រូកបំបៅដោះ និងកូនជ្រូក

១. យោនីមានទឹកលំហូរពណ៌ស បញ្ជាក់ថាស្បូនមានជំងឺឆ្លង ។

២ .កន្សោមដោះក្តៅ និងដុំពកៗ បញ្ជាក់ថាកន្សោមដោះមានជំងឺឆ្លង (ជំងឺរលាកដោះ)

៣.មេជ្រូកដេកមិនឱ្យកូនបៅដោះ បញ្ជាក់ថាកន្សោមដោះរបស់វាមានបញ្ហាៈ ស្ងួតទឹកដោះ រឺឈឺចាប់ ដោយសារគេមិនបានកាត់ធ្មេញព្រៃរបស់កូនជ្រូក ។

៤.មេជ្រូកខ្វះថាមពល និង/រឺ ក្តៅ បញ្ជាក់ថាមេជ្រូកមិនមានសុខភាពល្អ ដែលបណ្តាល ឱ្យវាមិនថែទាំកូនរបស់វា ។ ចូរអ្នកត្រួតពិនិត្យកំដៅរបស់វា ។

៥. មេជ្រូកស៊ីចំណីមិនឈប់អាចបញ្ជាក់ថា ការផ្តល់ចំណីច្រើនពេក រឺមិនមានទឹកផឹក រឺមេជ្រូកមិនមានសុខភាពល្អ

៦.កូនជ្រូកស្គម និងរោមបះ ប៉ុន្តែមិនបានដុសសំអាតទេ នោះបញ្ជាក់ថា ខ្វះទឹកដោះ ។ តែប្រសិនបើគេដុសសំអាតហើយវាមានពណ៌ស កូនជ្រូកអាចបណ្តាលមក ពីខ្វះជាតិដែក។

៧.កូនជ្រូកនៅមិនស្ងៀម និងនៅជិតមេរបស់វា បញ្ជាក់ថា កូនជ្រូកមិនបានទទួលទឹក ដោះគ្រប់គ្រាន់

៨.កូនជ្រូកជាច្រើនដេកគរលើគ្នា បញ្ជាក់ថាកូនជ្រូករងារពេក និងដេកជិតមេរបស់វា រឺពួកវាមិនបានទទួលទឹកដោះគ្រប់គ្រាន់ រឺមេជ្រូកមិនមានទឹកដោះគ្រប់គ្រាន់ ។

៩.កូនជ្រូកនៅគរលើគ្នាបញ្ជាក់ថា ពួកវាត្រជាក់ និងមិនសប្បាយរីករាយ ។

១០.ក្រមរដំបៅក្រៀមលើមុខ និងក្បាលជង្គង់បញ្ជាក់ថា កូនជ្រូកខាំគ្នាពេលស៊ីចំណីពីព្រោះពួកវាមិនបានទទួលទឹកដោះគ្រប់គ្រាន់ ។ បើវាកូនជ្រូកស្នាមរលាត់តែជង្គង់ មានន័យថា កំរាលទ្រុងគ្រើមពេក

១១.ស្បែកកូនជ្រូកដុះសំអាតពណ៌លឿង គឺជាទឹកដោះ មេជ្រូកឱ្យកូនបៅទឹកដោះច្រើន ពេក តែបើដុសសំអាតទៅពណ៌ស រឺក្រហម អាចបណ្តាលមកពីបាក់តេរី ដូចនេះត្រូវ ការព្យាបាលដោយអង់ទីប៊ីយោទិច ។

១២.មេជ្រូកមិនជុះអាចម៍ រឺលាមករឹងមូល បញ្ជាក់ថាមេជ្រូកក្តៀន ។ បញ្ហានេះអាចបណ្តាលឱ្យមេជ្រូកមិនសុខស្រួល ហើយវាជាបុព្វហេតុនាំឱ្យមានបញ្ហាទឹកដោះ ។




## ជំពូក ៩: ការថែរក្សា និងផ្តាច់ដោះកូនជ្រូក

### ៩.១ ភាពស៊ាំ និង ពេលវេលាផ្តាច់ដោះ

កូនជ្រូកទើបផ្តាច់ដោះងាយនឹងរងគ្រោះថ្នាក់ណាស់ ការទទួលភាពស៊ាំបន្ថែមពីមេរបស់វារួមជាមួយនឹង ភាពស៊ាំរបស់វា គឺមានតិចតួចណាស់ ។ ៥អាទិត្យក្រោយប៉ុណ្ណោះ គឺភាពស៊ាំផ្ទាល់ខ្លួនរបស់វា (តាមរយៈ កន្លែងចិញ្ចឹម និង/រឺ តាមរយៈការចាក់ថ្នាំការពារ) មានលទ្ធភាព ប្រឆាំងនឹងជំងឺនៅកំរិតណាមួយដែល សមហេតុផល ។




ការផ្តាច់ដោះតាមទំលាប់ គឺនៅអាយុ ៦អាទិត្យ ហើយកូនជ្រូកត្រូវបានគេយកទៅដាក់ទ្រុងផ្តាច់ដោះ ។ នៅក្នុងកសិដ្ឋានដែលគេបានកែលំអរ(បែបឧស្សាហកម្ម) ការផ្តាច់ដោះគេអនុវត្តនៅអាយុ ៤អាទិត្យ ។

**អាយុ ៦អាទិត្យ**



ថ្ងៃទីមួយក្នុងកំឡុងពេលផ្តាច់ដោះ (គ្មានមេជ្រូក មិនមានការថែទាំពីមេ និងមិនមានទឹកដោះ ) កូនជ្រូកដែលខ្សោយអាចត្រូវបានគេផ្លាស់ទីកន្លែង និងផ្តល់ចំណីដែលមានគុណភាពល្អ ហើយនៅដំណាក់កាលនេះ



**អាយុ ៤អាទិត្យ**





គឺមានសារៈសំខាន់ណាស់ ។

មុនផ្តាច់ដោះកូនជ្រូក អ្វី១ទាំងអស់គឺប្រកបដោយគ្រោះថ្នាក់ ពោលគឺ សុខភាព និងអនាម័យ ចំណីអាហារ និងទ្រុង ។ អ្វី១ទាំងអស់ដែលនៅក្នុងទ្រុងផ្តាច់ដោះត្រូវតែសំអាតឱ្យបានម៉ត់ចត់ និង សំលាប់ មេរោគមុនពេលនាំក្រុមកូនជ្រូកផ្តាច់ដោះថ្មីមកដាក់ក្នុងទ្រុង ។

យើងត្រូវផ្តល់កន្លែងកក់ក្តៅដល់គ្រប់កូនជ្រូកតូច១ទាំងអស់ ជាពិសេសកូនជ្រូកមុនពេលផ្តាច់ដោះ ។ ស្ទើរគ្រប់កូនជ្រូកតូច១ទាំងអស់ មិនធន់ទៅនឹងការផ្លាស់ប្តូរអាកាសធាតុទេ ។ ទីធ្លាទូលាយ និង កន្លែងកក់ក្តៅងាយស្រួល ត្រូវមានគ្រប់ពេលនៅពេលកូនជ្រូកត្រូវការ ។



តំរូវការចំណីរបស់កូនជ្រូកត្រូវមានរស់ជាតិឆ្ងាញ់ ។ មានតែចំណី បែបឧស្សាហកម្មតែមួយគត់ដែលគួរប្រើ ។ ចំណីថ្លៃនឹងត្រូវចំណាយ សំរាប់ពពួកវា នៅពេលកូនជ្រូកនៅរស់ច្រើន និងធំជាងបើប្រៀប ធៀបទៅនឹងជ្រូក ៨ អាទិត្យ ។

របបអាហារសំរាប់កូនជ្រូកដែលបានផ្តាច់ដោះ អាចដូចខាងក្រោម ( អាស្រ័យលើពូជជ្រូកនាំចូល រឺពូជជ្រូកដែលត្រូវការចំណីដែលមានគុណភាព) :

- ចាប់ផ្តើមការផ្តល់ចំណីលើកទី១ ( កូនជ្រូកអាយុ ៤អាទិត្យ) ២០០-២៥០ក្រាមសំរាប់កូនជ្រូក ១ក្បាលក្នុង១ថ្ងៃ ។
- បង្កើនរបបអាហារ ១០០ក្រាមសំរាប់ជ្រូកមួយក្បាលក្នុងមួយថ្ងៃនៅអាទិត្យនិមួយ១បន្តបន្ទាប់
- នៅអាយុ ៨អាទិត្យ ( មួយខែក្រោយ) កូនជ្រូកត្រូវបានគេផ្តល់ចំណី ៦០០-៧០០ក្រាមសំរាប់កូនជ្រូកមួយក្បាលក្នុងមួយថ្ងៃ ( ប្រើចំណី ៣ដងច្រើនការចាប់ផ្តើម



ផ្តល់នៅលើកទី ១)

កូនជ្រូកតូចៗលូតលាស់លឿនណាស់ ។ ក្នុងល័ក្ខខណ្ឌគ្រប់គ្រងបានល្អ ការលូតលាស់របស់កូនជ្រូកដែលមានអាយុ៨អាទិត្យភាគច្រើនបានកើនឡើង៣ដង ។ ចាប់ពីអាយុ ៤អាទិត្យកូនជ្រូកមានទំងន់ ៦-៧គ.ក ចំពោះអាយុ១២អាទិត្យ មានទំងន់១៥-២០គ.ក ( ទំងន់កូនជ្រូកទាំងនេះ សំរាប់ពូជជ្រូកដែលចិញ្ចឹមតាមបែបឧស្សាហកម្ម ) ។ ការលូតលាស់របស់កូនជ្រូកកើតមានឡើងនៅដំណាក់កាលថៃទាំ ។ ការកំណត់សក្តានុភាពរបស់វាសំរាប់ការលូតលាស់ដែលមានប្រសិទ្ធភាពក្នុងកំឡុងពេលនៃការបំប៉នឱ្យធាត់ ( ជ្រូកកាន់តែធំធាត់ឡើងចាប់ពីទំងន់ ៦០-៨០-១០០គ.ក) ។

ជ្រូកត្រៀមសំរាប់កាប់សាច់: អាយុ ១២អាទិត្យក្នុងកំឡុងពេលនៃការថែបំប៉នឱ្យធាត់ ទំងន់ ៧០-៨០គ.ក នៅអាយុ ២៤អាទិត្យ ។



កូនជ្រូកអាយុ៤អាទិត្យមុនផ្តាច់ដោះ ជ្រូកត្រៀមសំរាប់បំប៉នឱ្យធាត់ទំងន់ ១៥-២០គ.កអាយុ ១២អាទិត្យ



ការថែទាំកូនជ្រូក

៨អាទិត្យ

## ៩.២ ការផ្តល់ចំណី និង ទ្រុងសំរាប់កូនជ្រូកផ្តាច់ដោះ

កសិករត្រូវតែប្រាកដថា កូនជ្រូកទាំងអស់ ផឹកទឹកគ្រប់ គ្រាន់សំរាប់ ការពារ ការបាត់បង់ជាតិទឹក និងជំរុញឱ្យកូនជ្រូកផឹកទឹក ។



កសិករត្រូវតែផ្តល់ចំណីឱ្យបាន ៤-៥ដង ក្នុង១ថ្ងៃ និងត្រូវឱ្យច្បាស់ថាកូនជ្រូកទាំងអស់អាចស៊ីចំណីរួមគ្នាពេលតែមួយបាន



( មានទីធ្លាសមល្មមសំរាប់កូនជ្រូកមួយក្បាល១) ។

អ្នកចិញ្ចឹមត្រូវតាមសង្កេតដោយយកចិត្តទុកដាក់ និងព្យាបាលភ្លាម១ ចំពោះជ្រូកមួយណាដែលមានបញ្ហា ។



វាជាការប្រសើរបើយើងប្រើ បន្ទះឈើ រឺដែក ធ្វើដូច្នោះលាមករបស់វាមិនជាប់ នៅលើកំរាល ។ ការគ្រប់គ្រងបែបនេះគឺ កូនជ្រូកតូចៗមិនគួរយកពួកវា ទៅដាក់ក្នុងទ្រុងចាក់កំរាលស៊ីម៉ង់ទេ ទុកឱ្យពួកវាបាន អាយុ៨អាទិត្យសិនទើបល្អ ។



សំរាប់កសិដ្ឋានធំៗ ( ផលិតដោយរោងចក្រ) សំភារៈមានដូចខាងក្រោមគឺ កំណាត់ដែក ដែកដែលមាន លាបថ្នាំ និង បន្ទះប្លាស្ទិចរឹង ។

ទ្រុងកំរាលស៊ីម៉ង់តឹ ហាក់ដូចជាអេប៉ង់នៅពេលវាកើតមានបាក់តេរី ។ វាពិបាកណាស់ដើម្បីធ្វើឱ្យទ្រុងដែល មានកំរាល ស៊ីម៉ង់តឹស្អាតល្អដោយមិនមានបាក់តេរី ។ ការពង្រីកផ្ទៃរបស់ទ្រុងដែលមានកំរាលស៊ីម៉ង់តឹ បង្ហាញថា ទ្រុង គគ្រាតគគ្រើមពេកដែលបណ្តាល ឱ្យពពួកមេរោគលាក់ខ្លួនចេញពីការបោស សំអាតបាន ។





កូនជ្រូកនឹងផ្លាស់ទីនៅក្នុងទ្រុងដើម្បីស្វែង រកទីកន្លែងដែលវាមានអារម្មណ៏ថារស់នៅកក់ក្តៅ សំរាប់ពួកវា ។



សំរាប់ការអនុវត្តជាក់ស្តែង ដំណាក់កាល ការថែទាំដំបូង( ពី ៤ទៅ១២អាទិត្យ) គឺភាគច្រើន ត្រូវបានគេប្រើយ៉ាងទូលំទូលាយ ។ ទ្រុងថែទាំកូនជ្រូក នេះ ត្រូវរៀបចំទីធ្លាធ្វើឱ្យទូលាយល្អ ខណៈដែលកូន ជ្រូកលូតលាស់ពី ៧គ.ក ទៅ២០គ.ក ។ ការចិញ្ចឹម សត្វត្រូវតែមានគំនិតសុទិដ្ឋិនិយម ។



ក្នុងកសិដ្ឋានធំៗ ( កូនជ្រូកចេញទាំងអស់ ចូលទាំងអស់) ជ្រូកដែលគេដាក់ក្នុងទ្រុងរួមគ្នា គឺមានទំងន់ និងអាយុដូចៗគ្នា និង បំបែកចេញពី ជ្រូកដែលមានអាយុខុសគ្នា ។

## ៩.៣ ការចាប់ និងដឹកកូនជ្រូក



ពីរអាទិត្យក្រោយពេលផ្តាច់ដោះកូនជ្រូកអាចត្រូវបានគេលក់ រឺផ្លាស់ទៅទីកន្លែងផ្សេង ។ នៅពេលបំបែកកូនជ្រូកទៅកន្លែងដទៃទៀត ត្រូវសំអាត និងបាញ់ថ្នាំសំលាប់មេរោគ នៅក្នុងទ្រុងថ្មីជាមុនសិនមុនពេលដាក់កូនជ្រុក ហើយសំភារៈ ( ស្នូកទឹក និងស្នូកចំណី) និង ត្រូវផ្តល់ចំណីគ្រប់គ្រាន់ ។



នៅពេលលក់ និងបំបែកកូនជ្រូកត្រូវការប្រុងប្រយត្ន័ដូចខាងក្រោមៈ

- សំរាប់កូនជ្រូកតូចៗ ចាប់ជើងក្រោយ និងដៃម្ខាងទៀតកាន់វា



- អាចត្រូវការមនុស្សពីរនាក់ដើម្បីចាប់ជ្រូកជំទង់ ដូចជាបង្ខំជ្រូកដាក់ជុច រឺដាក់លើឡាន ។

- ជ្រូកអាចខាំគ្នាក្នុងកំឡុងពេលនៃការដឹកជញ្ជូន ។ គេអាចដាក់ពួកវានៅក្នុងជុចបើសិនចាំបាច់ ។ ក្នុងកំឡុងពេលដឹកជញ្ជូននោះដែរ ជ្រូកត្រូវបានគេការពារទប់ទល់ទៅនឹងការរលាក់



ប៉ះទង្គិច និងកំដៅខ្លាំងពីព្រះអាទិត្យ ។

នៅពេលដែលឡានដឹកជ្រូកឈប់សំរាកនៅកន្លែងមួប់ ត្រូវបាចទឹកឱ្យជ្រូកដើម្បីកាត់បន្ថយកំដៅ ។ ពេលមកដល់ ត្រូវទុកឱ្យជ្រូកសំរាកប្រហែល ៣០នាទីសិន ហើយបន្ទាប់មកទើបដាក់ទឹក និងចំណីឱ្យវាស៊ី ។

## ជំពូក ១០: ជ្រូកជំនង់ និងជ្រូកសាច់

### ១០.១ បញ្ហាលើជ្រូកជំនង់ និងកំឡុងពេលជ្រូកសាច់



កូនជ្រូកត្រូវបានគេបំបែកពីទ្រុងថែទាំមកដាក់ក្នុងទ្រុងជ្រូកសាច់នៅអាយុ ១២អាទិត្យ នៅពេលដែល ពួកវាមាន ទំងន់ ១៨ ទៅ២០គ.ក ។ ការបំបែក

នៅអាយុខ្ចីពេក រឺ ទំងន់ស្រាលពេក អាចកាត់បន្ថយ សមត្ថភាព និងលទ្ធភាពនៃ ការលូតលាស់របស់ជ្រូក ។




ការមិនបានទទួលផលចំពោះជ្រូកសាច់ គឺពិបាកកត់សំគាល់ដូចជាជ្រូកលូតលាស់យឺត រឺចំណីមិនមានគុណភាព ។ ចូរជៀសវាងការផ្តល់ ចំណីដែលគ្មានគុណភាពផ្តល់ការថែទាំសុខភាពសត្វបានល្អ និង រៀបចំទ្រុងត្រឹមត្រូវ គឺជាកត្តា សំខាន់ បំផុតសំរាប់ការចិញ្ចឹមជ្រូកដែលទទួលបាន ផលចំណេញ ។

បញ្ហាលើផ្លូវដង្ហើមកើតមានឡើងចំពោះ
សត្វ ដូចជា ក្អក កណ្តាស់
ច្រមុះរៀចដោយរលាកច្រមុះ
និងហើមសួតបណ្តាលមកពីវីរុស
និងបាក់តេរី ជាដើម ។





បញ្ហាលើផ្លូវរំលាយអាហារ ឧទាហរណ៍
ជ្រូករាគ វីរុសបង្ការលើ ពោះវៀន អាចបណ្តាលឱ្យរាគ
និង/រឺ លាមកមានលាយ ឈាម ។
បរាសិតនៅក្នុងក្រពេះនិង ពោះវៀន
អាចបឺតយកសារធាតុចិញ្ចឹមបានយ៉ាងច្រើនពីជ្រូក ។
បរាសិតខាងក្រៅ (ចៃ)ជាមូលហេតុបណ្តាលឱ្យជ្រូក
ស្រេស្គ និង ស្រកទំងន់ ។



បញ្ហាទីធ្លាផ្តល់ចំណី: ទំហំទីធ្លាផ្តល់ចំណី
មានសារៈសំខាន់ណាស់ជាពិសេសនៅពេលជ្រូកកាន់តែ
ធំ ។ ជ្រូកដែលខ្សោយ និងជ្រូកដែលមិនអាចប្រជែងគេ
បាន មិនមានឱកាសស៊ីចំណីបានគ្រប់គ្រាន់ទេ ហើយ
ពួកវាកាន់តែតូចជាងគេ ។



បញ្ហាទឹក: យ៉ាងហោចណាស់
ត្រូវមានក្បាលបឺតទឹក ២ក្នុងទ្រុងមួយហើយពេល
ដែលជ្រូកត្រូវការទឹកត្រូវមានគ្រប់ពេល ។ ចូរអ្នកត្រួត



ពិនិត្យទឹកជារៀងរាល់ថ្ងៃ។ បំពង់ទឹកគួរធ្វើពី សំណាបាហាំង ដើម្បីការពារការខាំស៊ីរបស់ជ្រូក។

## ១០.២ ការបែងចែកជាក្រុម និងការផ្តល់ចំណី

ជ្រូកមេក្រមុំ និងជ្រូកសាច់ទំងន់ចាប់ពី ៥០គ.ក ឡើងគួរតែដាក់ទ្រុងដាច់ពីគ្នា ពីព្រោះតំរូវការ ចំណីរបស់វាខុសគ្នា។



ជ្រូកបា ជ្រូកគ្រៀវ ជ្រូកមេក្រមុំ

ជ្រូកមេក្រមុំត្រូវការចំណីដែលមានប្រូតេអ៊ីនច្រើន ហើយការលូតលាស់យឺតម្តងបន្តិចៗ។



ជ្រូកសាច់ស៊ីចំណីច្រើន ហើយឆាប់បំពេញបានទំងន់ទីផ្សារ(ឆាប់បានលក់)។

ជ្រូកស៊ីច្រើនទំងន់ ចាប់ពី ១៥-២០គ.ក ទៅ ៦០-៨០គ.ក ហើយបើជ្រូកស៊ីច្រើនវាជាការចង្អុលបង្ហាញពីសុខភាពរបស់វា។ ជ្រូកមិនស៊ីចំណីបានន័យថា រីស្ទើនឹងសុខភាព រឺ ចំណីមានបញ្ហា។





ការសង្កេត ដោយយកចិត្តទុកដាក់ នឹងប្រទះឃើញជ្រូកមួយមិនស៊ីចំណី បើទោះបីពួកវាចូលក្នុងហ្វូងនៅពេលដាក់ចំណីក៏ដោយ ។



នៅកសិដ្ឋានធំៗពេលខ្លះ ប្រើចំណីផលិតផ្ទាល់ខ្លួនរបស់គេ ។ ប្រសិនបើគ្រប់គ្រងបានល្អ ពួកគេអាចសន្សំ កំលាំង ហើយជ្រូកបានស៊ីចំណីធ្វើថ្មីៗ រាល់ពេល ។



គុណវិបត្តិមួយដ៏សំខាន់នៃការផលិត ចំណីខ្លួនឯងនោះ គឺថាចំណីទាំងនេះ ទាក់ទាញឱ្យមានកណ្តុរ ។



យុទ្ធសាស្ត្រដើម្បីរៀបចំទីផ្សារឱ្យបានល្អ ទាមទារឱ្យជ្រូកមានទំងន់ស្មើៗគ្នា ហើយមាន ជ្រូកលក់នៅពេល តំលៃទីផ្សារបាន តំលៃសមស្រប ។ អ្នកចិញ្ចឹមគួរតែដឹងនៅពេលណាដែល



សាច់ជ្រូកមានតំរូវការច្រើន ហើយមាន តំលៃខ្ពស់។

ប្រសិនបើចាំបាច់ រៀបចំឡើងវិញ កូនជ្រូកតូចៗជាក្រុមដែលពួកវាលូតលាស់ និងលក់ជាមួយគ្នា។ ប៉ុន្តែត្រូវប្រុងប្រយ័ត្ន ការដាក់បញ្ចូលគ្នាទៅក្នុងក្រុមថ្មីអាច បណ្តាលឱ្យវាខាំគ្នា។ ការលូតលាស់របស់វាអាច ថយចុះក្នុងរយៈពេល ៤-៥ថ្ងៃ ដោយសារ ពួកវារៀបចំខ្លួនឡើងវិញទៅនឹង ស្ថានភាពក្រុមថ្មីរបស់វា។





គន្លឹះដើម្បីទទួលបានប្រាក់ចំណេញពីការ លក់ជ្រូកអាស្រ័យ ទៅលើការបែងចែកក្រុមកូនជ្រូក មិនសូវបានល្អ នៅអាយុ ៨-១២អាទិត្យ ហើយនឹងការបែងចែកជ្រូកសាច់ដែលមានទំងន់ និងអាយុស្មើគ្នា នៅក្នុងក្រុមដូចគ្នា។

**១០.៣ គារាងសំរាប់ជ្រូកជំនង់ និងជ្រូកសាច់**

១. ស្នូកជ្រូកតូចពេកមិនស្របតាមចំនួនជ្រូក។ បញ្ហានេះធ្វើឱ្យជ្រូកខាំគ្នានៅកន្លែងស្នូកចំណី

២. ជ្រូកច្រើនពេកនៅក្នុងទ្រុងតូច នាំមកនូវការលូតលាស់យឺត និងការលូតលាស់មិនស្មើគ្នា ហើយពេលខ្លះមានបញ្ហាផ្សេងៗដូចជា ការខាំកន្ទុយគ្នា។

៣. ការផ្តល់ទឹកមិនគ្រប់គ្រាន់ ជាទូទៅដោយសារនៅក្នុងទ្រុងមួយមានក្បាលបឺតចំនួនតិចពេក។ គ្រប់ទ្រុងទាំងអស់ត្រូវតែមានក្បាលបឺតយ៉ាងហោចណាស់២ ការពារក្នុងករណីក្បាលបឺតមួយទៀតខូច។

៤. ក្បាលបឺតដាក់មិនបានត្រឹមត្រូវ នាំឱ្យជ្រូកពិបាកផឹកទឹក

៥. ជ្រូកឈឺត្រូវព្យាបាលឱ្យទាន់ពេលវេលា រឺ វានៅក្នុងលក្ខខណ្ឌកាន់តែយាប់យឺនទៅៗយ៉ាងឆាប់រហ័ស និងវាអាចងាប់

៦. ផ្ទៃរបន្ទះឈើ រឺបន្ទះដែកមិនល្អ រឺក៏បន្ទះដែកមានចន្លោះធំពេកនឹងបណ្តាលប្រអប់ជើង និងជើងបាក់។

៧. ជ្រូកដែលយើងបានឃើញវាខាំគ្នា និង ដៃគូររបួសរបស់វាត្រូវប្រញាប់លក់ដើម្បីកុំឱ្យខាតច្រើន

៨. ទំងន់ជ្រូកមិនស្មើគ្នាដាក់នៅក្នុងទ្រុងតែមួយជាសញ្ញាណគ្រោះអាសន្នមួយ ។ តើវាមានការដណ្ដើមទីធ្លា ចំណី និងទឹកគ្នាផឹកឬ? មូលហេតុទាំងនេះត្រូវតែរកឱ្យឃើញ និងកែលំអរឱ្យបានឆាប់រហ័ស ។

៩. ទ្រុងកខ្វក់ជាពិសេសនៅកន្លែងផ្ដល់ចំណី បញ្ជាក់ថាជ្រូកនៅមិនបានសុខស្រួល ។ មូលហេតុនេះត្រូវរកឱ្យឃើញ និងកែលំអ ថាតើវាក្ដៅពេក? ឬមានខ្យល់ខ្លាំងពេក? តើកំរាលមិនស្មើគ្នា?
តើកំរាលវាចោទពេក? រឺក៏ជ្រូកឈឺ ?

១០.ការបែងចែករនាំង (ខ្សែពទ្ធ័របង)រឹងមាំពេកនៃទ្រុងមិនអាចជួយឱ្យជ្រូកដឹងថាពីកន្លែងណាត្រូវដេក និងដឹងពីទីកន្លែងណាដែលត្រូវវាជុះអាចម៏នោះទេ ។ ចូរអ្នកធ្វើកំរាលឥតមានប្រហោងកន្លែងសំរាប់ជ្រូកដេក ។


1
2
3
4
5
6
7
8
9
10



# ជំពូក ១១: ការត្រួតពិនិត្យ និងកត់ត្រាផលិតផល

## ១១.១ ការថែរក្សាការកត់ត្រា



អ្នកចិញ្ចឹមត្រូវការថែរក្សាការកត់ត្រាផលិតផលរបស់គាត់ដើម្បីតាមដានការរីក លូតលាស់របស់ជ្រូក( ការផ្លាស់ប្តូរចំណី) ការបន្តពូជរបស់ជ្រូកមេ( ចំនួនកូនជ្រូកក្នុងមួយសំបុកក្នុងមួយឆ្នាំ) ចាក់ថ្នាំការពារ និងព្យាបាលទាន់ពេល គិតពីប្រាក់ចំណេញ( ប្រាក់ចំណូលដកប្រាក់ចំណាយ) ។ល ។



ការកំណត់អត្តសញ្ញាណរបស់ជ្រូកបា និងជ្រូកមេបង្កាត់ពូជនិមួយៗគឺមានសារៈសំខាន់ណាស់ តាមរយៈការកាត់ស្លឹកត្រចៀក ការសាក់លើត្រចៀក រឺតាមរយៈការចុះស្លឹកត្រចៀក ។





ការកត់ត្រានៅក្នុងកសិដ្ឋានត្រូវបានគេរក្សាទុកនៅជាប់នឹងទ្រុង ដូច្នេះព័ត៌មានដែលទាក់ទង គឺគេអាច ដឹងបាននៅពេលគេត្រួតពិនិត្យ មើលជ្រូក ។ ជាការសំខាន់នោះគឺកាតផលិតភាព របស់មេជ្រូក ដើម្បីពិនិត្យមើលថាមេជ្រូកនិមួយៗ សំរេចបានផលគួរជាទីពេញចិត្ត ។

| កាតផលិតភាពរបស់ជ្រូកមេ | | | | | | | |
|---|---|---|---|---|---|---|---|
| ចំនួនមេជ្រូក | | ថ្ងៃខែកើត | | បា | | មេ | |
| ចំនួនកូនក្នុង១សំបុក | ថ្ងៃខែដាក់បា | ចំនួនជ្រូកបា | ថ្ងៃខែកើត | ចំនួនកូនជ្រូករស់ | ចំនួនកូនជ្រូកងាប់ | ចំនួនជ្រូកផ្តាច់ដោះ | ថ្ងៃផ្តាច់ដោះ |
| ១ | | | | | | | |
| ២ | | | | | | | |
| ៣ | | | | | | | |
| ៤ | | | | | | | |
| ៥ | | | | | | | |
| ៦ | | | | | | | |

តារាងសកម្មភាពប្រចាំអាទិត្យ គួរតែថែរក្សាទុកផងដែរ ត្រួតពិនិត្យមើលគ្រប់ដំណាក់កាល នៃផលិតកម្មទាំងអស់ ។ តារាងនេះត្រូវការកត់ត្រាជាពិសេសចំនួនជ្រូកដែលមានអាយុខុសៗគ្នា ផលិតភាពរបស់ពូជជ្រូក និងការប្រើប្រាស់ចំណី ។

តារាងសកម្មភាពប្រចាំអាទិត្យ

- ការដាក់ឈ្មោល
- ការផ្លាស់ប្តូរ
- ការកើតកូន
- ចំនួនងាប់
- ការផ្តាច់ដោះ
- ការលក់
- ការចែកចាយចំណី
- ការណែនាំ
- ការជំរុះចោល



### ១១.២ ទិសដៅផលិតកម្ម



ក្នុងការបង្កាត់ពូជ មេជ្រូកនិមួយៗត្រូវតែផលិតកូនឱ្យបានច្រើនតាមតែអាចធ្វើទៅបានក្នុងមួយឆ្នាំៗ។ ប្រការទាំងនេះទាក់ទងទៅនឹង៣ចំនុចៈ

- ចំនួនសំបុកកើតកូនក្នុងមួយឆ្នាំ
- ចំនួនកូនជ្រូកកើតក្នុងមួយសំបុក
- ចំនួនកូនជ្រូកផ្តាច់ដោះក្នុងមួយសំបុក

នៅក្នុងកសិដ្ឋានចិញ្ចឹមជ្រូកមួយ ចំនួនសំបុកក្នុងមួយឆ្នាំគឺទាក់ទងទៅនឹងៈ

- អាយុផ្តាច់ដោះកូនជ្រូកជាមធ្យម
- ចំនួនចន្លោះថ្ងៃផ្តាច់ដោះ និងថ្ងៃដាក់បា
- ចំនួនមេជ្រូកដែលរកឈ្មោលម្តងទៀតក្រោយពី ៣អាទិត្យ ៦អាទិត្យ រឺ៩អាទិត្យ
- ចំនួនមេជ្រូកមិនមានផើម រឺមេជ្រូករលូតកូន
- អត្រាមេជ្រូកស្លាប់ និងមេជ្រូកជំរុះចោល



កត្តាសំខាន់មួយដែលជះឥទ្ធិពលលើកូនជ្រូកផ្តាច់ដោះក្នុងមួយសំបុកគឺ ចំនួនកូនជ្រូកនៅរស់ដែលមានសុខភាពល្អក្រោយពេលកើត។

នៅក្នុងហ្វូងជ្រូកយកសាច់ ជ្រូកត្រូវតែធំលូតលាស់លឿន និងឱ្យផលល្អដើម្បីឈានទៅរកទំងន់ដែលទីផ្សារត្រូវការ។ លទ្ធផលនេះគឺទាក់ទងទៅនឹង៤ ចំនុចៈ

១. អត្រាស្លាប់តិចបំផុត　　　២. អត្រាលូតលាស់លឿន

៣. ថ្លៃចំណីអស់តិច　　　៤. ការស៊ីចំណីបានច្រើន



វាមាន៥ លំដាប់សំខាន់ៗសំរាប់អត្រាការលូតលាស់បានល្អ និងជាសំណាកនៃជ្រូក១ក្បាល គួរត្រួតពិនិត្យទំងន់ នូវគ្រប់ដំណាក់កាលទាំងនេះ :

| ដំណាកកាល | លំដាប់ថ្នាក់( ពូជជ្រូកពណិស) |
|---|---|
| ១. ពេលកើត | ១,២គ.ក-១,៥គ.ក |
| ២. អាយុ៤អាទិត្យ | ៦,០គ.ក- ៧,០គ.ក |
| ៣. អាយុ១២អាទិត្យ | ១៥គ.ក- ២០គ.ក |
| ៤. អាយុ ១៨អាទិត្យ | ៤០គ.ក-៥០គ.ក |
| ៥. អាយុ ២៤អាទិត្យ | ៧០គ.ក- ៨០គ.ក |







អត្រាស្លាប់របស់ជ្រូកកាត់បន្ថយចំនួននៅលក់ ។ អត្រាស្លាប់របស់ជ្រូកត្រូវតែកាត់បន្ថយឱ្យបានតិចបំផុត នៅគ្រប់លំដាប់ថ្នាក់ទាំងអស់ ពោលគឺ មិនមែនតែក្នុងកំឡុងកូនជ្រូកបៅដោះនោះទេ។

| ដំណាក់កាល | អត្រាខ្ពស់បំផុតអាចទទួលយកបា |
|---|---|
| ១. កូនជ្រូកបៅដោះ | ១២ភាគរយ |
| ២. កូនជ្រូកផ្តាច់ដោះ | ៣ភាគរយ |
| ៣. ជ្រូកសាច់ | ២ភាគរយ |

ជ្រូកស៊ីចំណីអាស្រ័យលើកត្តាជាច្រើន។ អ្នកត្រូវដឹងថា កាកសំណល់ពីចំណីអាហារគឺជាជំនួយមួយយ៉ាងសំខាន់ ដើម្បីឱ្យជ្រូកស៊ីចំណីបានច្រើន និង ចំណីនោះមានតំលៃខ្ពស់។



# ជំពូក ១២: ការត្រួតពិនិត្យសុខភាពជ្រូក

## ១២.១ ការធ្វើអនាម័យ និងវិធានការការពារសុខភាពសត្វ





វិធានការដែលអនុវត្តដដែលៗប្រចាំថ្ងៃដើម្បីការពារជំងឺ គឺតាមរយៈការរៀបចំកសិដ្ឋានបានរៀបរយ និង មានអនាម័យល្អ ។ នេះគឺមានន័យថា លាមកជ្រូកត្រូវសំអាតចេញពីទ្រុងជារៀងរាល់ថ្ងៃ (រឺឱ្យវាធ្លាក់តាមកំរាលបន្ទះដែក) ។ រណ្តៅលាមក រឺគំនរកំប៉ុស្តិ៍ គួរតែផ្លាស់ប្តូរពីមួយទៅមួយ និង ដាក់វានៅក្នុងសួនបន្លែ រឺនៅទីវាលផ្តល់ជាជីដល់រុក្ខជាតិ ។





ការបោសសំអាតបានម៉ត់ចត់ជាប្រចាំនៅក្នុងហ្វូងជ្រូកជួយកាត់បន្ថយគ្រោះថ្នាក់នៃការផ្ទុះជំងឺ ។

ការសំអាតបានល្អជាមួយថ្នាំសំលាប់ មេរោគ (ដូចជា ហ្វម៉ាល់ដេអ៊ីត) លើគ្រប់ទ្រុងមេកើត កូន និងទ្រុងថែទាំកូនជ្រូក មុនពេលដាក់មេជ្រូកថ្មី រឺកូនជ្រូកដាក់បញ្ចូល ។



ចូរអ្នកស្លៀកពាក់ខោអាវសំរាប់ការងារដែលគេតំរូវឱ្យពាក់តែក្នុងក្រុមជ្រូកនោះប៉ុណ្ណោះ ។ មិនគួរស្លៀកពាក់ខោអាវទាំងនេះទៅមើលជ្រូករបស់កសិករផ្សេងទៀតឡើយ ។ សំលៀកបំពាក់ និងស្បែកជើងអាចនាំជំងឺឆ្លងបាន ។



ចូរអ្នកសំលាប់មេរោគលើស្បែក រឺស្បែកជើងកវែងរបស់ជាមុនសិន មុនពេលចូលក្នុងទ្រុងជ្រូក ។ ចូរអ្នកប្រើទ្រនាប់កំរាល រឺសំលៀកពាក់ដែលជប់ទឹកដោយដាក់ជាមួយសូលុយស្យុង កំបោរនៅមុខ ផ្លូវចូលទ្រុងជ្រូក ។ ប្រើជំរើសមួយ យកធុងមានដាក់ទឹកលាយ



ជាមួយសូលុយស្យុងហ្វម៉ាលីនមុនពេលដើរ ចូលក្នុងទ្រុងជ្រូក ។



អ្នកចូលទស្សនៈកិច្ចត្រូវអង្កេតមើលដោយម៉ដ្ឋចត់ដើម្បីកាត់បន្ថយការនាំជំងឺចូលឱ្យបានតិចបំផុត ។

ចូរអ្នកឱ្យអ្នកចូលទស្សនាចេញឆ្ងាយពីទ្រុងជ្រូករបស់អ្នកតាមដែលអ្នកអាចធ្វើទៅបាន ។

ការរៀបចំធ្វើអនាម័យបានល្អកាត់បន្ថយការរីករាលដាលនៃជំងឺឆ្លង ។



សំរាប់ជ្រូកយកសាច់ថែទាំឱ្យបានម៉ដ្ឋចត់បំបែកទៅតាមអាយុរបស់វា ។ ដូចនេះជ្រូកដែលបានកើតនៅក្នុងអាទិត្យជាមួយគ្នាត្រូវរក្សាទុកពពួកវាជាមួយគ្នា ។ ការធ្វើបែបនេះនឹងកាត់បន្ថយការឆ្លងជំងឺពីជ្រូកចាស់មកជ្រូកក្មេង ។



ប្រសិនបើចាំបាច់បំបែកកូនជ្រូកតូច រឺខ្សោយជាងគេចេញពីកូនជ្រូកដែលឈ្មះ ហើយធំជាង ។ ការអនុវត្តបែបនេះ ការពារកូនជ្រូកដែលខ្សោយជាងកាន់តែខ្សោយទៅៗ
នៅពេលដែលពពួកវាស៊ីចំណីមិនបានគ្រប់គ្រាន់ ។

## ១២.២ គោលការណ៍ការពារជំងឺ

ការការពារជំងឺមាន ៣ប្រភេទ:

១. សកម្មភាពការពារទូទៅ

- សំអាត និងបាញ់ថ្នាំសំលាប់មេរោគជាប្រចាំ ហើយផ្តល់ទឹក និងចំណីដែលមានគុណភាពឱ្យបានគ្រប់គ្រាន់

- លុបបំបាត់ប្រភពបង្កើតមេរោគ ដូចជា លាមក ទឹកនោម កំរាលរបស់ជ្រូកឈឺ និងជ្រូកងាប់



- ត្រួតពិនិត្យចរាចរសត្វចេញ និងចូលក្នុងភូមិ

២.ការការពារជំងឺដោយការដាក់ដោយឡែកពីគេ

ចូរអ្នកអានជំពូកស្តីពី " ការដាក់បញ្ចូលជ្រូកថ្មីទៅក្នុងកសិដ្ឋាន"

៣. ការការពារជំងឺដោយការចាក់ថ្នាំការពារ

ព័តិមានពិស្តារសូមអ្នកអានជំពូកស្តីពី "ជំងឺជ្រូក"

ការចាក់ថ្នាំការពារតាមសាច់ដុំ គឺនៅក្បែរក រឺភ្លៅខាងក្រោយ ។ ជ្រូកធំត្រូវការបង្ខាំងកុំឱ្យកព្រោល ។

*កន្លែងចាក់សំរាប់ការចាក់ថ្នាំការពារ*



## ១២.៣ ការដាក់បញ្ចូលជ្រូកថ្មីចូលក្នុងកសិដ្ឋាន



ការដាក់បញ្ចូលជ្រូកថ្មីទៅក្នុងកសិដ្ឋានជាសញ្ញាបង្ហាញនូវសក្តានុពលនៃការគំរាមកំហែងមួយ ដល់សុខភាពសត្វក្នុងហ្វូង ។

យើងត្រូវប្រុងប្រយត្ន័នៅពេលដាក់ជ្រូកថ្មីចូល អាចឆ្លងជំងឺដែលអាចបង្កឱ្យមានបញ្ហានៅក្នុងហ្វូងជ្រូករបស់យើង ។

ការដាក់បញ្ចូលពពួកជ្រូកថ្មីត្រូវការបង្ខាំងទុករយៈពេល ២-៣អាទិត្យនៅក្នុងទ្រុងដោយដាក់ដាច់ពីជ្រូកដទៃទៀតនៅក្នុងកសិដ្ឋាន ។ នៅក្នុងកំឡុងពេលនេះវានឹងអាចលេចឡើង ប្រសិនបើជ្រូកថ្មីមានជំងឺ រឺអត់ ។ ចូរអ្នកផ្តល់ទឹក និងចំណីដែលមានគុណភាពឱ្យបានគ្រប់គ្រាន់ ។







ក្រោយពេលបង្ខាំងទុក ជ្រូកថ្មីត្រូវបានគេបញ្ចូលដាក់ក្នុងហ្វូង ។ គួរតែទុកឱ្យពពួកដែលចូល ថ្មី សំរបខ្លួនក្នុងហ្វូងទៅវិញទៅមក និងបរិយាកាសថ្មីឱ្យបានរយៈពេលប្រហែល ៣-៤អាទិត្យសិនមុនពេល ពពួកវាត្រូវបានគេយកបង្កាត់ ។

ដូច្នោះ យើងត្រូវការមើលដោយប្រុងប្រយ័ត្នក្នុងការបញ្ចូលជ្រូកថ្មី នៅពេលដែលពពួកវាត្រូវបានគេទិញពីកន្លែងបង្ខាំងទុកទៅដាក់ក្នុងទ្រុង។ ក្នុងកំឡុងពេល ៣-៤អាទិត្យនេះការសំរបខ្លួន ពពួកនឹងបង្ហាញឱ្យយើងឃើញចំពោះហ្វូងជ្រូកចាស់ ដើម្បីឱ្យភាពស៊ាំអាចទទួលរស់នៅបាន។





បន្ថែមពីនេះទៀត កម្មវិធីចាក់ថ្នាំការពារ និង ទំលាក់ព្រូនដែលគេចាក់ក្នុងហ្វូងជ្រូក គួរតែប្រើ ចំពោះជ្រូកទើបដាក់ថ្មីផងដែរ។



ជ្រូកញីដែលទើបយកមកថ្មី មិនគួរបង្កាត់ភ្លាមៗទេ។ ជ្រូកមេក្រមុំគួរដាក់បាលើកដំបូងយ៉ាងហោច ណាស់អាយុ ៦ខែ ( ទំងន់លើសពី ៨០គ.កសំរាប់ពូជជ្រូកពណិស) ។ ការបង្កាត់មុនអាយុ នឹងកាត់បន្ថយការ បង្កកំណើតចំណែកឯមេជ្រូកប្រដាប់បន្តពូជនឹងមិនមានពេលលូតលាស់បានល្អ។



ការបង្កាត់លឿនពេកធ្វើឱ្យជ្រូកមេក្មេងអស់លទ្ធភាពបន្តពូជឆាប់រហ័ស ហើយការបន្តពូជរបស់មិនបានល្អ។

# ជំពូក ១៣: ជំងឺជ្រូក

## ១៣.១ ចំណាត់ថ្នាក់ជំងឺប៉េស្តជ្រូក

ជំងឺប៉េស្តបង្កឡើងដោយពីវីរុស ។ វាផ្ទុះឡើង ហើយអាចបណ្ដាលឱ្យជ្រូកជាច្រើនក្បាលងាប់ ។ មេរោគនេះអាចឆ្លងតាមរយៈសត្វឈឺ និងសាច់សត្វដែលមានផ្ទុកមេរោគ ។ មេរោគនេះអាចរស់ក្នុងបរិយាកាស ៣-៤ថ្ងៃ ហើយគេអាចសំលាប់វាបានតាមរយៈការសំលាប់មេរោគ ។

១. វីរុសឆ្លងពីជ្រូកឈឺ ទៅជ្រូកជា

២. ជ្រូកមេដែលមានជំងឺអាចរលូតកូន រឺកូនជ្រូក ២-៣ក្បាលប៉ុណ្ណោះដែលរស់នៅពេលកើត

៣. វីរុសឆ្លងចូល និង បង្កើនចំនួននៅលើកូនជ្រូក

៤. កូនជ្រូកគ្រុនក្ដៅ និងមិនស៊ីចំណី

៥. កូនជ្រូកដេកផ្ដុំគ្នា

៦. ជ្រូកក្អៀន ហើយរាគ

៧. ជ្រូកមានស្នាមក្រហមតូចៗនៅលើស្បែក ហើយជ្រូកមានអាការៈខុសធម្មតា

៨. ជ្រូកងាប់




**<u>ការព្យាបាលៈ</u>** មិនថ្នាំសំលាប់វីរុសទេ ( មិនមានថ្នាំព្យាបាលទេ) ។ ជ្រូកឈឺនឹងងាប់ ។

**<u>ការការពារៈ</u>**

- ការពារជំងឺ ជ្រូកទាំងអស់ត្រូវចាក់ថ្នាំការពារដោយវ៉ាក់សាំងប៉េស្ត
- ក្នុងកំឡុងពេលផ្ទុះជំងឺ ជ្រូកងាប់គួរតែកប់ដើម្បីកាត់បន្ថយការឆ្លងជំងឺ ហើយជ្រូកជាគួរថែរក្សាទុកឱ្យឆ្ងាយពីជ្រូកឈឺ ។
- កុំដឹកជញ្ជូនជ្រូកឈឺ រឺសាច់ជ្រូកដែលសង្ស័យថាមានផ្ទុកជំងឺ ។



## ១៣.២ ជំងឺអុតក្តាម

ជំងឺអុតក្តាមបង្កឡើងដោយវីរុស។ ការផ្ទុះជំងឺអុតក្តាមកើតឡើងលើគោ ក្របី ជ្រូក ចៀម និងពពែ។ ចំពោះជ្រូកស្លាកស្នាមកើតនៅលើ ជើង ច្រមុះ និងក្រពេញដោះ។ ស្លាកស្នាមនៅលើជើងខ្លាំងជាងនៅលើច្រមុះ។ ដំណើរឈឺចាប់ ហើយជ្រូកចង់ផ្តេកខ្លួន។ ចំពោះមេជ្រូកមិនឱ្យកូនជ្រូកបៅដោះ ពីព្រោះមេជ្រូកឈឺនៅលើ និងជុំវិញចុងដោះ។

ជ្រូកផ្តេកខ្លួន មិនស៊ីចំណី និងមានកំដៅឡើងខ្ពស់






១. នៅលើច្រមុះពងដោរតូចៗ វិវឌ្ឍន៍ទៅដំបៅ

២. ពងដោរ និងដំបៅកើតជុំវិញ និងចន្លោះក្រចកជើង។ក្រចកអាចសន្លក

៣. ពងដោរតូចៗ និងដំបៅកើត នៅលើក្រពេញដោះ និងចុងដោះ



**<u>ការព្យាបាល:</u>** មិនមានថ្នាំណាដែលអាចសំលាប់វីរុសបានទេ ។

លាងសំអាតពងដោរបែកជាមួយថ្នាំដូចជា អ៊ីយូឌីន។ ថ្នាំអង់ទិប៊ីយោទិចត្រូវបានគេប្រើនៅពេលដែលបាក់តេរីបានចូលទៅក្នុងខ្លួនសត្វតាមរយៈដំបៅដែលបណ្តាលឱ្យដំបៅក្រជាសះស្បើយ។

**<u>ការការពារ:</u>**

- ការចាក់ថ្នាំការពារជំងឺដោយវ៉ាក់សាំងអុតក្តាមនឹងអាចការពារជំងឺនេះ។
- នៅពេលមានជំងឺផ្ទុះឡើង ការធ្វើចរាចារសត្វគួរតែបញ្ឈប់ដើម្បីកុំឱ្យសត្វជាប៉ះពាល់ជាមួយសត្វជា។



## ១៣.៣ ជំងឺព្រូនមូល

វាំនមានប្រភេទព្រូនជាច្រើនដែលរស់នៅក្នុងក្រពេះ ពោះវៀន រឺថ្លើមរបស់ជ្រូក។ វាបណ្តាលឱ្យជ្រូកមានជំងឺ ស្រកទំងន់ និងការលូតលាស់យឺត។ សំខាន់បំផុតគឺប្រភេទព្រូនធំពណិស ( អាស្ការីស ស្យូម) ។ ព្រូននេះរស់នៅក្នុងពោះវៀនតូច ហើយភាគច្រើនកើតលើជ្រូកតូចៗអាយុរវាងពី ២-៤ខែ។



មានប្រភេទព្រូនជាច្រើនអាចកើតមាននៅលើជ្រូកតូចៗ។ ព្រូននេះអាចរស់នៅក្នុងពោះវៀន ក្រពះ និងថ្លើម។

មានប្រភេទព្រូនជាច្រើនទៀត អាចកើតមាននៅលើជ្រូកមេ ជាពិសេសនៅពេលកូនជ្រូកបៅដោះ។ ជាទូទៅព្រូនទាំងនេះរស់នៅក្នុងពោះវៀន និង ក្រពះ។



| **ការព្យាបាលៈ** គួរតែប្រើថ្នាំសំលាប់ប៉ារ៉ាសិតដើម្បីសំលាប់ព្រូន | | |
|---|---|---|
| | ឈ្មោះថ្នាំ | វិធីប្រើ កំរិតប្រើ និងកម្មវិធីចាក់ថ្នាំ |
| ១ | | |
| ២ | | |

**ការការពារៈ**

- ជ្រូកចិញ្ចឹមដាក់ក្នុងទ្រុងស្អាតអាចចាក់ថ្នាំសំលាប់បរាសិតរៀងរាល់ ៣ខែម្តង។
- ប្រសិនជ្រូកចិញ្ចឹមមិនដាក់ទ្រុងស្អាតទេ គួរចាក់ទំលាក់ព្រូនរៀងរាល់ ៤អាទិត្យម្តង។
- ជ្រូកដែលទើបមកដល់គួរចាក់ថ្នាំទំលាក់ព្រូននៅពេលមកដល់ភ្លាមៗ។
- ជ្រូកមេផើម គួរតែចាក់ទំលាក់ព្រូន ៤អាទិត្យមុនពេលកើតកូន។



## ១៣.៤ ជំងឺរាគកូនជ្រូក

ជំងឺនេះអាចបណ្ដាលមកពីពួកមីក្រុបជាច្រើនខុសៗ ទាំងបាក់តេរី និងវីរុស។ ពពួកមីក្រុបទាំងនេះអាចជ្រាតចូលទៅក្នុងជ្រូកជាបាន នៅពេលជ្រូកស៊ីរឺផឹកទឹកដែលមានផ្ទុកលាមកជ្រូកឈឺ ។ ពួកមីក្រុបទាំងនេះទៅរស់នៅក្នុងពោះវៀនតូច រឺពោះវៀនធំ។ ជំងឺរាគភាគច្រើនកើតនៅលើកូនជ្រូកអាយុពី ១អាទិត្យ ទៅ ៣-៤ខែ។

១. មីក្រុបត្រូវបានលេបចូលទៅក្នុងក្រពះដោយកូនជ្រូក

២. កូនជ្រូករាគ

៣.កូនជ្រូកអាចជាពីជំងឺ ប៉ុន្តែពេលខ្លះលូតលាស់យឺត

៤. កូនជ្រូកអាចងាប់ភ្លាមៗដោយមិនមានរោគសញ្ញា រឺក្រោយពេលរាគ




| **ការព្យាបាល:** ការពារការខ្វះជាតិទឹកតាមរយៈការផ្ដល់ទឹកលាយជាមួយអំបិលឡៃមៗជាមួយស្ករ វីតាមីន និងអង់ទិប៊ីយោទិចអាចជួយឱ្យជ្រូកមានកំលាំងផងដែរ។ | | |
|---|---|---|
| | ឈ្មោះថ្នាំ | វិធីប្រើ កំរិតប្រើ និងកម្មវិធីចាក់ថ្នាំ |
| ១ | | |
| ២ | | |

**ការការពារ:**

- ការថែរក្សាជ្រូកនៅក្នុងទ្រុងស្អាត គឺមានសារៈសំខាន់ជាពិសេសសំរាប់ជ្រូកមានកូន
- មេជ្រូកដែលមានកូនគួរតែចិញ្ចឹមបំបែកពីជ្រូកមេចាស់ផ្សេងទៀត រឺជ្រូកសាច់
- ជ្រូកដែលមានសុខភាពល្អគួរតែថែរក្សាឱ្យនៅឆ្ងាយពីជ្រូកឈឺ

## ១៣.៥ ជំងឺកញ្ជ្រិល

កញ្ជ្រិលគឺជាជំងឺឆ្លងដែលបណ្តាលមកពីបាក់តេរី ដែលភាគច្រើនបង្កលើកូនជ្រូក ( វាអាចកើតលើមនុស្សផងដែរ) ។ ជ្រូកលេចចេញរោគសញ្ញា បន្ទះក្រហមរាងដូចពេជ្រលើស្បែក កណ្តាលឆ្អឹងខ្នង សន្លាក់ និងបេះដូង អាចរាគត្បាត ហើយមេរោគនេះអាចសំលាប់ជ្រូកបាន ។




១. ជ្រូកជាឆ្លងជំងឺតាមរយៈជ្រូកឈឺ ជ្រូកអាចស្លាប់ភ្លាមៗដោយមិនមានរោគសញ្ញា

២.ជ្រូកផ្ទុកជំងឺមានកំដៅឡើង និងមានស្លាកស្នាមនៅលើស្បែក

៣. បាក់តេរីរាតត្បាតលើស្បែក បេះដូង និងសន្លាក់ ។ ជ្រូកហេវហត់ និងមិនចង់ដើរ

៤. ជ្រូកអាចរស់ ហើយក្លាយជាអ្នកចំលងជំងឺ រឺក៏ស្លាប់ក្រោយពេលមានបញ្ហាបេះដូង

| **ការព្យាបាល:** គួរតែប្រើអង់ទិប៊ីយោទិចដើម្បីព្យាបាលជំងឺនេះ | | |
|---|---|---|
| | ឈ្មោះថ្នាំ | វិធីប្រើ កំរិតប្រើ និងកម្មវិធីចាក់ថ្នាំ |
| ១ | | |
| ២ | | |

**ការព្យាបាល:**

- ជ្រូកគួរតែចិញ្ចឹមដាក់នៅក្នុងទ្រុងស្អាត
- ក្នុងកំឡុងពេលផ្ទុះជំងឺ ជ្រូកដែលមានសុខភាពល្អត្រូវដាក់ឱ្យឆ្ងាយពីជ្រូកឈឺ ។



## ១៣.៦ ជំងឺអង្គែរ

ជំងឺនេះបង្កឡើងដោយចៃដែលរស់នៅលើស្បែក។  ពពួកចៃតូចណាស់មិនអាចមើលឃើញដោយភ្នែកទទេបានទេ។ ជ្រូករមាស់ និងអេះជាញឹកញាប់ដោយខ្លួនវា។ កន្លែងស្បែកដែលរមាស់ឡើងពណ៌ក្រហម ស្បែកក្រៀមហើយក្រាស់ ។ ជ្រូកមិនសូវស៊ីចំណី ហើយលូតលាស់យឺត។



ការឆ្លងជំងឺកើតឡើងដោយសារការប៉ះពាល់ជាមួយសត្វឈឺ។

ចៃរស់នៅជុំវិញស្បែកផ្នែក ត្រចៀក ច្រមុះ ជើង និងដងខ្លួន។
ជ្រូកអេះ រឺត្រដុសញឹកញាប់ ហើយនៅលើស្បែកដែលមានចៃពណ៌ក្រហម ក្រមរក្រៀម និងក្រាស់។
ជ្រូកមិនសូវស៊ីចំណី និងលូតលាស់យឺត។

| **ការព្យាបាល:** គួរតែប្រើថ្នាំសំលាប់ប៉ារ៉ាសិតដើម្បីសំលាប់ចៃ | | |
|---|---|---|
| | ឈ្មោះថ្នាំ | វិធីប្រើ កំរិតប្រើ និងកម្មវិធីចាក់ថ្នាំ |
| ១ | អ៊ីវ៉ូមិច | ចាក់ក្រោមស្បែក ១ម.លសំរាប់ជ្រូកទំងន់៣៣គ.ក |
| ២ | | |

**ការព្យាបាល:**

- ជ្រូកឈឺត្រូវប្រញាប់ព្យាបាល ហើយដាក់វាដាច់ឱ្យឆ្ងាយពីជ្រូកជា
- ជ្រូកមេដើមគួរចាក់ឱ្យបាន៤អាទិត្យមុនពេលកើតដើម្បីការពារអង្គែរ
- ជ្រូកនាំចូលមកថ្មីត្រូវព្យាបាលភ្លាមនៅពេលមកដល់



## ១៣.៧ ជំងឺតេញ៉ា

ជំងឺតេញ៉ា គឺបណ្តាលមកពីព្រូនសំប៉ែតដែលរស់នៅលើខ្លួនមនុស្ស ។ ព្រូនសំប៉ែតនេះផលិតពងដែលត្រូវបានឆ្លងកាត់តាមរយៈលាមក ។ នៅពេលដែលជ្រូកស៊ីលាមកមនុស្ស ពងតេញ៉ាទាំងនោះញាស់ក្លាយទៅជាកូនដង្កូវ ហើយវាផ្លាស់ទីទៅនៅក្នុងសាច់ដុំកន្លែងណាដែលវាអាចបង្កជាគីសបាន ។ នៅពេលដែលមនុស្សបរិភោគសាច់ជ្រូកដែលមានផ្ទុកគីស ហើយគីសនេះលូតលាស់ទៅជាតេញ៉ាពេញវ័យនៅក្នុងពោះវៀនមនុស្ស ។
មនុស្សទទួលជំងឺដោយសារ ព្រូននេះ ។ គ្រោះថ្នាក់ដ៏ធំនោះ នៅពេលដែលមនុស្សបានលេបចូលពងតេញ៉ាដោយផ្ទាល់ទៅក្នុង ខ្លួន ហើយគីសនេះអាច លូតលាស់នៅក្នុងខួរក្បាលដែលបណ្តាលឱ្យកើតជំងឺសរសៃប្រសាទ ។




១. តេញ៉ាពេញវ័យរស់នៅក្នុងពោះវៀនមនុស្ស និងផលិតពង

២. ជ្រូកស៊ីដោយពងតេញ៉ានៅក្នុងលាមកមនុស្ស

៣. គីសលូតលាស់នៅក្នុងសាច់ដុំរបស់ជ្រូក

៤. នៅពេលមនុស្សហូបសាច់ជ្រូកដែលមានគីសចំអិនមិនបានឆ្អិនល្អ តេញ៉ាអាចលូតលាស់នៅក្នុងពោះ វៀន ។

មនុស្សអាចឆ្លងជំងឺនេះបានតាមរយៈការហូបចុកដែលមានពងតេញ៉ាដោយផ្ទាល់ រឺក៏តាមចំណីអាហារ ដែលមានផ្ទុកពងតេញ៉ា ។ បញ្ហានេះកើតឡើងនៅពេលចំណីនោះត្រូវបានប៉ះពាល់ដោយមនុស្សដែលមានផ្ទុកតេញ៉ា ហើយអ្នកទាំងនោះមិនបានលាងដៃមុនពេលចាប់កាន់ចំណីអាហារ ។ នៅពេលមនុស្សបរិភោគដោយពងតេញ៉ា គឺអាចលូតលាស់ទៅផ្នែកផ្សេងៗនៃសារពាង្គកាយ ដូចជាខួរក្បាលជាដើម ។ ប្រសិនបើគីសលូតលាស់នៅក្នុងខួរក្បាល ពយកគេអាចបណ្តាលឱ្យកើតជំងឺសរសៃប្រសាទ ។

**<u>ការព្យាបាលលើជ្រូក:</u>** មិនមានថ្នាំសំលាប់តេញ៉ាទេ និងគីសនៅសាច់ដុំរបស់ជ្រូកទេ ។

**<u>ការព្យាបាលលើមនុស្ស:</u>** ប្រើថ្នាំសំលាប់ទំលាក់ប៉ារ៉ាសិតធម្មតាដែលអាចរកបានសំរាប់មនុស្សអាចសំលាប់តេញ៉ាពេញវ័យបាន ។

**ការការពារៈ**

- ការពារជ្រូកដែលមានគីសនៅក្នុងសាច់ដុំ ជ្រូកត្រូវតែថែរក្សាវាកុំឱ្យស៊ីលាមកមនុស្ស។ មនុស្សគួរប្រើបង្គន់អនាម័យ និងជ្រូកគួរតែដាក់នៅក្នុងទ្រុង។

- ការពារកុំឱ្យមនុស្សបរិភោគគីសចេញពីសាច់ជ្រូក សាច់គួរតែចំអិនឱ្យបានឆ្អិនល្អមុនពេលបរិភោគដើម្បីសំលាប់គិស។

- ការពារមនុស្សមិនឱ្យបរិភោគពងតេញ៉ា យើងគួរតែលាងដៃក្រោយពេលចេញពីបង្គន់ និងមុនពេលចាប់កាន់ចំណីអាហារ។

**១. ពូជជ្រូក**

ម៉ុយឡាតប្រភេទ ១



ម៉ុយឡាតប្រភេទ ២



ម៉ុយឡាតប្រភេទ ៣



ឡាយវ៉ាយ



ឡែនដ្រាស



ឌុយរ៉ុក



ស៊ីនជី



ពូជកូនកាត់



## ២. ការជ្រើសរើសពូជ

បាល្អពូជក្នុងស្រុក



បាអន់ពូជក្នុងស្រុក



មេល្អពូជក្នុងស្រុក



មេអន់ពូជក្នុងស្រុក



ការបង្កាត់តាមធម្មជាតិ



ការជ្រើសរើសកូនជ្រូកពីមេល្អ



កូនកាត់ល្អ



ជ្រើសរើសជ្រូកសាច់ធំលឿន



## ៣. ទ្រុង និងកំរាល

ជំរកនៅក្នុងរបងពទ្ធ័ជុំវិញ



ទ្រុងតូច កំរាលបន្ទះឈើ



ទ្រុងធំ កំរាលបន្ទះឈើ



ទ្រុងជ្រូកលើដីផ្ទាល់



ទ្រុងសង់លើស្រះត្រី



កូនជ្រូកបំប៉ននៅលើកំរាលបន្ទះដែក



កំរាលចាក់ស៊ីម៉ង់ត៍



កំរាលធ្វើពីឈើ



## ៤. ស្នូកទឹក និង ស្នូកចំណី

កំរិតដាក់ចំណី



ស្នូកចំណីធ្វើពីឈើ



ស្នូកចំណីធ្វើពីស៊ីម៉ង់តិ៍



ស្នូកស្វ័យប្រវត្តិ



ក្បាលបឺតទឹក



ជ្រូកផឹកទឹក



ការផ្តល់តាមបែបធម្មតា ១



ការផ្តល់តាមបែបធម្មតា ២



## ៥. ចំណីៈ អនុផល និងគ្រាប់ធញ្ញជាតិ

កន្ទក់



ចុងអង្ករ



ដូង



គ្រាប់សណ្តែកសៀង



ពោតក្រហម



ដំឡូងមី



ត្រាវ



ស្លឹកកន្ទំថេត



## ៦. ចំណី: ការធ្វើចំណីតាមបែបធម្មជាតិ

ត្រាវព្រៃ



កំប្លោក



កាកបាយស្រា



ផលិតផលព្រៃ



របបចំណីផលិតនៅផ្ទះ



ការកិនពោតក្រហម (រឹអង្ករ)



ការចំអិនបន្លែ



ចំណីធ្វើនៅផ្ទះចំអិនហើយ



## ៧. ចំណីៈ ការធ្វើចំណីតាមបែបឧស្សាហកម្ម

ចំណីកូនជ្រូកត្រៀមផ្តាច់ដោះ



ចំណីសំរាប់កូនជ្រូកផ្តាច់ដោះ ជ្រូកសាច់



ចំណីសំរាប់មេពូជ



ចំណីរបស់ក្រុមហ៊ុនផ្សេងៗគ្នា



ការផ្សំចំណីដោយខ្លួនឯង



អង្ករ និងពោតក្រហម



ដំឡូងមី និងសណ្តែកសៀង



សារធាតុរ៉ែ និងវីតាមីន



## ៧. ការថែទាំកូនជ្រូក

មេកើតកូន



ជំនួយពេលមេជ្រូកកើតកូន



ការជូតកូនជ្រូក



ការសំលាប់មេរោគលើផ្ចិត



កូនជ្រូកនៅក្នុងប្រអប់ដោយមានអំពូលភ្លើង



ការកាត់ធ្មេញ



ការកាត់ត្រចៀក



ការចាក់ជាតិដែក



## ៩. មេជ្រូកបំបៅកូន និងកូនជ្រូក

មេជ្រូកធើម



ទ្រុងមេកើតកូនបែបទំនើប



ទ្រុងមេកើតកូនក្នុងស្រុក



ទ្រុងមេកើតកូន កូនជ្រូកនៅក្នុងប្រអប់



ទ្រុងជ្រូកក្នុងស្រុក កូនជ្រូកនៅក្នុងប្រអប់



ការបែងចែកមេ និងកូនជ្រូក



ចំណីកូនជ្រូកត្រៀមបំបែកពីមេ



ចំណីបែបឧស្សាហកម្ម



## ១០. ការចាប់ជ្រូក និងការចាក់ថ្នាំការពារ

ការចាប់ជ្រូក



ការត្រួតពិនិត្យជ្រូក



ការចាក់ថ្នាំជ្រូកនៅស្មៀម



ការចាក់ថ្នាំជ្រូកដែលបានចាប់



ការចាក់ថ្នាំសាច់ដុំ



ការចាក់ថ្នាំក្រោមស្បែក



ការចាក់ថ្នាំក្រោមស្បែក



ការសំលាប់មេរោគលើសំភារៈពេទ្យ



## ១១. ជំងឺ និងភាពមិនប្រក្រតី

ជំងឺអុតក្តាម ស្លាកស្នាមនៅលើជើង



ជំងឺអុតក្តាម ស្លាកស្នាមនៅលើច្រមុះ



ជំងឺប៉េស្ត ស្នាមអុជក្រហម



ជំងឺប៉េស្ត សំបុកជ្រូកឈឺ



អង្កែរ



ជ្រូកធ្លាក់ពោះវៀន(អែកនី)



ជំងឺរាគ



ជ្រូកខូចក្រចក



## ១២. ការគ្រៀវកូនជ្រូក

ការសំលាប់មេរោគ



ការវះកាត់



ការយកពងចេញ



ការសំលាប់មេរោគ



## ១៣. ការយកវត្ថុវិភាគទៅមន្ទីរពិសោធន៏

ការយកសំណាកឈាមលើស្លឹកត្រចៀក



ការយកឈាមចូលក្នុងបំពង់



ការកត់ត្រា



ការយកសំណាកលើស្បែក( ប៉ារ៉ាសិត)



## ១៤. កសិដ្ឋានចិញ្ចឹមជ្រូកខ្នាតធំ

ទ្រុងសំរាប់កើតកូន



កូនជ្រូកបំប៉ន



កូនជ្រូកផ្ដាច់ដោះនៅលើកំរាលបន្ទះដែក



ជ្រូកសាច់នៅលើកំរាលស៊ីម៉ង់ត៍



ទ្រុងដាក់មេផើម



ការប្រើប្រាស់សារធាតុវ៉ែ វីតាមីន



ប្រភេទចំណីខុសៗគ្នា



ការដឹកជញ្ជូនជ្រូកសាច់



## ១៥. រូបភាពជ្រូកផ្សេងៗ

ទំងន់កូនជ្រូកផ្តាច់ដោះ



ការដឹកបណ្តើរជ្រូកទៅទីផ្សារ



ការលក់ជ្រូកនៅទីផ្សារ



ជ្រូកសាច់ដឹកទៅសត្តឃាដ



ការវះពិនិត្យសាកសព



ការលក់សាច់ជ្រូកនៅទីផ្សារ



ការដឹកបណ្តើរជ្រូកបា



ការដុសលាងជ្រូកបា



## អាការៈមេជ្រូកមុនពេលកើតកូន

រយៈពេលមេជ្រូកផើមគឺ ១១៤ថ្ងៃ (៣ខែ ៣អាទិត្យ ៣ថ្ងៃ) ។ ថ្ងៃកើតកូន អាចប្រែប្រួល ១-២ថ្ងៃ (អាចរហ័សជាង ឬយឺតជាង១-២ថ្ងៃ) ករណីពិសេសមានមេជ្រូកយឺតរហូតដល់ ៧-១០ថ្ងៃ ។

អាការៈបង្ហាញឡើងពេលមេជ្រូកជិតកើតកូនៈ

- ដើរចុះឡើងយ៉ាងពិបាក
- កន្ទេរាមដោះឡើង តឹងមានពណ៌ក្រហមស្រស់ យកដៃច្បួតមានចេញទឹកដោះ
- មេជ្រូកកាច់សំបុក ឈូសស្នូក ទ្រុង ជុះអាចម៍បន្តបន្ទាប់ លាមករឹងប៉ុនម្រាមដៃ
- ពេលបែកទឹកភ្លោះហូរចេញមក (ទឹករំអិលខាប់អន្ទិល ឬមានអាចម៍ព្រៃកូនជ្រូកហូរចេញមក ជាមួយ)

មេជ្រូកកូនដំបូង (កូនលើកទី១) ច្រើនកើតពិបាកជាងមេជ្រូកចាស់ (កើតកូនលើស ២ដងឡើងទៅ) ។



មេជ្រូករួញកន្ទ្រាក់ជើងក្រោយ និង ប្រឹងយ៉ាងខាំងម្តងៗ គឺពេលនោះដែលកូនជ្រូកត្រូវបានមេជ្រូកប្រឹងជំរុញចេញមកក្រៅ ធម្មតាជាមធ្យម ១០-១៥នាទី ។ បើសិនមេជ្រូកបង្កើតកូនស្រួល គ្រាន់តែក្រោយ ២-៥ម៉ោង គឺបង្កើតកូនរួច និង ២-៣ម៉ោងសុកនឹងធ្លាក់ចេញមកអស់ ។

ក្នុងពេលដែលកូនជ្រូកកើតចេញមកពីពោះ អាចក្បាលកើតចេញមកមុន ឬជើងក្រោយពីរចេញមកមុន កើតមកបន្តបន្ទាប់គ្មានអ្វីគ្រោះថ្នាក់ទេ ។ តែបើមេជ្រូកបែកទឹកភ្លោះ ៣-៦ម៉ោងហើយមិនឃើញកើតកូន ចេញមក ត្រូវតែរកអ្នកបច្ចេកទេសបសុពេទ្យមកជួយធ្វើអន្តរាគមន៍ ។

## ការថែទាំកូនជ្រូកទើបនឹងកើត

នៅក្នុងពោះមេ កូនជ្រូកទំលាយស្រោមសុកដោយខ្លួនវា និងកើតចេញមកក្រៅ។ ករណីខ្លះកូនជ្រូកកើតចេញមកទាំងស្រោម យើងចាំបាច់ហែកទំលាយស្រោម ដើម្បីយកកូនចេញមកកុំឱ្យកូនជ្រូកថប់ដង្ហើម។ កូនជ្រូកកើតមកភ្លាមប្រលាក់ប្រឡូសដោយទឹករំអិល យើងត្រូវចាប់លើកកូនជ្រូកថ្មីៗ យកកន្សែងស្ងួតស្អាតមកជូតជំរះរំអិលក្នុងមាត់ ច្រមុះ និងខ្លួនឱ្យបានស្ងួត ប្រើសរសៃអំបោះត្រាំក្នុងអាល់កុលចងទងផ្ចិត ចន្លោះពី ពោះ ៣សង់ទីម៉ែត្រ រួចយកកន្ត្រៃស្អាត (ជូតជំរះដោយអាល់កុល) កាត់ទងផ្ចិតឃ្លាតពីចំនុចចង ២សង់ទី-ម៉ែត្រ រួចជូតសំអាតកន្លែងកាត់ដោយថ្នាំក្រហម ឬអាល់កុលអ៊ីយ៉ូត។







ប្រើកន្ត្រៃកាត់ក្រចក ឬកន្ត្រៃកាត់ធ្មេញ កាត់ធ្មេញស្រួចទាំង៨របស់កូនជ្រូក (ធ្មេញខាងលើ ៤ ខាងក្រោម៤) កាត់យកចេញផ្នែកស្រួច ២ភាគ៣នៃធ្មេញ ធ្វើយ៉ាងណាកុំឱ្យមុតរបួសអញ្ចាញធ្មេញ។ ការកាត់ធ្មេញកាន់តែរហ័សកាន់តែល្អ (កុំឱ្យលើសពី ២៤ម៉ោងក្រោយពេលកើត) ពីព្រោះពេលនោះ ធ្មេញនៅទន់ឈាមហូរតិច។ ផលប្រយោជន៏នៃការកាត់ធ្មេញ ដើម្បីជៀសវាងកុំឱ្យកូនជ្រូកខាំដោះមេវា និងខាំដណ្តើមគ្នានៅពេលដែលវាបៅដោះមេរបស់វា។

## ការផ្តល់កំដៅឱ្យកូនជ្រូក

កូនជ្រូកទើបនឹងកើត ក្រោយពេលកាត់ផ្ចិត កាត់ធ្មេញរួចត្រូវយកដាក់ទ្រុង (ធុង) ដើម្បីផ្តល់កំដៅដល់កូនជ្រូក។

រដូវក្តៅផ្តល់កំដៅឱ្យកូនជ្រូក ១អាទិត្យ ក្រោយមកគ្រាន់តែផ្តល់កំដៅឱ្យកូនជ្រូកនៅពេលយប់ក្នុងរយៈពេល ២អាទិត្យ។



ក្នុងរដូវភ្លៀងធ្លាក់ត្រូវផ្តល់កំដៅឱ្យកូនជ្រូករយៈពេល ២អាទិត្យ។

ទ្រុងកំដៅត្រូវរៀបចំឱ្យធំល្មម (១ម៉ែត្រ គុណនឹង ០.៥ម៉ែត្រ) ដោយមានក្រាលចំបើង ឬស្លឹកចេកងាប់ ក្រណាត់ ឬបាវចាស់ៗស្ងួត ដោយប្រើអំពូលអគ្គិសនី ៧៥-១០០វ៉ាត់ ឬចង្ក្រានធ្យូង ដើម្បីកំដៅឱ្យកូនជ្រូក។ អំពូលត្រូវដាក់កំពស់ ៣០សង់ទីម៉ែត្រ



ចង្ក្រានធ្យូងត្រូវមានប្រដាប់ដាក់ ឃាំង ដើម្បីការពារកុំឱ្យកូនជ្រូកឆេះឬរលាកបាន

## ទឹកដោះដំបូង

ទឹកដោះដំបូងគឺជា ទឹកដោះដែលមេជ្រូកបញ្ចេញ ២-៣ថ្ងៃដំបូងក្រោយពេល បង្កើតកូនរួច។ ទឹក ដោះដំបូងមានសារជាតិចិញ្ចឹមសំរាប់ កូនបានគ្រប់គ្រាន់ និងមានអង់ទីគ័រសំរាប់ប្រឆាំងទប់ទល់នឹង ជំងឺឱ្យកូនជ្រូកដោយ មេជ្រូក បានបញ្ជូន តាម រយៈទឹកដោះ របស់វា។ ត្រូវដាក់ទៅឱ្យបោះដោះមេរបស់វា ប្រមាណ ៣០នាទី ក្រោយ ពេលដែលកូនជ្រូកបានកើត។ ក្នុងថ្ងៃដំបូងត្រូវឱ្យកូនជ្រូកទាំងអស់ បៅដោះដំបូង ពេលថ្ងៃឱ្យបៅ ២ម៉ោង រយៈពេលបៅគឺ ១០-១៥នាទីពេលយប់ឱ្យបៅក្នុងរយៈពេលពី ៣-៤ម៉ោងម្តង ចាប់ពី ២អាទិតឡើងទៅឱ្យកូណជ្រូកបៅ ដោយ សេរី ។

## ការចាក់បន្ថែមជាតិដែកឱ្យកូនជ្រូក

កូនជ្រូកត្រូវការជាតិដែកមួយថ្ងៃ ៧-៩មីលីក្រាម ប៉ុន្តែបរិមាណជាតិដែកដែលមេជ្រូកផ្តល់ ឱ្យកូនជ្រូកតាមរយៈទឹកដោះបានតែ១-២មីលីក្រាមសំរាប់កូនមួយក្បាលក្នុង១ថ្ងៃ ។ ដូច្នេះមួយថ្ងៃកូនជ្រូកខ្វះជាតិដែកពី ៦-៧មីលីក្រាម ។



ជាតិដែកជាសារធាតុមួយយ៉ាងសំខាន់សំរាប់បង្កើតឈាម ក្រហម ។ ដូច្នេះបើសិនជាកូនជ្រូកទទួលជាតិដែកតែតាមរយៈទឹកដោះមេ នោះសារពាង្គកាយរបស់ កូនជ្រូកនឹងខ្វះជាតិដែកធ្វើឱ្យកូនជ្រូកខ្វះឈាម បណ្តាលឱ្យខ្វះជីវជាតិទៅជាក្រិន និងរាគរូសលាមក ពណិស ។ ដូចេះយើងត្រូវចាកបំពេញជាតិដែកឱ្យទៅកូនជ្រូកនៅអាយុបាន៣ថ្ងៃ ចាក់ ១ម.លហើយចាក់លើកទី ២ នៅអាយុ១០ថ្ងៃ ចាក់២ម.លក្នុងមួយក្បាល ។

## វិធីផ្តាច់ដោះកូនជ្រូក



បង្ហាត់កូនជ្រូកឱ្យស៊ីចំណីផ្សំចាប់ពីអាយុ ៧-៨ថ្ងៃឡើងទៅ ស៊ីចំណីផង និងបៅដោះមេវាផង ។ បង្ហាំងកូនជ្រូកឱ្យនៅដាច់ពីមេរាល់ពេលឱ្យកូនជ្រូកបៅដោះនិងស៊ីចំណីផឹកទឹករួចហើយផ្តាច់ដោះត្រូវអនុវត្តជាបណ្តើរៗ ។ បន្ថយចំនួនការបៅដោះក្នុងមួយថ្ងៃៈ ថ្ងៃទី១ ឱ្យបៅ៥ដង ថ្ងៃទី២ឱ្យបៅ ៤ដង ថ្ងៃទី៣ ឱ្យបៅ ៣ដង ថ្ងៃទី៤ ឱ្យបៅ ២ដង ថ្ងៃទី៥ បៅ ១ដង និងថ្ងៃទី៦ផ្តាច់ ។ ឱ្យកូនជ្រូកស៊ីចំណីតែមួយប្រភេទមុននឹងក្រោយពេលផ្តាច់ដោះ ។ ពេលផ្តាច់ដោះគប្បីឱ្យកូនជ្រូកនៅក្នុងទ្រុងចាស់ប្រមាណ១អាទិត្យ បន្ទាប់មកនាំមេជ្រូកទៅដាក់ក្នុងទ្រុងផ្សេងទៀត ។